ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក ស ក

ក្រសួងកសិកម្ម

រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍បូកសរុប
# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំឆ្នាំ២០១៤-២០១៥ និងទិសដៅការងារសម្រាប់ឆ្នាំ២០១៥-២០១៦



សន្និបាតកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ថ្ងៃទី០៧-០៨ ខែមេសា ឆ្នាំ២០១៥

# មាតិកា


**I- សេចក្តីផ្តើម** ............ 1

**II- គោលនយោបាយនិងយុទ្ធសាស្រ្តសម្រាប់អភិវឌ្ឍន៍កសិកម្ម ២០១៤-២០១៨** ............ 1

**III- សមិទ្ធផលនៃការបង្កើនផលិតភាព ពិពិធកម្ម និង ពាណិជ្ជូបនីយកម្មកសិកម្ម** ............ 2

*១. សមិទ្ធផលជារួម* ............ 2

*២. សមិទ្ធផលនៃផលិតកម្មដំណាំស្រូវ ដំណាំរួមផ្សំនិងខ្វស្សាហាកម្ម* ............ 4

*៣- ការបង្កើនផលិតភាពលើដំណាំកៅស៊ូ* ............ 13

**IV- ការជំរុញផលិតកម្មសត្វនិងសុខភាពសត្វ** ............ 16

**V- ការអនុវត្តគោលនយោបាយកំណែទម្រង់វិស័យជលផល** ............ 20

**VI- ការអនុវត្តគោលនយោបាយកំណែទម្រង់វិស័យព្រៃឈើ** ............ 22

**VII- លទ្ធផលសម្រេចបានផ្នែកសេវាកម្មគាំទ្រនិងអភិវឌ្ឍន៍ធនធានមនុស្ស** ............ 24

*ក- លទ្ធផលសម្រេចបានលើការអនុវត្តគម្រោងវិនិយោគឯកជន* ............ 24

*ខ- ការរៀបចំលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យកសិកម្ម* ............ 25

*គ- ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* ............ 27

*ឃ- ការងារសហប្រតិបត្តិការអន្តរជាតិ* ............ 27

*ង- ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យកសិកម្ម* ............ 34

**VIII. បញ្ហាប្រឈម** ............ 36

**IX- ទិសដៅអនុវត្តឆ្នាំ២០១៥-២០១៦** ............ 38

*១. ផែនការផលិតកម្មដំណាំស្រូវ ដំណាំរួមផ្សំនិងខ្វស្សាហាកម្ម* ............ 38

*២. ផែនការផលិតកម្មដំណាំកៅស៊ូ* ............ 39

*៣. ផែនការផលិតកម្មសត្វ* ............ 39

*៤. ទិសដៅនិងផែនការក្នុងវិស័យជលផល* ............ 40

*៥. ទិសដៅនិងផែនការក្នុងវិស័យព្រៃឈើ* ............ 41

**X- សេចក្តីសន្និដ្ឋាន** ............ 42

# របាយការណ៍បូកសរុប
# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៤-២០១៥
# និងទិសដៅអនុវត្តឆ្នាំ២០១៥-២០១៦

## I- សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងម៉ឺងម៉ាត់បំផុតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយ និងជំរុញការអនុវត្ត «យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣» និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ ហើយនៅតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាព ដោយបានកំណត់យ៉ាងច្បាស់ថា ការលើកកម្ពស់ផលិតភាព ពិពិធកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ការកែទម្រង់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ពិសេសធនធានព្រៃឈើនិងជលផល គឺជាមុខព្រួញស្នូលដ៏សំខាន់ ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

អនុវត្តតាមគោលនយោបាយនិងយុទ្ធសាស្ត្រនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តោតការយកចិត្តទុកដាក់លើការបង្កើនផលិតភាព ការធ្វើពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ដោយបានជំរុញការអនុវត្តវិធានការចាំបាច់មួយចំនួនរួមមានៈ ការកសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធ ដែលបម្រើដល់ផលិតកម្មកសិកម្ម បង្កើនការផ្តល់សេវាបច្ចេកទេសកសិកម្មដល់កសិករ ការស្រាវជ្រាវបច្ចេកទេសកសិកម្មសំដៅបង្កើនទិន្នផលដំណាំនិងបន្សាំការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងនិងបង្កើនជីជាតិដីកសិកម្ម ការពង្រឹងសហគមន៍កសិកម្ម និងការកសាងនិងពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្ម។ ទន្ទឹមនឹងនេះក្រសួងក៏បានគិតគូផងដែរអំពីការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ព្រមទាំងខិតខំយ៉ាងខ្លាំងក្លាអនុវត្តវិធានការច្បាប់និងវិធានការបច្ចេកទេសឱ្យបានល្អក្នុងការគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិ ដូចជា ព្រៃឈើ ជលផល ដីកសិកម្ម ដើម្បីធានាចីរភាពនៃធនធាន និងរួមចំណែកការពារបរិស្ថាន។ ការខិតខំប្រឹងប្រែងទាំងអស់នេះ គឺក្នុងទិសដៅចូលរួមចំណែកបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ក៏ដូចជាការជួយបង្កើនប្រាក់ចំណូលជូនប្រជាកសិករ ការបន្តជំរុញការធ្វើកសិពាណិជ្ជកម្ម និងការបង្កើនចំណូលថវិកាជាតិតាមផ្នែកសំខាន់ៗនីមួយៗផងដែរ។

## II- គោលនយោបាយនិងយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍កសិកម្ម ២០១៤-២០១៨

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មរុក្ខាប្រមាញ់ និងនេសាទ២០១៤-២០១៨ បានរៀបចំស្របទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ និងយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។ ឯកសារនេះបានដាក់ឆ្លងការពិគ្រោះយោបល់ពីគ្រប់ភាគីពាក់ព័ន្ធ ទាំងដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងផ្នែកឯកជន។ ការកំណត់ទិសដៅគោលនយោបាយរួមរបស់ក្រសួងសម្រាប់អនុវត្តរយៈពេល៥ឆ្នាំគឺ៖

ទិសដៅគោលនយោបាយរួម (Overall Policy Goal)៖ “*ជំរុញកំណើនកសិកម្មឱ្យបានក្នុងរង្វង់៥%ក្នុងមួយឆ្នាំ តាមរយៈ ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ដោយយកចិត្តទុកដាក់ខ្ពស់លើការការពារនិងគ្រប់គ្រងធនធានព្រៃឈើនិងជលផលប្រកបដោយចីរភាព*”។

ដើម្បីសម្រេចបានទិសដៅគោលនយោបាយនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតកម្មវិធីថ្មីចំនួន៥ ដូចខាងក្រោមនេះ៖

### កម្មវិធីទី-១៖ បង្កើនផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម

ជំរុញកំណើនផលិតកម្មគ្រប់មុខដំណាំក្នុងរង្វង់១០%ក្នុងមួយឆ្នាំ តាមរយៈការបង្កើនការស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មសំដៅបង្កើនទិន្នផលដំណាំ លើកកម្ពស់គុណភាពផលិតផល ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដោយផ្សារ

ភ្ជាប់ជាមួយផលិតកម្មកសិកម្មតាមកិច្ចសន្យា និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងប្រើប្រាស់ដីប្រកបដោយនិរន្តរភាព។ កម្មវិធីនេះ ត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន២០និងត្រូវអនុវត្តដោយអង្គភាពជំនាញពាក់ព័ន្ធ។

**កម្មវិធីទី-២៖ជំរុញផលិតកម្មសត្វនិងសុខភាពសត្វ**

ជំរុញការចិញ្ចឹមសត្វក្នុងអត្រាកំណើន៣%ក្នុងមួយឆ្នាំ ដោយផ្អែកលើប្រសិទ្ធភាពនៃការពិសោធន៍ស្រាវជ្រាវ និងផ្សព្វផ្សាយ បង្កើនសមត្ថភាពបង្ការទប់ស្កាត់ជំងឺឆ្លងសត្វ និងជំងឺសូណូស៊ីស ធានាការផ្គត់ផ្គង់សត្វ សាច់សត្វ ប្រកបដោយអនាម័យ សុវត្ថិភាព និងបង្កើនសក្តានុភាពនៃការនាំចេញ។ កម្មវិធីនេះត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន៩។

**កម្មវិធីទី-៣៖ ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព**

បង្កើនការការពារ និងអភិរក្សធនធានជលផល ដោយលុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព ពង្រឹងសមត្ថភាពគ្រប់គ្រង១០០សហគមន៍នេសាទ និងជំរុញការអភិវឌ្ឍវារីវប្បកម្មក្នុងកំណើន១៥% រៀងរាល់ឆ្នាំ ដើម្បីធានាឱ្យបាននូវនិរន្តរភាពធនធានជលផល ព្រមទាំងកែលម្អគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផល សម្រាប់ការប្រើប្រាស់ក្នុងស្រុកនិងនាំចេញ។ កម្មវិធីនេះត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន១១។

**កម្មវិធីទី-៤៖ ការគ្រប់គ្រងធនធានព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាព**

បង្កើនការគ្រប់គ្រងព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាព តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពី ព្រៃឈើ ជំរុញការដាំឈើឱ្យបាន២៥.០០០ហ.តក្នុងមួយឆ្នាំ បង្កើតព្រៃការពារនិងតំបន់អភិរក្សសត្វព្រៃឱ្យបាន៥០.០០០ហ.តក្នុងមួយឆ្នាំ និងសហគមន៍ព្រៃឈើឱ្យបាន៣២សហគមន៍ក្នុង១ឆ្នាំ។ កម្មវិធីនេះ ត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន៨។

**កម្មវិធីទី-៥៖ ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស**

បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ការផ្តល់សេវាគាំទ្រនិងពង្រឹងសមត្ថភាពផ្នែកអប់រំ និងបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព។ កម្មវិធីនេះត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន១២ និងត្រូវអនុវត្តដោយអង្គភាពជំនាញពាក់ព័ន្ធ។

## III- សមិទ្ធផលនៃការបង្កើនផលិតភាព ពិពិធកម្ម និង ពាណិជ្ជូបនីយកម្មកសិកម្ម

### ១. សមិទ្ធផលជារួម

នៅក្នុងឆ្នាំ២០១៤នេះ ស្ថានភាពទឹកភ្លៀងបានចាប់ផ្តើមធ្លាក់យឺតជាងរដូវវស្សាឆ្នាំមុន និងបានធ្លាក់ច្រើននៅពេលចុងក្រោយ។ ជាមួយនឹងស្ថានភាពនេះ កសិករបានជួបប្រទះនូវគ្រោះរាំងស្ងួតនាដើមរដូវ និងទឹកជំនន់ទន្លេមេគង្គនាពាក់កណ្តាលរដូវវស្សា ដែលជះឥទ្ធិពលអវិជ្ជមានដល់ការងារបង្កបង្កើនផល។ ស្ថានភាពនៃអាកាសធាតុបែបនេះបានបណ្តាលឱ្យប៉ះពាល់ដល់ទំហំផ្ទៃដីបង្កបង្កើនផល ការលូតលាស់របស់ដំណាំស្រូវ និងបង្កការខូចខាតដល់ដំណាំរដូវវស្សាមួយចំនួន។ ផលត្រីទឹកសាបបានថយចុះ ដោយកត្តាទឹកជំនន់នៅឆ្នាំ២០១៤នេះ បានលិចដែននេសាទមានរយៈពេលខ្លី ដែលជាហេតុធ្វើឱ្យផលត្រីមានបរិមាណតិចនិងត្រីមានទំហំតូចៗ។ ការចិញ្ចឹមសត្វគ្រប់ប្រភេទមានការកើនឡើង ជាពិសេសបក្សីនិងជ្រូក ប៉ុន្តែគោ ក្របី និងកម្លាំងអូសទាញមានការថយចុះ។ ការផ្ទុះរាលដាលនៃជំងឺឆ្លងសត្វមិនមានជាបញ្ហាធំដុំគួរឱ្យព្រួយបារម្ភទេ។

លើសពីនេះទៀត បញ្ហាផលិតភាពទាបនៃផលិតផលកសិកម្ម ពិសេសផលិតកម្មដំណាំស្រូវ ជាកង្វល់មួយដែលត្រូវប្រឹងប្រែងដោះស្រាយ ហើយបញ្ហានេះមានការពាក់ព័ន្ធដល់បញ្ហាថ្លៃស្រូវ។ ក្រសួងបានមើលឃើញពីបញ្ហានេះ និងបានខិតខំជំរុញការបង្កបង្កើនផលស្រូវរបៀបទំនើប តាមបែបស៊ីជម្រៅជាប្រពលវប្បកម្ម ដើម្បីឱ្យទទួលបានទិន្នផលខ្ពស់និងគុណភាពល្អ ដោយប្រើប្រាស់យន្តូបនីយកម្ម និងបច្ចេកវិទ្យាថ្មីៗ ស្របតាមចរន្តសកលភាវូបនីយកម្ម។

ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ក្នុងក្របខណ្ឌនៃការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ព្រៃឈើនិងជលផល សំដៅជំរុញលើកកម្ពស់បង្កើនផលិតភាពកសិកម្ម ធានាឱ្យបាននូវបរិមាណនិងគុណភាព ធានាសន្តិសុខស្បៀង និងបង្កើនការនាំចេញកសិផល ក៏ដូចជាការធានានូវការគ្រប់គ្រងធនធានព្រៃឈើនិងជលផលប្រកបដោយចីរភាព។ មិនតែប៉ុណ្ណោះ វិស័យកសិកម្ម

បាននិងកំពុងស្រូបទាញនូវទុនវិនិយោគពីអ្នកវិនិយោគទាំងក្នុង និងក្រៅប្រទេសកាន់តែច្រើនឡើងជាលំដាប់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ទោះជួបប្រទះនូវកត្តាអវិជ្ជមានខ្លះៗក៏ដោយ។

## ក. ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ

វិស័យកសិកម្មបានចូលរួមចំណែកប្រហែល ២៨,៧% (ថ្លៃបច្ចុប្បន្ន) នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៤។ ដោយឡែក វិស័យឧស្សាហកម្មបានរួមចំណែកប្រមាណ ២៥,៥% និងវិស័យសេវាកម្មប្រហែល ៤០,៥%។ ការកើនឬថយចុះនូវចំណែកនៃការចូលរួមរបស់វិស័យកសិកម្ម គឺអាស្រ័យទៅនឹងការរីកលូតលាស់នៃផ្នែកពីរសំខាន់ផ្សេងទៀត ក្នុងវិស័យសេដ្ឋកិច្ច (វិស័យឧស្សាហកម្ម សំណង់ និងវិស័យសេវាកម្ម) ដែលជាការកត់សម្គាល់នាពេលកន្លងមក ការចូលរួមចំណែករបស់វិស័យកសិកម្មមានការប្រែប្រួលពី ៣៣,៩%-២៨,៧% ក្នុងចន្លោះឆ្នាំ២០១០-២០១៤ ដោយសារតែវិស័យឧស្សាហកម្ម សំណង់ និងវិស័យសេវាកម្មមានមានការកើនឡើងបន្ទាប់ពីឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចពិភពលោក។







**<u>ប្រភពទិន្នន័យ</u>**÷ ក្រសួងផែនការឆ្នាំ២០១៤

## ខ. សមាសភាគនៃអនុវិស័យក្នុងវិស័យកសិកម្ម

ពិនិត្យជារួមយើងសង្កេតឃើញថា នៅក្នុងវិស័យកសិកម្មទាំងមូល សមាសភាគចូលរួមចំណែកគិតជា (%) របស់ផលិតកម្មដំណាំគ្រប់ប្រភេទនាឆ្នាំ២០១៤ មានចំនួនជាងពាក់កណ្តាលពោលគឺកើនដល់ ៥៩,៤% នៃផលិតផលសរុបរបស់វិស័យកសិកម្ម។ ផលិតកម្មនេសាទ បានចូលរួមចំណែកបន្ទាប់ពីដំណាំ គឺមានប្រមាណ ២២,២% ផលិតកម្មសត្វបានចូលរួម១១,៣% និងអាជីវកម្មព្រៃឈើកើនប្រមាណ ៧% (ឆ្នាំ២០១៣ មានប្រមាណ ៥.៤៩%)។

ផលិតកម្មដំណាំ ពិសេសស្រូវនៅតែជាមុខដំណាំសំខាន់សម្រាប់ការរកចំណូលរបស់កសិករ។ មុខរបរអាជីវកម្មបន្ទាប់គឺសន្និដ្ឋានថា អាជីវកម្មនេសាទ (សមាសភាគប្រមាណពី២២%-២៣% ឆ្នាំ២០១០-២០១៤) និងផលិតកម្មសត្វមានការចូលរួមតិចជាងអាជីវកម្មនេសាទចន្លោះប្រមាណពី ១១%-១៣% ឆ្នាំ២០១០-២០១៤។ ដោយឡែក ចំពោះអាជីវកម្មព្រៃឈើមាននិន្នាការថយចុះជាបន្តបន្ទាប់ (សមាសភាគចូលរួមក្នុងវិស័យកសិកម្មមានត្រឹមតែប្រមាណ ៥,៤៩% នាឆ្នាំ២០១៣) ប៉ុន្តែនៅឆ្នាំ២០១៤ សមាសភាគនៃព្រៃឈើបានកើនដល់ ៧%។




**<u>ប្រភពទិន្នន័យ:</u>** ក្រសួងផែនការឆ្នាំ២០១៤

### គ. ស្ថានភាពកម្លាំងពលកម្មក្នុងវិស័យកសិកម្មឆ្នាំ២០០៩និងឆ្នាំ២០១៣

ក្នុងក្របខណ្ឌនៃសេដ្ឋកិច្ចប្រទេសកម្ពុជា កម្លាំងពលកម្មត្រូវបានបែងចែកជាបីប្រភេទសំខាន់គឺៈ (១)ពលកម្មក្នុងវិស័យកសិកម្ម (២)ពលកម្មក្នុងវិស័យឧស្សាហកម្ម (៣)ពលកម្មក្នុងវិស័យសេវាកម្ម។ ជាការសង្កេតគឺពលកម្មក្នុងវិស័យកសិកម្មបាននិងកំពុងធ្លាក់ចុះគួរឱ្យកត់សម្គាល់។ កម្លាំងពលកម្មក្នុងវិស័យកសិកម្មឆ្នាំ២០០៩ មានចំនួន៥៧,៦%នៃពលកម្មសរុប ហើយមានការថយចុះមកត្រឹមតែ៥៤,២%ឆ្នាំ២០១០។ ដោយឡែកឆ្នាំ២០១១ កម្លាំងពលកម្មក្នុងវិស័យកសិកម្មមានការកើនឡើងដល់៥៥,៨% និងបន្តថយចុះមកត្រឹមតែ៤៨,៧%នៅឆ្នាំ២០១៣។ ចរន្តនៃការធ្វើចំណាកស្រុក ពីជនបទមកកាន់ទីក្រុងនិងទៅក្រៅប្រទេសកំពុងមាននិន្នាការកើនឡើង។ ពលកម្មក្នុងវិស័យឧស្សាហកម្មមានតែ១៥,៩%នៅឆ្នាំ២០០៩ និងកើនដល់១៦,៩%ឆ្នាំ២០១១ និងមានការកើនដល់១៩,៩%នៅឆ្នាំ២០១៣។ ចំពោះពលកម្មក្នុងវិស័យសេវាកម្មមានចំនួន២៦,៥%ឆ្នាំ២០០៩ និងកើនដល់៣១,៥%នៅឆ្នាំ២០១៣ (ប្រភពព័ត៌មានពីក្រសួងផែនការ)។




**<u>ប្រភពទិន្នន័យ</u>**÷ ក្រសួងផែនការ

ជាក់ស្តែងក្នុងឆ្នាំទី១នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចសមិទ្ធផលនៃការបង្កើនផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្មដូចតទៅៈ

## ២. សមិទ្ធផលនៃផលិតកម្មដំណាំស្រូវ ដំណាំរួមផ្សំនិងឧស្សាហកម្ម

### ២.១- ផលិតកម្មដំណាំស្រូវ

នៅក្នុងឆ្នាំ២០១៤នេះស្ថានភាពទឹកភ្លៀងបានចាប់ផ្តើមធ្លាក់យឺតជាងរដូវវស្សាឆ្នាំមុន និងមានភ្លៀងធ្លាក់ច្រើននៅចុងរដូវវស្សា។ ជាមួយគ្នានេះដែរ កសិករបានជួបប្រទះនូវគ្រោះធម្មជាតិ (រាំងស្ងួតដើមរដូវនិងទឹកជំនន់ពាក់កណ្តាលរដូវ) ដែលជះឥទ្ធិពលអវិជ្ជមានដល់ការងារបង្កបង្កើនផល។ ស្ថានភាពនៃអាកាសធាតុបែបនេះ បានបណ្តាលឱ្យប៉ះពាល់ដល់ទំហំផ្ទៃដីបង្កបង្កើនផល ការលូតលាស់របស់ដំណាំស្រូវ និងបង្កការខូចខាតដល់ដំណាំរដូវវស្សាមួយចំនួន។

ជាលទ្ធផលជាក់ស្តែង ផលិតកម្មដំណាំស្រូវក្នុងឆ្នាំ២០១៤-២០១៥ អនុវត្តបានលើផ្ទៃដីចំនួន៣.០៥៥.៥០៧ហ.ត។ ផ្ទៃដីអាចប្រមូលផលបានមានចំនួនប្រមាណ៣.០២៨.៨៣៦ហ.ត និងបរិមាណផលសរុបទទួលបានចំនួន៩.៣២៤.៤១៦តោន។ ទិន្នផលមធ្យមប្រចាំឆ្នាំ២០១៤ ទទួលបានមានចំនួន៣,០៧៩តោន/ហ.ត។ អតិរេកស្បៀងគិតជាអង្ករមានចំនួនប្រមាណ៣.០១៣.៧៨៣តោន ឬស្មើនឹង ៤.៧០៩.០៣៦តោនស្រូវ។

រីឯលទ្ធផលនៃការងារបង្កបង្កើនផលស្រូវវស្សានិងប្រាំងសម្រាប់ឆ្នាំ២០១៤-២០១៥មានលម្អិតដូចខាងក្រោមៈ

#### ក- ការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៤

ជាមួយនឹងមូលបញ្ហាទាំងឡាយដូចបានរៀបរាប់ខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំជំរុញលើការងារបង្កបង្កើនផលរដូវវស្សាឆ្នាំ២០១៤ ដោយទទួលបានលទ្ធផលដូចខាងក្រោមៈ

- ផ្ទៃដីភ្ជួររាស់សរុបចំនួន២.៩៨០.១១៧ហ.ត (ក្នុងនោះភ្ជួររាស់ដោយគោក្របីចំនួន៧១៥.១៨៤ហ.ត ស្មើនឹង២៤% និងគ្រឿងយន្តចំនួន២.២៦៤.៩៣៣ហ.ត ស្មើនឹង៧៦%) តិចជាងឆ្នាំមុនចំនួន២៩៤.០៩៤ហ.ត
- ផ្ទៃដីសាបសរុបចំនួន១១៣.៣៦២ហ.ត តិចជាងឆ្នាំមុនចំនួន៤៥.៥៦៣ហ.ត
- ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន២.៥៦៤.៥៧២ហ.ត ស្មើនឹង១០៦,៣៦%នៃផែនការ២.៤១១.២០៧ហ.ត តិចឆ្នាំមុនចំនួន៣.១៥១ហ.ត រួមមាន៖
  - ស្រូវស្រាលចំនួន៦៦១.១០៦ហ.ត (ក្នុងនោះស្រូវបង្កើនរដូវចំនួន ១៧៦.២៤២ហ.ត) លើសឆ្នាំមុន៨៨៧ហ.ត
  - ស្រូវកណ្តាលចំនួន១.២៥៦.២៥៩ហ.ត លើសឆ្នាំមុន២០.២២១ហ.ត
  - ស្រូវធ្ងន់ចំនួន៥៥០.៥៨០ហ.ត តិចជាងឆ្នាំមុន៧.២៨១ហ.ត
  - ស្រូវចម្ការចំនួន៤៤.០៨៨ហ.ត តិចជាងឆ្នាំមុន៣.៤៥៥ហ.ត
  - ស្រូវឡើងទឹកចំនួន៥២.៥៣៩ហ.ត តិចជាងឆ្នាំមុនចំនួន១៣.៥២៣ហ.ត។
- ការងារប្រមូលផលស្រូវរដូវវស្សាសម្រេចបានលើផ្ទៃដីសរុបចំនួន២.៥៣៧.៩៧៦ហ.ត លើសឆ្នាំមុនចំនួន៥២.៤៥៦ហ.ត ដោយទទួលបានបរិមាណផលប្រមាណ៧.១៤៣.៥២១តោន តិចជាងឆ្នាំមុនចំនួន១២៧.៧៣០តោន។ ទិន្នផលជាមធ្យម២,៨១៥តោន/ហ.ត (ឆ្នាំមុនទិន្នផលមធ្យម២,៩២៥តោន/ហ.ត)។

### ខ- ការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៤-២០១៥

- ផ្ទៃដីអនុវត្តបានមានចំនួន៤៩០.៩៣៥ហ.ត លើសឆ្នាំមុន៦.២៣៨ហ.ត
- ផ្ទៃដីប្រមូលផលសម្រេចបានចំនួន៤៩០.៨៦០ហ.ត លើសឆ្នាំមុន៧.៤១៤ហ.ត
- បរិមាណផលទទួលបានចំនួន២.១៨០.៨៩៦តោន លើសឆ្នាំមុន៦២.១៨៦តោន
- ទិន្នផលទទួលបានប្រមាណ៤,៤៤៣តោន/ហ.ត (ឆ្នាំមុនទទួលបាន៤,៣៨៣តោន/ហ.ត)។

### គ- ស្ថានភាពប៉ះពាល់និងខូចខាតដោយគ្រោះធម្មជាតិ (ស្រូវរដូវវស្សា)

- **ផ្ទៃដីប៉ះពាល់ដោយគ្រោះធម្មជាតិ៖** ប៉ះពាល់លើផ្ទៃដីសរុបចំនួន១៩៨.៨៦៦ហ.ត ក្នុងនោះរាំងស្ងួតចំនួន១១៦.១២៩ហ.ត សត្វល្អិតចំនួន១.៦៥៤ហ.ត ទឹកជំនន់ចំនួន៨១.០៨៣ហ.ត។
- **ផ្ទៃដីខូចខាតដោយគ្រោះធម្មជាតិ៖** ខូចខាតលើផ្ទៃដីសរុបចំនួន៤៥.៩៤០ហ.ត ក្នុងនោះរាំងស្ងួតចំនួន២០.២៨៩ហ.ត សត្វល្អិតចំនួន១.៥៥១ហ.ត ទឹកជំនន់ចំនួន២៤.១០០ហ.ត។

ក្នុងរយៈពេល៥ឆ្នាំ គឺចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៤ ការងារបង្កបង្កើនផលស្រូវ មានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ទាំងផ្ទៃដីនិងបរិមាណផល ដោយសារការខិតខំស្តារឡើងវិញនូវផ្ទៃដីដែលបានខូចខាត និងម្យ៉ាងទៀតគឺអាស្រ័យដោយប្រជាកសិករមានភាពរីកចម្រើនក្នុងការគ្រប់គ្រងស្រែចម្ការ ការការកែលម្អបច្ចេកទេស និងការផ្លាស់ប្តូរពូជដែលមានទិន្នផលខ្ពស់។ លើកលែងតែក្នុងឆ្នាំ២០១៤ មានការថយចុះនូវបរិមាណផលបន្តិច បណ្តាលមកពីគ្រោះធម្មជាតិ ពិសេសស្ថានភាពរាំងស្ងួតធ្ងន់ធ្ងរអូសបន្លាយដើមរដូវ និងនៅកណ្តាលរដូវវស្សា។ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៣ យើងសង្កេតឃើញថា ថ្វីត្បិតផ្ទៃដីប្រមូលផលកើន២% តែទិន្នផលថយចុះ២,៦៧% ដែលនាំឱ្យបរិមាណផលសរុបថយចុះ០,៧% (ថយពី៩,៣៨លានតោននៅឆ្នាំ២០១៣ មកត្រឹមតែ៩,៣២លានតោននៅឆ្នាំ២០១៤)។ ការប្រែប្រួលកំណើនកើននិងថយចុះនេះ គឺបណ្តាមកពីកត្តាបម្រែបម្រួលអាកាសធាតុ ដែលបានជះឥទ្ធិពលដល់ផលិតកម្មកសិកម្ម ពិសេសគ្រោះរាំងស្ងួត។ ជាការកត់សម្គាល់ ផ្ទៃដីដែលបានប៉ះពាល់មានជិត២សែនហ.ត ហើយផ្ទៃដីដែលខូចខាតទាំងស្រុងដោយរាំងស្ងួតនៅឆ្នាំ២០១៤នេះ មានចំនួន២០.២៨៩ហ.ត ជាតួលេខខ្ពស់បំផុតក្នុងរយៈពេល៥ឆ្នាំកន្លងមក (ឆ្នាំ២០១៣ មានត្រឹមតែ១៧៨ហ.តប៉ុណ្ណោះ) ដែលធ្វើឱ្យប៉ះពាល់លើការលូតលាស់របស់ដំណាំ ហើយក៏ជាកត្តាចម្បងធ្វើឱ្យទិន្នផលស្រូវធ្លាក់ចុះផងដែរ។

តារាងទី១÷ ផលិតកម្មដំណាំស្រូវប្រចាំឆ្នាំ២០១០-២០១៤

| បរិយាយ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ប្រៀបធៀបកើន/ថយ ២០១៤/២០១៣ |
|---|---|---|---|---|---|---|
| ផ្ទៃដីដាំដុះ(ហ.ត) | 2,795,892 | 2,968,529 | 3,007,545 | 3,052,420 | 3,055,507 | 0.10% |
| ផ្ទៃដីប្រមូលផល(ហ.ត) | 2,777,323 | 2,766,617 | 2,980,297 | 2,968,967 | 3,028,836 | 2.02% |
| ទិន្នផល(តោន/ហ.ត) | 2.97 | 3.173 | 3.117 | 3.163 | 3.079 | -2.67% |
| បរិមាណផល(តោន) | 8,249,452 | 8,779,365 | 9,290,940 | 9,389,961 | 9,324,416 | -0.70% |
| បរិមាណអង្ករសល់(លានតោន) | 2,516,752 | 2,780,328 | 3,031,017 | 3,090,452 | 3,013,783 | -2.48% |
| គិតជាស្រូវសល់(លានតោន) | 3,932,425 | 4,344,263 | 4,735,964 | 4,828,832 | 4,709,036 | - 2.48% |

## ២.២. ពិពិធកម្មដំណាំរួមផ្សំនិងឧស្សាហកម្ម

ផ្ទៃដីផលិតកម្មដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន៩៥៣.៥៩៧ហ.ត លើសឆ្នាំមុនចំនួន ១២.៥៦៩ហត និងទទួលបានបរិមាណផលសរុបចំនួន១៤.៧២៧.២៦២តោន លើសឆ្នាំមុនចំនួន៤.១៩០.៥២០តោន ក្នុងនោះ៖

- ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន៧៧៥.៨២២ហ.ត (រដូវវស្សា៦៦៤.៩១៣ហ.ត និងរដូវប្រាំង១១០.៩០៩ហ.ត) និងមានបរិមាណផលចំនួន១៣.០២២.៩៦០តោន
- ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន១៧៧.៧៧៥ហ.ត (រដូវវស្សា១៥៨.៧១៦ហ.ត និងប្រាំង១៩.០៥៩ហ.ត) ទទួលបានបរិមាណផលសរុបចំនួន១.៧០៤.៣០២តោន។

ជាការកត់សម្គាល់ឃើញថា ផ្ទៃដីផលិតកម្មមានការកើនឡើង និងផលិតភាពក៏មានការកើនឡើងព្រមគ្នា ដែលនេះឆ្លុះបញ្ចាំងអំពីការប្រែប្រួលជាវិជ្ជមាន នៅក្នុងប្រព័ន្ធផលិតកម្មដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម តាមរយៈការធ្វើប្រពលវប្បកម្មដោយប្រើប្រាស់បច្ចេកទេសសមស្រប និងការប្រើប្រាស់ធាតុចូលមានគុណភាព។

## ២.៣ ការផលិតនិងផ្សព្វផ្សាយពូជដំណាំ

ពូជជាកត្តាគន្លឹះមួយដ៏សំខាន់កំណត់គុណភាព និងផលិតភាពផលិតកម្មដំណាំ។ បណ្តាវិធានការពាក់ព័ន្ធការងារស្រាវជ្រាវនិងផលិតពូជដំណាំដែលមានគុណភាពល្អ ត្រូវបានជំរុញយ៉ាងសកម្ម ដើម្បីអភិវឌ្ឍន៍ផ្នែកនេះ សំដៅផ្សព្វផ្សាយជូនប្រជាកសិករប្រើប្រាស់ឱ្យបានកាន់តែទូលំទូលាយ និងស្របតាមលក្ខខណ្ឌកេ្សត្រ-បរិស្ថាននៃតំបន់ដាំដុះនីមួយៗ។ គួរឱ្យកត់សម្គាល់ផងដែរថា បច្ចុប្បន្ននេះ ទាំងផ្នែកឯកជន ដៃគូអភិវឌ្ឍន៍ ក៏ដូចជាសហគមន៍កសិករ បាននិងកំពុងចូលរួមយ៉ាងសកម្មជាមួយអង្គភាពជំនាញនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការលើកកម្ពស់ការងារនេះ។ កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ បានចូលរួមចំណែកធ្វើឱ្យមានការផ្លាស់ប្តូរឥរិយាបទ និងទម្លាប់ក្នុងចំណោមប្រជាកសិករស្តីពីការប្រើប្រាស់ពូជនៅក្នុងផលិតកម្មគួរឱ្យកត់សម្គាល់។ ជាពិសេស ការប្រើប្រាស់ពូជស្រូវសំខាន់ៗក្នុងចំណោម១០ពូជ កំពុងទទួលបាននូវការវាយតម្លៃជាវិជ្ជមានពីសំណាក់ប្រជាកសិករ ព្រមទាំងមានការទទួលយកពីវិស័យឯកជនផងដែរ។

ជារួមស្ថានភាពនៃប្រើប្រាស់ពូជស្រូវសុទ្ធល្អនៅក្នុងផលិតកម្មដំណាំស្រូវ កំពុងតែមានភាពប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ក្នុងឆ្នាំ២០១៤កន្លងមកនេះ ជាង២៥%នៃគ្រួសារកសិករដាំដុះដំណាំស្រូវទូទាំងប្រទេស ត្រូវបានវាយតម្លៃថាមានលទ្ធភាពទទួលបានពូជស្រូវសុទ្ធល្អយកទៅប្រើប្រាស់ បើធៀបនឹងឆ្នាំ២០១៣ ដែលមានត្រឹមតែ ២៥%។ ដោយឡែក ក្នុងឆ្នាំ២០១៤នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផលិតពូជដំណាំមានគុណភាពនិងផ្សព្វផ្សាយជូនកសិករប្រើប្រាស់មានចំនួន១.៤០១,៦៣៥តោន ក្នុងនោះ៖

- គ្រាប់ពូជស្រូវចំនួន១.៣៣២តោន (គ្រាប់ពូជស្រូវអ៊ីអ៊ែ៦៦ ចំនួន៨៩០តោន គ្រាប់ពូជស្រូវជលសា ចំនួន ៣៩៥តោន និងគ្រាប់ពូជស្រូវផ្សេងៗទៀតចំនួន៤៧តោន )
- គ្រាប់ពូជដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មចំនួន៦៩,៦៣៥តោន (គ្រាប់ពូជពោតដំណើប ពោតផ្អែម ត្រសក់ ល្ពៅ សណ្តែកកួរ សណ្តែកសៀង សណ្តែកបាយ សណ្តែកប្រេង និងប៉េងប៉ោះ)។

## ២.៤ ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម

សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មត្រូវបានពង្រឹងនិងពង្រីក តាមរយៈសកម្មភាពផ្សេងៗរួមមាន៖ ការស្រាវជ្រាវ ការបណ្តុះបណ្តាលនៅក្នុងថ្នាក់ និងនៅទីវាលឬសាលារៀនស្រែកសិករ ការអនុវត្តស្រែបង្ហាញ ការដំណើរការទិវាស្រែ និងទស្សនៈកិច្ចសិក្សា។ ក្នុងឆ្នាំ២០១៤កន្លងមកនេះ ធនធានមនុស្សនៅថ្នាក់ក្រោមជាតិបម្រើឱ្យវិស័យកសិកម្មក៏ត្រូវបានពង្រីកបន្ថែមទៀតផងដែរ។ ជាសរុប មន្ត្រីបច្ចេកទេសថ្នាក់ក្រោមជាតិ ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ក្រុមប្រឹក្សាឃុំ និងកសិករប្រមាណ៣០.៨៥៦នាក់ ក្នុងនោះស្រ្តីចំនួន១៤.០៣៩នាក់ ស្មើនឹង៤៥,៥% បានចូលរួមពាក់ព័ន្ធ និងទទួលផលប្រយោជន៍ពីសេវាផ្សព្វផ្សាយកសិកម្ម។ ជាពិសេសគឺភ្នាក់ងារផ្សព្វផ្សាយភូមិ-ឃុំ ដែលត្រូវបានចាត់ទុកជាដៃគូសហការដ៏សំខាន់ ក្នុងការនាំសេវាផ្សព្វផ្សាយកសិកម្ម ឱ្យកាន់តែខិតជិតប្រជាកសិករក៏ត្រូវបានពង្រឹងនិងពង្រីកផងដែរ។ គិតត្រឹមដំណាច់ឆ្នាំ២០១៤នេះ នៅទូទាំងប្រទេសមានកសិករសរុបចំនួន៩.៦៤០នាក់ ទទួលបានការបណ្តុះបណ្តាលពង្រឹងសមត្ថភាពឱ្យក្លាយជាភ្នាក់ងារផ្សព្វផ្សាយភូមិ-ឃុំ ក្នុងនោះ៖ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិចំនួន៨.៧៩៤នាក់ (ស្រ្តីចំនួន៧០១នាក់ ស្មើនឹង ៨%) និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំចំនួន៨៤៦នាក់ (ស្រ្តីចំនួន៣២៣នាក់ ស្មើនឹង៣៨%)។

ព្រមជាមួយនេះ ដើម្បីពង្រីកការទទួលបាននូវព័ត៌មាន និងចំណេះដឹងបច្ចេកទេសកសិកម្មសកម្មភាពផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ក៏ត្រូវបានជំរុញតាមរយៈការបោះពុម្ពនិងចែកចាយឯកសារបច្ចេកទេស៣៧.៨៥០ច្បាប់ ការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានសារធារណៈដូចជាទូរទស្សន៍ វិទ្យុ បានចំនួន១៥៦លើក។

សន្និបាតកសិករទូទាំងប្រទេសត្រូវបានរៀបចំជារៀងរាល់ឆ្នាំតាំងពីឆ្នាំ២០១០។ មកទល់ឆ្នាំ២០១៤ មានកសិករចូលរួមប្រកួតប្រជែងដណ្តើមជ័យលាភីសរុបចំនួន៧៤២នាក់ (ឆ្នាំ២០១០ចំនួន១៤៩នាក់ ឆ្នាំ២០១១ចំនួន១៨៦នាក់ ឆ្នាំ២០១២ចំនួន១៣៨នាក់ ឆ្នាំ២០១៣ចំនួន១៥៣នាក់ និងឆ្នាំ២០១៤ចំនួន១១៦នាក់)។ កសិករទទួលជ័យលាភីសរុបទូទាំងប្រទេសមានចំនួន១៦០នាក់ (ស្រ្តី២១នាក់)។

## ២.៥ ការអភិវឌ្ឍសហគមន៍កសិកម្ម

ដោយមានការចូលរួមសហការពីដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិ ការអភិវឌ្ឍសហគមន៍កសិកម្មក៏បាននិងកំពុងទទួលបានការយកចិត្តទុកដាក់លើកកម្ពស់ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍកសិកម្មមានលក្ខណៈប្រមូលផ្តុំក្នុងភាពជាដៃគូជាមួយផ្នែកឯកជននានា ទទួលបានទាំងបច្ចេកវិទ្យាថ្មីនិងឥណទាន និងធានាស្ថេរភាពនៃការផ្គត់ផ្គង់ផលិតផលទៅកាន់ទីផ្សារក្នុងស្រុកនិងក្រៅស្រុក និងជាពិសេសអភិវឌ្ឍន៍សហគមន៍កសិកម្ម ឱ្យក្លាយជាសហគ្រាសកសិកម្មជនបទ សំដៅលើកកម្ពស់សេដ្ឋកិច្ច-សង្គមជនបទ។ ក្នុងឆ្នាំ២០១៤កន្លងមកនេះ ក្រសួងបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការសហគមន៍កសិកម្មសម្រេចបានចំនួន៧០សហគមន៍។ មកទល់បច្ចុប្បន្ននេះ នៅទូទាំងប្រទេសមានសហគមន៍កសិកម្មសរុបចំនួន៥៥៦សហគមន៍ មានសមាជិកសរុបចំនួន ៦៤.៦៦២នាក់ (ស្រ្តីចំនួន៣៩.៨៥០នាក់ ឬស្មើនឹង៦១,៦%) ហើយមានទុនសរុបចំនួន ២៦.៩៧០.៦១២.៩៩៧រៀល។




*ក្រាហ្វិកទី១៖ ចំនួនសហគមន៍កសិកម្មពីឆ្នាំ២០០៣ ដល់ ២០១៤*




*ក្រាហ្វិកទី២៖ របាយសហគមន៍កសិកម្មតាមខេត្តនីមួយៗ*

## ២.៦ ការខារជំរុញយន្តូបនីយកម្មកសិកម្ម

បច្ចុប្បន្នការប្រើប្រាស់គ្រឿងយន្តនិងឧបករណ៍កសិកម្ម កំពុងមាននិន្នាការកើនឡើងគួរឱ្យកត់សម្គាល់ ដែលជាបច្ច័យមួយបង្ហាញអំពីដំណើរការវិវត្តនៃយន្តូបនីយកម្មក្នុងវិស័យកសិកម្មកម្ពុជា។ ជាក់ស្តែងក្នុងឆ្នាំ២០១៤កន្លងមកនេះ ៧៦%នៃផ្ទៃដីដំណាំស្រូវរដូវវស្សាសរុបត្រូវបានភ្ជួររាស់រៀបចំដោយគ្រឿងយន្តកសិកម្ម។ ដោយឡែក ការប្រើប្រាស់គ្រឿងយន្តនិងឧបករណ៍កសិកម្មសំខាន់ៗដូចជា ម៉ាស៊ីនបូមទឹក ម៉ាស៊ីនច្រូតស្រូវ ម៉ាស៊ីនបោកស្រូវ ម៉ាស៊ីនកិនស្រូវក៏មាននិន្នាការកើនឡើងផងដែរបើធៀបនឹងឆ្នាំ២០១៣។

ទាំងអស់នេះបញ្ជាក់ថាខ្សែសង្វាក់ផលិតកម្ម និងកែច្នៃដំណាំកសិកម្ម កំពុងត្រូវបានធ្វើទំនើបភាវូបនីយកម្មជាបណ្តើរៗ ដែលជាកត្តាគន្លឹះមួយចូលរួមដោះស្រាយបញ្ហាកង្វះខាតកំលាំងពលកម្មនៅទីជនបទ ដែលកំលាំងពលកម្មមួយចំនួនធំត្រូវបានស្រូបយកដោយវិស័យឧស្សាហកម្មនិងសេវាកម្ម និងលើកកម្ពស់ផលិតភាពនិងគុណភាពផលិតផលកសិកម្ម។




*ក្រាហ្វិកទី៣៖ ប្រៀបធៀបគ្រឿងយន្តកសិកម្មពីឆ្នាំ ២០១២-២០១៤*

## ២.៧ ការជំរុញការនាំចេញផលិតផលកសិកម្ម

ក្នុងឆ្នាំ២០១៤ ការជំរុញការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារតំបន់ និងពិភពលោកសម្រេចបានចំនួន៤៧មុខ មានបរិមាណសរុបចំនួន៣.៤៤៥.២៦៦,៥៦តោន។ ការនាំចេញអង្ករកើនឡើងតិចតួច គឺកើនពី៣៧៨.៨៥៦តោន ក្នុងឆ្នាំ ២០១៣ ដល់ ៣៨៧.០៦១តោន ក្នុងឆ្នាំ២០១៤ ឬស្មើ២,២% ធៀបនឹងឆ្នាំ២០១៣ ដែលក្នុងនោះ អង្ករសគ្រប់ប្រភេទមានចំនួន ១៥៧.៤១៧តោន អង្ករក្រអូបគ្រប់ប្រភេទចំនួន២១០.៥៩៤តោន និងអង្ករចំហុយចំនួន១៩.០៥០តោន។ ក្នុងចំណោមអង្ករក្រអូបទាំងនោះ អង្ករផ្ការំដួល/ផ្កាម្លិះមានចំនួន១៤៥.៩២៣តោន (ជាប់លំដាប់លេខ១) អង្ករក្រអូបចម្រុះមានចំនួន៣៩.១០៦តោន (ជាប់លំដាប់លេខ២) អង្ករក្រអូបនាងម្លិះមានចំនួន១៩.៤៣២តោន (ជាប់លំដាប់លេខ៣) អង្ករសូម៉ាលីមានចំនួន ៤.៩៧៥តោន (ជាប់លំដាប់លេខ៤) អង្ករក្រអូបភ្លីមានចំនួន៦៦៨តោន និងអង្ករក្រអូបសរីវង្គមានចំនួន៤៨៩តោន។ អង្កររបស់ពូជស្រូវផ្ការំដួល ត្រូវបានចាត់ទុកជា អង្ករមានរស់ជាតិឆ្ងាញ់ជាងគេបំផុត រយៈពេល៣ឆ្នាំជាប់ៗគ្នាពីឆ្នាំ២០១២ រហូតដល់ឆ្នាំ២០១៤។




*ក្រាហ្វិកទី៤៖ ស្ថានភាពនាំអង្ករចេញពីឆ្នាំ ២០១០-២០១៤*




*ក្រាហ្វិកទី៥៖ ការនាំចេញតាមប្រភេទអង្ករ*




*ក្រាហ្វិកទី៦៖ ការនាំចេញតាមប្រភេទអង្ករក្រអូប*

អង្ករត្រូវបាននាំចេញទៅកាន់ប្រទេសចំនួន៥៩ ដែលភាគច្រើនជាប្រទេសក្នុងសហគមន៍អឺរ៉ុប។ ប្រទេសដែលជាទីផ្សារអង្ករធំៗទាំង១០របស់កម្ពុជារួមមាន៖ ប្រទេសបារាំងនៅក្បាលលំដាប់លេខ១ដែល គឺមានចំនួន៧០.០៧៧តោន ប្រទេសប៉ូឡូញចំនួន៥៥.៩៣៨តោន ប្រទេសចិនចំនួន៤៨.៩៨០តោន ប្រទេសម៉ាឡេស៊ីចំនួន៤៨.១២០តោន ប្រទេសហូឡង់ចំនួន៣២.០២៤តោន ប្រទេសប៊ែលហ្សិកចំនួន១៧.៥១៥តោន សាធារណរដ្ឋឆែកចំនួន១៣.១៩៨តោន ប្រទេសអង់គ្លេសចំនួន១១.៨២៩តោន ប្រទេសអេស្ប៉ាញចំនួន១១.៧២៨តោន និងប្រទេសអាឡឺម៉ង់ចំនួន១១.៥០២តោន។

ក្រុមហ៊ុននាំអង្ករចេញសរុបមានចំនួន៨៦ ដែលនាំមុខគេដោយក្រុមហ៊ុនចំនួន៥នោះគឺ៖ Khmer Food ក្នុងបរិមាណ ៤៥.៧៦៦តោន ក្រុមហ៊ុន Amru Rice ក្នុងបរិមាណ៤៣.០៦៤តោន ក្រុមហ៊ុនបៃតង ក្នុងបរិមាណ ២៨.៧១៤តោន ក្រុមហ៊ុន Golden Rice ក្នុងបរិមាណ២៥.២៣៥តោន និងក្រុមហ៊ុន International Rice Trading ក្នុងបរិមាណ២០.៦៩៤តោន។

ទំហំនៃការនាំចេញកសិផលទៅកាន់ទីផ្សារប្រទេសចិនក្នុងឆ្នាំ២០១៤ ក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ។ ជាក់ស្តែងការនាំចេញផលិតផលដំឡូងមីសរុបមានចំនួន១១៩.៥៩៧តោន (ក្នុងនោះ ចំណិតដំឡូងមីក្រៀមចំនួន៩៤.២០៩តោន

ម្សៅដំឡូងមីចំនួន១២.៣៧០តោន និងកាកសំណល់ដំឡូងមីចំនួន១២.៩៩៦តោន) គឺកើនទ្វេដងបរិមាណនាំចេញសរុបក្នុងឆ្នាំ២០១៣ ដែលមានចំនួនតែ៥៥.២០២តោន។ ព្រមជាមួយគ្នានេះ ក្រុមហ៊ុនចំនួន១២បន្ថែមទៀតក៏ត្រូវបានត្រួតពិនិត្យ វាយតម្លៃ និងចុះបញ្ជីជាក្រុមហ៊ុន មានលក្ខណៈសម្បត្តិអាចនាំចេញដំឡូងមីក្រៀមរបស់កម្ពុជាទៅកាន់ប្រទេសចិន។ ដូច្នេះមកទល់ពេលនេះ មានក្រុមហ៊ុនចំនួន៥៧ ត្រូវបានពិនិត្យវាយតម្លៃ និងចុះបញ្ជីទទួលស្គាល់ ជាក្រុមហ៊ុននាំចេញចំណិតដំឡូងមីក្រៀមទៅកាន់ទីផ្សារប្រទេសចិន។

ទីផ្សារផលិតផលកសិកម្មកម្ពុជានៅក្នុងប្រទេសចិននឹងត្រូវបានពង្រីកបន្ថែមទៀតក្នុងពេលខាងមុខនេះ ក្រោយពេលដែលពិធីសារចំនួន៣ទៀតត្រូវបានអនុវត្តពេញលេញរួមមាន៖ ពិធីសារស្តីពីការនាំចេញផលិតផលពោតកម្ពុជាទៅកាន់ប្រទេសចិន ពិធីសារស្តីពីនាំចេញផ្លែចេក ស្វាយ និងសណ្តែកសៀងកម្ពុជាទៅកាន់ប្រទេសចិន និងពិធីសារស្តីពីការនាំចេញអង្ករទៅប្រទេសចិន ដែលឯកសារពាក់ព័ន្ធទាំង៣នេះត្រូវបានចុះហត្ថលេខារួចហើយ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយនឹងអគ្គរដ្ឋបាលត្រួតពិនិត្យគុណភាព អធិការកិច្ច និងចត្តាឡីស័កនៃសាធារណរដ្ឋប្រជាមានិតចិនកំឡុងពេលកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ាននៅប្រទេសមីយ៉ានម៉ាក្នុងឆ្នាំ២០១៤។ បន្ថែមលើនេះ ក្រសួងបាន និងកំពុងរៀបចំពិធីសារស្តីពីការនាំចេញផ្លែស្វាយទៅកាន់សាធារណរដ្ឋកូរ៉េ។

## ២.៨ ការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាដំណាំកសិកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) ជាអង្គភាព ជំនាញបានបង្កើតពូជដំណាំកសិកម្មថ្មីៗ ថែរក្សានូវគុណភាពគ្រាប់ពូជនៃពូជដំណាំដែលបានបញ្ចេញ រួមទាំងផ្សព្វផ្សាយនូវពូជទាំងនោះ និងវិធីសាស្ត្រសម្រិតសម្រាំងគ្រាប់ពូជស្រូវបែបកសិករ បច្ចេកវិទ្យាដាំដុះ ថែទាំ និងប្រមូលផល រួមទាំងចងក្រង បោះពុម្ពនិងផ្សព្វផ្សាយអត្ថបទវិទ្យាសាស្ត្រ ព្រមទាំងឯកសារបច្ចេកវិទ្យា ជូនដល់កសិករ និងអ្នកពាក់ព័ន្ធទូទាំងប្រទេស។ ជាក់ស្តែងការងារជាច្រើនត្រូវបានអនុវត្តនិងផ្តល់លទ្ធផលសំខាន់ៗរួមមាន៖

- អត្ថបទវិទ្យាសាស្ត្រ៖ បានសរសេរនិងបោះពុម្ពអត្ថបទ នៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រអន្តរជាតិនិងសៀវភៅសន្និសីទនានាបានចំនួន១៣អត្ថបទ
- ការអភិរក្សពូជដំណាំកសិកម្ម៖ បានប្រមូលយកមករក្សាទុកបន្ថែមនូវពូជដំណាំផ្សេងៗចំនួន៦៩៤សំណាក។ ជារួមនៅក្នុងរយៈពេលមួយឆ្នាំ២០១៤នេះ វិទ្យាស្ថានបានប្រមូលនិងបន្តអភិរក្សលើដំណាំចំនួន៣០ប្រភេទ ដែលក្នុងនោះមានស្រូវចំនួន៦.៦២១បញ្ជីក/សំណាក និងដំណាំផ្សេងចំនួន២៩ប្រភេទរួមមាន៩៩៨ សំណាក សរុបទាំងអស់មានចំនួន៧.៦១៩បញ្ជីក/សំណាក
- ការបញ្ចេញពូជដំណាំថ្មីៗ៖ វិទ្យាស្ថានបានបញ្ចេញពូជដំណាំថ្មីៗចំនួន៣ពូជ ក្នុងនោះមានពូជស្រូវចំនួន២ពូជ គឺ (១)ពូជស្រូវ ផ្ការំដួលប្រាំង ដែលជាពូជស្រូវក្រអូបប្រណីតដូចពូជស្រូវផ្ការំដួលវស្សាដែរ តែអាចដាំដុះបាននៅរដូវទឹកស្រកនាចុងខែតុលានិងក្នុងខែវិច្ឆិកា ដោយប្រមូលផលនាខែកុម្ភៈនិងដើមខែមីនា ដោយសារពូជស្រូវនេះនៅប្រកាន់រដូវខ្សោយនៅឡើយ។ ទិន្នផលអាចដល់៤,៥ត/ហ.ត កម្ពស់ជាមធ្យម១,១ម ប្រវែងកួរជាមធ្យម២២ស.ម និងគ្រាប់ស្រូវ១០០គ្រាប់មានទម្ងន់២,៩ក្រ។ អង្ករលូនវែងមានប្រវែងគ្រាប់៧,២ម.ម បន្ទារកម្រាស់២,១ម.ម និងមានកម្រិតអាមីឡូស១៤,៨% និង (២)ពូជស្រូវ ខា១៤ (CAR14, CAR=Cambodian Rice) ដែលជាពូជស្រូវស្រាលមិនប្រកាន់រដូវ មានប្រភពដើមពីអ៊ីរី (IR06L164)។ ពូជនេះជាមធ្យមមានអាយុកាល៩៥ថ្ងៃ (ព្រោះ) កម្ពស់០,៩ម ប្រវែងគ្រាប់អង្ករ៦,៨ម.ម បន្ទារកម្រាស់១,៨ម.ម មានកម្រិតអាមីឡូ១៨,៦% និងទិន្នផល៤,២ត/ហ.ត។ ពូជស្រូវខា១៤ អាចផ្តល់ផលរហូតដល់៧,៥ត/ហ.ត។ ជាមួយគ្នានេះ ពូជពោតដំណើប ស៊ីអឹម១ (CM1, CM=Cambodian maize) ដែលកសិករអាចទុកពូជដាំបន្តទៀតបាន និងអាចដាំដុះបាននៅតំបន់ចម្ការនិងស្រែទំនាបរំពឹងទឹកភ្លៀងបន្ទាប់ពីប្រមូលផលស្រូវវស្សារួចភ្លាម។ ពូជស៊ីអឹម១ ជាមធ្យមចេញផ្កាឈ្មោលរយៈពេល៣៧ថ្ងៃ និងផ្កាញីរយៈពេល៤០ថ្ងៃបន្ទាប់ពីដាំ កម្ពស់១,៧ម ប្រវែងផ្លែ១៧ស.ម ចំនួនផ្លែក្នុង១ដើមមានចំនួន១ និងទិន្នផលគ្រាប់ទុំ៦ត/ហ.ត

- **ប្រព័ន្ធដាំដុះដំណាំដែលមាននិរន្តរភាព:** គួរកត់សម្គាល់ថា នៅតំបន់ស្រោចស្រពពេញលេញក្នុងមួយឆ្នាំ ការធ្វើស្រូវដើមរដូវវស្សា ស្រូវវស្សា (ប្រើពូជស្រូវផ្ការំដួល ផ្ការមៀត ឬពូជស្រូវក្រអូបផ្សេងទៀត) និងធ្វើបន្ថែមឬសណ្តែកក្នុងរដូវប្រាំងជាប្រព័ន្ធដាំដុះផ្តល់ផលចំណេញនិងរក្សាគុណភាពដីសមស្របជាងគេ (ក្រាហ្វិកទី៧)។




***ក្រាហ្វិកទី៧៖*** *បរិមាណផលស្រូវមធ្យម៣ឆ្នាំ (PY) ទុនចំណាយ (Input) ប្រាក់ចំណូល (Income) និងប្រាក់ចំណេញដុល (GM) របស់ប្រព័ន្ធដាំដុះ ១)ស្រូវប្រាំង+ដើមរដូវវស្សា (DS+EWS) ២)ស្រូវប្រាំង+ស្រូវវស្សា (DS+WS) ៣)ស្រូវដើមរដូវវស្សា+ស្រូវវស្សា (EWS+WS) និង៤)ស្រូវប្រាំង+ស្រូវដើមរដូវវស្សា+ស្រូវវស្សា (DS+EWS+WS)*

- **ប្រសិទ្ធិភាពនៃបង្គុំបច្ចេកវិទ្យាថ្មី:** ផលិតភាពស្រូវវស្សាជាមធ្យមអាចកើនរហូតដល់៤តោន/ហាត គឺច្រើនជាងផលិតភាពដែលទទួលបានជាមធ្យមក្នុងឆ្នាំ២០១៣ ជាង១តោន គឺ (១)កសិករដាំដុះពូជស្រូវដែលបានបញ្ចេញឱ្យសមស្របទៅតាមលក្ខខណ្ឌដាំដុះ (ស្រែលើ ស្រែកណ្តាល និងស្រែក្រោម) (២)ប្រើប្រាស់គ្រាប់ពូជសុទ្ធល្អ និង (៣)ស្គាល់ច្បាស់នូវក្រុមដីស្រែ និងប្រើប្រាស់ជីគីមីទៅតាមកម្រិតណែនាំរបស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (ក្រាហ្វិកទី៨)




***ក្រាហ្វិកទី៨៖*** *ទិន្នផលមធ្យម និងប្រាក់ចំណេញដុលរបស់ការអនុវត្តតាមបង្គុំបច្ចេកទេស និងការបញ្ចូលពូជស្រូវធៀបជាមួយការដាំដុះតាមទម្លាប់របស់កសិករ*

- **វិធានការកម្ចាត់ខ្យងស៊ីស្រូវ៖** បានបញ្ជាក់ថា ថ្នាំនុយ Mollucide6GB និង Osbuvang5G មានប្រសិទ្ធភាពដូចគ្នាក្នុងការកម្ចាត់ខ្យងពណ៌មាសឬខ្យងស៊ីស្រូវដោយមិនបណ្តាលឱ្យងាប់ត្រី កំពិស និងក្តាមនៅក្នុងស្រែឡើយ។ កសិករត្រូវតែប្រើប្រាស់ថ្នាំនុយទាំងពីរប្រភេទនេះឆ្លាស់គ្នា ជៀសវាងការបន្សុំាបានរបស់ខ្យង
- **អាហារូបត្ថម្ភរបស់ពូជស្រូវផ្ការំដែង៖** បានយកពូជស្រូវផ្ការំដែងទៅវិភាគអាហារូបត្ថម្ភ (Nutrition value) លើអង្ករសម្រិតនិងអង្ករសម្រូបនៅមន្ទីរពិសោធន៍បរទេសស្តង់ដាអន្តរជាតិក្នុងឆ្នាំ២០១៤នេះជាបន្ថែមទៀតដោយបានទទួលលទ្ធផលដូចមានក្នុងតារាង១.៨.១។ ចំពោះអង្ករសរបស់ពូជស្រូវផ្ការំដួលនិងសែនពិដោរ លទ្ធផល

វិភាគមិនបានទាំងអស់ ដោយសារមន្ទីរពិសោធន៍នាពេលវិភាគនោះមិនទាន់មានលទ្ធភាពវិភាគ។ លក្ខណៈដែលគួរឱ្យចាប់អារម្មណ៍បំផុតនោះគឺពូជស្រូវផ្ការមៀតមានជាតិដែក (Fe) ខ្ពស់និងមានវីតាមីនអា (Vitamin A) ទាំងក្នុងអង្ករសម្រិតនិងអង្ករសម្រូប ដែលជាទូទៅពូជស្រូវភាគច្រើនមិនមានសារធាតុទាំងនេះខ្ពស់ (ដែក) ឬគ្មានតែម្តង (វីតាមីនអា)។ តារាងនេះ មាននៅក្នុងគេហទំព័ររបស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ដើម្បីវិស័យឯកជនផ្នែកស្រូវអង្ករប្រើប្រាស់។

**តារាងទី២÷ អាហារូបត្ថម្ភមានក្នុងអង្ករសម្រិត (WR) និងអង្ករសម្រូប (BR) របស់ពូជស្រូវផ្ការំដួល (PRD) ផ្ការមៀត (PRM) សែនពិដោរ (SPD) ផ្កាច័ន្ទសែនសរ (PCSS) និងផ្ការំដេង (PRDg)**

| No | Parameter | Unit | PRD | | PRM | | SPD | | PCSS | | PRDg | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | WR | BR | WR | BR | WR | BR | WR | BR | WR | BR |
| 1 | Fe | mg/kg | | 11.2 | 12.9 | 17.7 | | 15.9 | 9.22 | 12.3 | 5.89 | 17.0 |
| 2 | Carbohydrate | g/100g | 79.1 | 75.9 | 79.5 | 75.6 | 80.9 | 76.9 | 79.9 | 78.1 | 78.8 | 75.4 |
| 3 | Dietary fiber | g/100g | 1.99 | 3.82 | 2.17 | 11.1 | 2.38 | 3.85 | 1.1 | 4.38 | 0.71 | 2.63 |
| 4 | Energy | kcal/100g | 356 | 366 | 359 | 364 | 365 | 377 | 361 | 380 | 351 | 362 |
| 5 | Protein | g/100g | 7.32 | 8.22 | 8.34 | 8.77 | 7.22 | 7.88 | 7.77 | 8.24 | 7.11 | 7.84 |
| 6 | Total fat | g/100g | 1.16 | 3.29 | 0.8 | 2.94 | 1.4 | 4.2 | 1.15 | 3.82 | 0.81 | 3.17 |
| 7 | Cholesterol | mg/100g | ND | ND | ND | ND | ND | ND | ND | ND | ND | ND |
| 8 | Polyunsat. fat | g/100g | 0.4 | 1.03 | 0.2 | 1 | 0.5 | 1.34 | 0.47 | 1.05 | 0.29 | 1.02 |
| 9 | Thiamine | ppm (mg/kg) | 0.81 | 2.39 | 1.1 | 4.7 | 0.72 | 2.5 | 0.6 | 3.2 | ND | 3.16 |
| 10 | Vitamin A | ppm (mg/kg) | ND | ND | 0.83 | 0.81 | ND | ND | ND | ND | ND | ND |
| 11 | Vitamin B2 | ppm (mg/kg) | | 2.67 | ND | ND | | 2.73 | ND | ND | ND | ND |
| 12 | Vitamin B3 | ppm (mg/kg) | | 10.2 | ND | ND | | 10.84 | 2.8 | 1.6 | 1.1 | 4.47 |
| 13 | Vitamin B6 | ppm (mg/kg) | | ND | ND | ND | | ND | ND | ND | ND | ND |
| 14 | Vitamin C | ppm (mg/kg) | | ND | ND | ND | | ND | ND | ND | ND | ND |
| 15 | Vitamin D | mcg/kg | | 36 | ND | ND | | 28 | ND | ND | ND | ND |
| 16 | Vitamin E | ppm (mg/kg) | | 5 | ND | 5.1 | | 8 | ND | ND | ND | ND |
| 17 | Vitamin K1 | ppm (mg/kg) | | ND | ND | ND | | ND | ND | ND | ND | ND |
| 18 | Vitamin B12 | mcg/kg | | ND | ND | ND | | ND | ND | ND | ND | ND |
| Date of analysis | | | WR: Aug.10 | | Aug. 11 | | WR: Aug. 10 | | Sept. 2013 | | WR: Sept. 14 | |
| | | | BR: Nov. 10 | | | | BR: Nov. 10 | | | | BR: Aug. 14 | |

ND = មិនអាចកំណត់បាន

– បានសិក្សាឃើញថា: ការច្រូតកាត់ដោយម៉ាស៊ីនកុំបៃ កាត់បន្ថយការបាត់បង់នានិងក្រោយពេលច្រូតកាត់ពីប្រមាណ១៣% មកត្រឹម៥% ថែមទាំងចំណេញពេលវេលានិងកម្លាំងពលកម្ម

– ការអភិវឌ្ឍន៍ធនធានមនុស្ស: បានបើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតដល់អ្នកបច្ចេកទេសចំនួន ៧៨១ឱកាស។ ម៉្យាងទៀត បានបណ្តុះបណ្តាលកសិករអំពីបច្ចេកទេសដាំដុះ ថែទាំ សម្រិតសម្រាំងគ្រាប់ពូជ និងក្រោយប្រមូលផលដំណាំចំនួន៥៥០ឱកាស។ បន្ថែមលើនេះ មានអ្នកចូលស្វែងរកឯកសារពីគេហទំព័រវិទ្យាស្ថាន cardi.org.kh គិតជាមធ្យមមានប្រមាណ១.១៨៩នាក់/ថ្ងៃ កើនលើសមធ្យមភាគប្រចាំឆ្នាំ២០១៣ ចំនួន២៩៣នាក់/ថ្ងៃ

– បានផ្តល់គ្រាប់ពូជស្រូវ ដំណើបស្បៃមង្គល ដែលបានបញ្ចេញនាឆ្នាំកន្លងមក ជូនគ្រប់មន្ទីរកសិកម្មទាំងអស់ រួមទាំងនាយកដ្ឋានដំណាំស្រូវ ធ្វើការពង្រីកគ្រាប់ពូជលើផ្ទៃដីយ៉ាងហោចណាស់០,៥ហិកតាក្នុងមួយខេត្ត ក្នុងឆ្នាំ២០១៤ សម្រាប់ផ្សព្វផ្សាយនិងពង្រីកបន្តដល់កសិករនាឆ្នាំ២០១៥។

## ២.៩ ការគ្រប់គ្រងសម្ភារកសិកម្ម

បច្ចុប្បន្ននេះតម្រូវការប្រើប្រាស់សម្ភារកសិកម្ម ត្រូវបានកើនឡើងជារៀងរាល់ឆ្នាំស្របតាមស្ថានភាពអភិវឌ្ឍន៍ផលិតកម្មកសិកម្មនៅក្នុងប្រទេស ដែលធ្វើឱ្យបរិមាណសម្ភារកសិកម្មនាំចូល និងបរិមាណសម្ភារកសិកម្មដែលផលិតលាយផ្សំនៅក្នុងស្រុកត្រូវបានកើនឡើង។ រាជរដ្ឋាភិបាលបានកំណត់យុទ្ធសាស្រ្តមិនយកពន្ធ ឬកំណត់អត្រាពន្ធសូន្យលើការនាំចូលសម្ភារកសិកម្ម ក្នុងគោលបំណងបង្កភាពប្រកួតប្រជែងទីផ្សារសម្ភារកសិកម្មដោយស្មើភាព ដែលអាចឱ្យកសិករទិញសម្ភារកសិកម្មប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងមានតម្លៃថោក ព្រមទាំងបានបង្កើតយន្តការអន្តរក្រសួង ដើម្បីតាមដានថ្លៃសម្ភារកសិកម្មជាប្រចាំ ក្នុងគោលបំណងរក្សាស្ថិរភាពថ្លៃសម្ភារកសិកម្ម បន្ទាប់ថ្លៃដើមផលិតកម្មកសិកម្ម និងបង្កឱកាសឱ្យកសិករអាចប្រកួតប្រជែងទីផ្សារកសិផលប្រកបដោយគុណភាព និងសុវត្ថិភាពសម្រាប់ការផ្គត់ផ្គង់ក្នុងស្រុក និងបង្កើនការនាំចេញផងដែរ។ ក្រសួងបានខិតខំពង្រឹងលើការគ្រប់គ្រងការធ្វើអាជីវកម្មសម្ភារកសិកម្មដែលបានចុះបញ្ជិកានៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងពង្រឹងមូលដ្ឋានអាជីវកម្មលក់ដុំលក់រាយសម្ភារកសិកម្មនៅតាមបណ្តាខេត្ត រាជធានីឱ្យបានសមស្របតាមនីតិវិធី។

ក្នុងឆ្នាំ២០១៤នេះ ក្រសួងបានផ្តល់លិខិតអនុញ្ញាតឱ្យនាំចូលសម្ភារកសិកម្មដល់ក្រុមហ៊ុនចំនួន១៨២ក្រុមហ៊ុនដែលមានបរិមាណដូចខាងក្រោម៖

- ថ្នាំកសិកម្មចំនួន២៧.០១៧តោន និង ៤៩៧.៧៨៨លីត្រ
- ជីកសិកម្មចំនួន ៩១២.៥៩៤តោន និង ១៩០.០០០លីត្រ
- ចំណីសត្វ ចំណីបន្ថែម ចំនួន៧២០.០៥៦តោន
- វត្ថុធាតុដើមសម្រាប់ផលិតចំណីសត្វចំនួន ៣៥៤.៥៨០តោន
- ពូជដំណាំមានចំនួន ៦.៣៩៦តោន

ចំពោះការងារផ្សព្វផ្សាយអប់រំនិងលើកកម្ពស់ការយល់ដឹងមានសកម្មភាពដូចតទៅ៖

- ផ្នែកនីតិកម្មកសិកម្មបានអនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹង ពាក់ព័ន្ធនឹងការធ្វើអាជីវកម្ម និងការប្រើប្រាស់សម្ភារកសិកម្ម នៅក្នុងខេត្តគោលដៅបានចំនួន១០ខេត្ត
- សហការអនុវត្តជាមួយមន្ទីរកសិកម្មរាជធានី ខេត្ត លើកម្មវិធីវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈដល់អាជីវករសម្ភារកសិកម្ម ដែលមានអាជីវករចូលរួមចំនួន៧៣២នាក់
- បានចែកឯកសារសៀវភៅច្បាប់ស្តីពី ការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មចំនួន១.២៥០ក្បាល សៀវភៅស្តីពីបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពី ការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មចំនួន១.០០០ក្បាល ព្រមទាំងខិតប័ណ្ណ និងបរិយាយប័ណ្ណផ្សព្វផ្សាយ ស្តីពីថ្នាំកសិកម្ម និងជីកសិកម្មសរុបចំនួន១០.០០០សន្លឹក
- បានត្រួតពិនិត្យការនាំចូលសម្ភារកសិកម្មចំនួន៣២ករណី ក្នុងនោះ បានអនុវត្តការពិន័យអន្តរការណ៍ចំនួន១១៣.០០០.០០០រៀល។

# ៣- ការបង្កើនផលិតភាពលើដំណាំកៅស៊ូ

នៅឆ្នាំ២០១៤នេះ ផ្ទៃដីកៅស៊ូសរុបមានចំនួន៣៥៧.៨០៩ហ.ត។ ផ្ទៃដីកៅស៊ូទាំងនេះ ត្រូវបានបែងចែកជា០២ផ្នែកគឺ៖ ចម្ការកៅស៊ូកសិឧស្សាហកម្ម ក្នុងនោះ អតីតចម្ការកៅស៊ូរដ្ឋនិងចម្ការកៅស៊ូវិទ្យាស្ថានកៅស៊ូកម្ពុជាមានចំនួន៥៥.៧៨៦ហ.ត ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច (ELC) មានចំនួន១៦១.៦៧៧ហ.ត និងចម្ការកៅស៊ូគ្រួសារនៅ ក្នុងខេត្តទាំង២០ មានចំនួន១៤០.៣៤៦ហ.ត។

### តារាងទី៣៖ ផលិតកម្មកៅស៊ូ២០១៣-២០១៤

| | ផលិតកម្មកៅស៊ូ | ប្រភេទចម្ការកៅស៊ូ | ឯកតា | ២០១៣ | ២០១៤ | ២០១៤/២០១៣ (Δ%) |
|---|---|---|---|---|---|---|
| 1.1 | ផ្ទៃដីដាំកៅស៊ូសរុប | កសិឧស្សាហកម្មអវិនិយោគ | ពាន់ហ.ត | 55.9 | 55.8 | 1.0 |
| | | កសិឧស្សាហកម្មវិនិយោគ (ELC) | ពាន់ហ.ត | 135.4 | 161.7 | 19.4 |
| | | កៅស៊ូគ្រួសារ | ពាន់ហ.ត | 137.4 | 140.3 | 2.1 |
| | | **សរុប** | **ពាន់ហ.ត** | **328.8** | **357.8** | **9.2** |
| 1.2 | ផ្ទៃដីចៀរជ័រ | កសិឧស្សាហកម្មអវិនិយោគ | ពាន់ហ.ត | 26.0 | 28.6 | 10.0 |
| | | កសិឧស្សាហកម្មវិនិយោគ (ELC) | ពាន់ហ.ត | 0.0 | 0.7 | - |
| | | កៅស៊ូគ្រួសារ | ពាន់ហ.ត | 52.5 | 61.3 | 16.7 |
| | | **សរុប** | **ពាន់ហ.ត** | **78.5** | **90.6** | **15.4** |
| 1.3 | ផលិតផលកៅស៊ូ | កសិឧស្សាហកម្មអវិនិយោគ | ពាន់តោន | 30.3 | 34 | 10.7 |
| | | កសិឧស្សាហកម្មវិនិយោគ (ELC) | ពាន់តោន | 0.0 | 0.05 | - |
| | | កៅស៊ូគ្រួសារ | ពាន់តោន | 55.0 | 63 | 14.7 |
| | | **សរុប** | **ពាន់តោន** | **85.3** | **97.0** | **13.4** |

ក្នុងឆ្នាំ២០១៤ ផ្ទៃដីដំណាំកៅស៊ូដាំដុះបានចំនួន៣៥៧.៨០៩ហ.ត កើនឡើងប្រមាណ៩,២% បើប្រៀបធៀបឆ្នាំ២០១៣ (៣២៨.៨០០ហ.ត)។ ផ្ទៃដីចៀរជ័របានមានចំនួន៩០.៥៤៥ហ.ត កើនឡើងប្រមាណ១៥,៤% បើធៀបនឹងឆ្នាំមុន (៧៨.៤៩៣ហ.ត)។ បរិមាណផលិតផលកៅស៊ូសម្រេចបានប្រមាណ៩៧.០៥៤តោន កើនឡើងប្រមាណ១៣,៨% បើធៀបនឹងឆ្នាំ២០១៣ (៨៥.៣០០តោន)។




*ក្រាហ្វិកទី៩៖* ផ្ទៃដីដាំដុះកៅស៊ូ

ទោះបីជាថ្លៃកៅស៊ូមានការចុះយ៉ាងខ្លាំង និងមានកត្តាអវិជ្ជមានមួយចំនួន ដែលបានជួបប្រទះកន្លងមកក៏ពិតមែនតែជារួមសមិទ្ធផលដែលសម្រេចបានទៅតាមគោលដៅដែលគ្រោងទុក។ ទាំងអស់នេះ គឺកើតឡើងដោយការខិតខំប្រឹងប្រែងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមហ៊ុន ចម្ការកៅស៊ូកសិឧស្សាហកម្ម ដៃគូអភិវឌ្ឍន៍នានា និងការចូលរួមយ៉ាងសកម្មពីកសិករកៅស៊ូគ្រួសារផងដែរ។ ទោះបីជាយ៉ាងនេះក្តី ការបង្កើនលទ្ធភាព និងសមត្ថភាពក្នុងការអភិវឌ្ឍឧស្សាហកម្មកៅស៊ូត្រូវតែយកចិត្តទុកដាក់ និងត្រូវជំរុញបន្ថែមទៀត ដើម្បីរួមចំណែកដោយជោគជ័យក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។

កៅស៊ូគឺជាដំណាំយុទ្ធសាស្ត្រមួយយ៉ាងសំខាន់ ដែលផ្តល់ផលប្រយោជន៍ជាច្រើនដល់សេដ្ឋកិច្ចសង្គមកម្ពុជា និងពិភពលោក៖ (១)បង្កើនប្រាក់ចំណូលដល់សេដ្ឋកិច្ចជាតិនិងដល់អ្នកដាំ (២)បង្កើតការងារនៅជនបទកាត់បន្ថយភាពក្រីក្រ និងទប់ស្កាត់ការធ្វើចំណាកស្រុក (៣)រួមចំណែកដល់ការពារបរិស្ថាន ដោយបង្កើតជាគម្របព្រៃឈើរក្សាលំនឹងធម្មជាតិ និងការហូរច្រោះដី (៤)តម្រូវការចាំបាច់សម្រាប់កម្មន្តសាល ផលិតទំនិញឧស្សាហកម្មរាប់ពាន់មុខ ដែលរួមមានសំបកយានយន្តគ្រប់ប្រភេទ សម្ភារកីឡា បរិក្ខារពេទ្យ ស្រោមដៃ ស្រោមអនាម័យ រហូតដល់សំណង់អគារ និងស្ពានធំៗ...។ល។

## ក. ការងារផលិតកម្មនិងនីហរណកៅស៊ូ

ឆ្នាំ២០១៤នេះ ផ្ទៃដីកៅស៊ូមិនទាន់ផ្តល់ផលដែលកំពុងថែទាំសរុបចំនួន២៦៧.២៦៤ហ.ត ក្នុងនោះ កៅស៊ូកសិឧស្សាហកម្មមានចំនួន១៨៨១៨៩ហ.ត និងកៅស៊ូគ្រួសារមានចំនួន៧៩.០៧៥ហ.ត។ ផ្ទៃដីកៅស៊ូចៀរជ័រក្នុងឆ្នាំ២០១៤ អនុវត្តបានចំនួន៩០.៥៤៥ហ.ត ក្នុងនោះកៅស៊ូគ្រួសារមានចំនួន៦១.២៧១ហ.ត បើធៀបនឹងផ្ទៃដីកៅស៊ូចៀរជ័រឆ្នាំ២០១៣ ចំនួន៧៨.៤៩៣ហ.ត គឺកើនឡើង១៥,៣៥%។ ផលិតផលកៅស៊ូឆ្នាំ២០១៤ សម្រេចបានចំនួន៩៧.០៥៤តោន ក្នុងនោះកៅស៊ូគ្រួសារសម្រេចបានចំនួន៦៣.១០០តោន បើធៀបនឹងឆ្នាំ២០១៣ ចំនួន៨៥.២៤៤តោន គឺកើនឡើងប្រមាណ១៣,៨៥%។ ទិន្នផលមធ្យមឆ្នាំ២០១៤ មានចំនួន១.០៧២គីឡូក្រាម/ហ.ត ធៀបនឹងឆ្នាំ២០១៣ដែលមានចំនួន១.០៨៦គីឡូក្រាម/ហ.ត គឺធ្លាក់ចុះ១,២៩%។ ការធ្លាក់ចុះបន្តិចបន្តួច គឺដោយសារផ្ទៃដីកៅស៊ូមួយចំនួនទើបនឹងបើកមុខចៀរថ្មី។




*ក្រាហ្វិកទី១០៖* ផលិតកម្ម និងបរិមាណកៅស៊ូនាំចេញ

ការនាំចេញកៅស៊ូឆ្នាំ២០១៤ សម្រេចបានចំនួន១០០.១៥១តោន ស្មើនឹងទឹកប្រាក់ចំនួន១៥៤.១៦០.៧៩៩ដុល្លារអាមេរិក បើធៀបនឹងឆ្នាំ២០១៣ មានចំនួន៨៦.០៥២តោន ស្មើនឹងទឹកប្រាក់ចំនួន១៨៩.៤០៨.៧៣២ដុល្លារអាមេរិក គឺផលិតផលកៅស៊ូនាំចេញកើនឡើង១៦,៣៨%។ ចំណែកទឹកប្រាក់ថយចុះប្រមាណ១៨,៦១% ការថយចុះនេះ គឺដោយសារតម្លៃកៅស៊ូនៅលើទីផ្សារអន្តរជាតិធ្លាក់ចុះ។ ឆ្នាំ២០១៤ តម្លៃកៅស៊ូគិតជាមធ្យមស្មើនឹងទឹកប្រាក់១.៥៣៩ដុល្លារអាមេរិកក្នុងមួយតោន បើធៀបនឹងឆ្នាំ២០១៣ ដែលមានតម្លៃកៅស៊ូមធ្យម២.២០១ដុល្លារអាមេរិកក្នុងមួយតោន គឺថយចុះ៦៦២ដុល្លារអាមេរិកក្នុងមួយតោនស្មើនឹង៣០%។

នៅឆ្នាំ២០១៤នេះ រោងចក្រសិប្បកម្មកែច្នៃផលិតផលកៅស៊ូសរុបមានចំនួន៩៨ ក្នុងខេត្តចំនួន៨ (កំពង់ចាម ត្បូងឃ្មុំ រតនៈគិរី កំពង់ធំ ក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី និងឧត្តរមានជ័យ) គឺកើនឡើងចំនួន៤០% បើធៀបទៅនឹងឆ្នាំ២០១៣ ដែលមានតែ៧០កន្លែង ក្នុងនោះ មានរោងចក្រកែច្នៃកៅស៊ូដុំ (TSR) ចំនួន៣៤កន្លែង រោងចក្រសិប្បកម្មកែច្នៃកៅស៊ូសន្លឹក (RSS) ចំនួន៦០កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូចំនួន៤កន្លែង។

## ខ. ការងារផ្សព្វផ្សាយនិងបណ្តុះបណ្តាល

គម្រោងថវិកាកម្មវិធីនៅក្នុងឆ្នាំ២០១៤នេះ បានចុះបើកវគ្គផ្សព្វផ្សាយបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដូចជាការជ្រើសរើសពូជ ការដាំដុះ ការថែទាំជំងឺ និងការបើកមុខចៀរដំបូងឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងបច្ចេកទេស

កែច្នៃកៅស៊ូក៏ដូចជាបើកវគ្គផ្សព្វផ្សាយពីទីផ្សារកៅស៊ូ ដល់កសិករឱ្យមានចំណេះដឹងពីកៅស៊ូ ដើម្បីទទួលបានលទ្ធផលល្អនៅថ្ងៃខាងមុខ ក្នុងខេត្តគោលដៅចំនួន១៣ គឺបាត់ដំបង ប៉ៃលិន រតនគិរី ស្ទឹងត្រែង មណ្ឌលគិរី ក្រចេះ ឧត្តរមានជ័យ ព្រះវិហារ ស្វាយរៀង ព្រៃវែង កោះកុង ត្បូងឃ្មុំ កំពង់ធំ រតនគិរី មណ្ឌលគិរី ត្បូងឃ្មុំ និងក្រចេះ មានមន្ត្រីកសិកម្មខេត្តចូលរួមសរុបចំនួន ៨៣នាក់ និងកសិករចូលរួមសរុប៧៨៣នាក់ និងបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដល់មន្ត្រីបង្គោល ដើម្បីបង្កើនសមត្ថភាពយល់ដឹងលើជំនាញដំណាំកៅស៊ូ និងប្រែក្លាយជាអ្នកផ្សព្វផ្សាយបន្តដល់អ្នកដាំកៅស៊ូ ជាពិសេសជួយដល់កសិករដាំកៅស៊ូ និងអ្នកមានបំណងដាំកៅស៊ូក្នុងខេត្តគោលដៅចំនួន០៤រួមមាន

### គ. ការងារពិសោធស្រាវជ្រាវកៅស៊ូ

បាននិងកំពុងអនុវត្តលើការស្រាវជ្រាវរួមមាន៖ (១)គ្រប់គ្រងតាមដានស្រង់និងបញ្ចូលទិន្នន័យ គ្រប់ឡូត៍ពិសោធន៍ក្លូនទាំងនៅក្នុងនិងក្រៅស្ថានីយ៍ សរុបមានចំនួន២២ឡូត៍ពិសោធន៍ និងចេញអនុសាសន៍ក្លូនឆ្នាំ២០១៤-២០១៦ (២)ការស្រាវជ្រាវលើសរីរៈវិទ្យានិងការយកផល បានបង្កើតនិងតាមដានទិន្នន័យពិសោធន៍ចំនួន១៦ពិសោធន៍ (៣)ការស្រាវជ្រាវការដាំដុះនិងការពារ ដោយបានបង្កើតប្រព័ន្ធ និងតាមដានទិន្នន័យចម្ការពិសោធន៍ចំនួន១៩ពិសោធន៍ (៤)ការបំប៉ៅកូនកៅស៊ូបានចំនួន៣១.០៣៦កូន លើពូជចំនួន៥៣ពូជនៅក្នុងស្ថានីយអនុវត្តរបស់វិទ្យាស្ថាន ការដាំដុះកូនកៅស៊ូក្លូន IRCA 317 នៅចម្ការពិសោធន៍ន៍បានចំនួន៦,២៥ហ.ត (៥)ការបង្កើតច្បារពូជថ្មីចំនួន០.៨៨ហ.ត (៦)ការដាក់ឱ្យដំណើរការមន្ទីរពិសោធន៍សរីរវិទ្យាទឹកជ័រ (៧)ការពង្រីកបណ្តាញចម្ការពិសោធន៍ពូជថ្មីចំនួន០១ នៅក្រុមហ៊ុនទ្រីភាពទន្លេប្រេចខេត្តព្រះវិហារ។

បាននិងកំពុងអនុវត្តផ្នែកមន្ទីរពិសោធន៍យថាប្រភេទរួមមាន៖ (១)ធ្វើតេស្តវិភាគសំណាកយថាប្រភេទចំនួន៣២៥ភាគសំណាក ដើម្បីបញ្ជាក់គុណភាពកែច្នៃរបស់រោងចក្រ CSR និងពិនិត្យគុណភាពកៅស៊ូប្រភេទ RSS និងគុណភាពប្រភេទ CSR CV60 (២)ការរៀបចំធ្វើតេស្ត និងរបាយការណ៍វិភាគលទ្ធផល នៃការធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុកចំនួន៤លើក ដើម្បីវាយតម្លៃសមត្ថភាពមន្ទីរពិសោធន៍មូលដ្ឋាន សម្រាប់ឈានទៅការទទួលស្គាល់ជាផ្លូវការ (៣)ធ្វើតេស្តអន្តរមន្ទីរពិសោធន៍ជាមួយ IRA បានចំនួន២លើក ដើម្បីទទួលស្គាល់ជាមន្ទីរពិសោធន៍យោងនៅក្នុងតំបន់ ចំពោះកៅស៊ូ TSR (៤)ការអនុវត្តនិងបំពេញតម្រូវការ វិញ្ញាបនបត្រទទួលស្គាល់ស្តង់ដារអន្តរជាតិ ISO/IEC17025:2005 ស្តីពីតម្រូវការទូទៅ សម្រាប់សមត្ថភាពមន្ទីរពិសោធន៍ធ្វើតេស្តនិងព្យាសកម្ម (calibration) ឧបករណ៍របស់មន្ទីរពិសោធន៍យថាប្រភេទ (៥)ការស្រាវជ្រាវលើការប្រើប្រាស់កៅស៊ូវុលកានីសេ (Vulcanization) និងផលិតផលពីកៅស៊ូធម្មជាតិ ដោយប្រើឧបករណ៍ជំនួយប្រភេទ Tensometer នៃអង្គការUNIDO។

## IV- ការជំរុញផលិតកម្មសត្វនិងសុខភាពសត្វ

សមិទ្ធផលការងារ ផ្នែកផលិតកម្មនិងបសុព្យាបាលក្នុងឆ្នាំ២០១៤ មានដូចខាងក្រោម៖

**<u>ក.ការចិញ្ចឹមសត្វគ្រប់ប្រភេទ៖</u>** (ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ និងជាលក្ខណៈពាណិជ្ជកម្ម) មានការកើនឡើងប្រមាណពី ៣៣.៩៨៧.០៤៣ក្បាល នាឆ្នាំ២០១៣ ដល់៣៧.៩៤៨.៨៧៨ក្បាលនាឆ្នាំ២០១៤ (១១,៦៦%) ក្នុងនោះ បក្សីកើន១៤,៩៦% ជ្រូកកើន១២,២៧% ប៉ុន្តែគោនិងក្របី និងកម្លាំងអូសទាញថយចុះ១១% និង៧%។

- **<u>ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ</u>** មានការកើនឡើងប្រមាណពី ២៧,៥១ លានក្បាល នាឆ្នាំ២០១៣ ដល់ ៣១,៦១លានក្បាលនាឆ្នាំ២០១៤ (កើន១៤,៦៧%) ក្នុងនោះបក្សីកើន ១៩,៦០% ជ្រូកកើន១៤,១៦% ប៉ុន្តែគោនិងក្របី និងកម្លាំងអូសទាញថយចុះ១១,១២% និង៧%។
- **<u>ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម</u>** ក៏មានការកើនឡើងគួរកត់សម្គាល់ ទាំងចំនួនកសិដ្ឋាន និងចំនួនសត្វ។ ឆ្នាំ២០១៤ កសិដ្ឋានចិញ្ចឹមសត្វសរុបមានចំនួន២.៣៥៩កន្លែង កើន១៤០,៧១% និងចំនួនសត្វសរុបកើនពី៥.៨៣៩.៥៤៥ក្បាល នាឆ្នាំ២០១៣ ដល់៦.៣៣៥.០០០ក្បាល(៨,៤៨%) នាឆ្នាំ២០១៤ ក្នុងនោះគោកើន១៨,៨៨% ជ្រូកកើន៤,៧២% និងបក្សីកើន៨,៧២%។

ជាការកត់សម្គាល់ ការចិញ្ចឹមសត្វបង្កើតបានកាកសំណល់ដូចជាលាមករឹង លាមករាវ ទឹកកាកសំណល់ ឧស្ម័នមេតាន។ល។ ដែលធ្វើឱ្យប៉ះពាល់បរិស្ថាន។ ដើម្បីកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាននេះ ក្រសួងបានជំរុញឱ្យមានការ

សាងសង់ឡជីវឧស្ម័នខ្នាតតូច (ឡជីវឧស្ម័នគ្រួសារ) និងរោងប្រព្រឹត្តកម្មជីវឧស្ម័នខ្នាតធំ (រោងប្រព្រឹត្តកម្មជីវឧស្ម័នបែបពាណិជ្ជកម្ម) នៅតាមបណ្តាកសិដ្ឋានចិញ្ចឹមសត្វធំៗ។ លទ្ធផលស្តីពីការគ្រប់គ្រងកាកសំណល់សត្វនាឆ្នាំ២០១៤ មានដូចខាងក្រោម៖

ការសាងសង់ឡជីវឧស្ម័នជាលក្ខណៈគ្រួសារបានចំនួន១.៣៣៦ឡ ក្នុងនោះមាន៖

- ឡជីវឧស្ម័នថ្នាក់ជាតិចំនួន១.២១៦ឡ ដែលសាងសង់នៅក្នុងខេត្តចំនួន១០ រួមមានខេត្ត ស្វាយរៀង ព្រៃវែង តាកែវ កំពង់ស្ពឺ កណ្តាល កំពង់ឆ្នាំង កំពត សៀមរាប កំពង់ធំ និងពោធិ៍សាត់
- ឡជីវឧស្ម័នដែលជាជំនួយឧបត្ថម្ភដោយសាធារណៈរដ្ឋប្រជាមានិតចិនមានចំនួន១២០ឡ ក្នុងនោះ នៅខេត្តកណ្តាល៤៥ឡ និងតាកែវ ៧៥ឡ។

ជាមួយគ្នានេះដែរ ក្រសួងបាននិងងកំពុងជំរុញការកែលម្អពូជសត្វ ដែលជាពូជសត្វផ្តល់ផលិតភាពនិងប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ព្រមទាំងធន់ទ្រាំនឹងបរិស្ថាននៅកម្ពុជា។ ការកែលម្អពូជប្រព្រឹត្តទៅទាំងការជ្រើសរើសមេបាល្អៗយកមកបង្កាត់ តាមរយៈការបង្កាត់ដោយសិប្បនិម្មិត ការនាំចូលទឹកមេជីវិតនិងពូជសត្វល្អៗពីបរទេស។ លើសពីនេះក្រសួងក៏កំពុងធ្វើការស្រាវជ្រាវនិងបង្កាត់ពូជគោ ជ្រូក ដូចជាពូជគោប្រាមាន់ កំផែងសែន និងនាំចូលទឹកមេជីវិតពូជគោសាន់តា និងស៊ីមប្រា។ ចំពោះជ្រូក ក្រសួងបាននិងកំពុងផ្សព្វផ្សាយពូជយ៉កសៀ ឡែនជ្រេស និងឌុយរ៉ុក ហើយក៏បាននិងកំពុងដំណើរការនិងអនុវត្តការបង្កាត់សិប្បនិម្មិតជ្រូកនិងគោ នៅតាមខេត្តមួយចំនួនទៀតដូចជា តាកែវ កំពង់ស្ពឺ និងពោធិ៍សាត់។ ផ្នែកឯកជនបានចូលរួមយ៉ាងសកម្មក្នុងការបង្កាត់ និងផ្សព្វផ្សាយពូជសត្វដែលទទួលបានលទ្ធផលគួរកត់សម្គាល់។ ការដាំដំណាំចំណីសត្វនៅបន្តអនុវត្តតាមបណ្តាខេត្តមួយចំនួនដូចជា ខេត្តកំពង់ចាម ត្បូងឃ្មុំ ពោធិ៍សាត់ បាត់ដំបង រតនគិរី កណ្តាល តាកែវ ព្រៃវែង កំពង់ឆ្នាំង។ល។

មានរោងចក្រផលិតចំណីសត្វចំនួន៧កន្លែង ដែលបាននឹងកំពុងដំណើរការផលិត និងលក់ចែកចាយចំណីផ្សំស្រេចសម្រាប់ជ្រូក មាន់ ទា និងត្រី។ រោងចក្រផលិតចំណីសត្វទាំងនោះរួមមានៈ ស៊ីភីខេមបូឌា អាហ្គ្រីម៉ាស៊្វរ ហ្វ្រីនហ្វីត វេលជ័រវេត អេសជីអែស ញូហូប ដីហ្វែរ និងរោងចក្រផលិតចំណីសត្វតាមបណ្តាកសិដ្ឋានចិញ្ចឹមសត្វធំៗមួយចំនួនទៀត។

ឆ្នាំ២០១៤ ផ្នែកផលិតកម្មនិងបសុព្យាបាល បានចុះត្រួតពិនិត្យយកវត្ថុវិភាគ និងធ្វើការវិភាគគុណភាព សុវត្ថិភាពចំណីសត្វ ដើម្បីអនុញ្ញាតឱ្យចុះបញ្ជីការចំណីសត្វទាំងនោះ បានធ្វើការត្រួតពិនិត្យនិងវាយតម្លៃចំណីសត្វនៅក្រុមហ៊ុនចំនួន១៧ដែលរួមមានៈ លីហុងសេង អេគ្រីខលឈ័រឌីវេឡុបមេន វីផារ៉េត រាជសីហ៍ អេសខេខូអិលធីឌី ហ្វ្រីនហ្វីត (ខេមបូឌា) វេលជ័រវេត ហុកហៀងត្រេនស្តត គាតខេងឌីវេឡុ សាន់ហ្វីត (ខេបូឌា) ផលហេង (ខេមបូឌា) បេយើថៃ (ខេបូឌា) សានណាហ្គ្រោខបធើរហ្សិនខូអិលធីឌី បាយអូមីនខេមបូឌាខូអិលធីឌី ជីភីមរកត បេសហ្វីតខូអិលធីឌី ស៊ីភី (ខេបូឌា)។

**ខ.ការងារបសុព្យាបាល៖** ជាផ្នែកមួយដ៏សំខាន់ និងមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយការងារផលិតកម្មសត្វ ក្នុងការជំរុញឱ្យការចិញ្ចឹមសត្វមានជីវសុវត្ថិភាពកាន់តែប្រសើរឡើង និងចូលរួមក្នុងការបង្ការ ការពារ ការត្រួតពិនិត្យ និងការទប់ស្កាត់ជំងឺឆ្លងសត្វ និងជំងឺឆ្លងពីសត្វទៅមនុស្ស ព្រមទាំងកាត់បន្ថយអត្រាសត្វឈឺ និងស្លាប់តាមរយៈការចាក់ថ្នាំការពារ និងព្យាបាល ការត្រួតពិនិត្យចលនាសត្វ និងផលិតផលមានដើមកំណើតពីសត្វ ការអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនានា ឱ្យបានទាន់ពេលវេលានិងមានប្រសិទ្ធភាព។

ជំងឺឆ្លងរាលដាលសត្វដែលផ្ទុះឡើងក្នុងឆ្នាំ២០១៤ គឺជំងឺអុតក្តាម សារទឹក បូសខ្យល់ និងជំងឺផ្តាសាយបក្សី។ ជំងឺទាំងនេះបណ្តាលឱ្យមានគោក្របីឈឺចំនួន៧០.២៧០ក្បាល (១,៩៥%) និងស្លាប់ចំនួន១.៦០២ក្បាល (0.0៤%) ជ្រូកឈឺចំនួន១១២.២០៧ក្បាល (៤,៧៥%) និងស្លាប់ចំនួន៦.៩៩៦ក្បាល (៣,៧២%) និងបក្សីឈឺចំនួន៦៧.៩៩៧ក្បាល (0,២៦%) និងស្លាប់ចំនួន៣១.៤២៤ក្បាល (0,១២%)។ តាមទិន្នន័យនេះ ស្ថានភាពជំងឺមិនសូវមានការរាលដាលខ្ពស់ដែលបណ្តាលឱ្យប៉ះពាល់ដល់ផលិតកម្មសត្វធ្ងន់ធ្ងរឡើយ។ លទ្ធផលជាវិជ្ជមាននេះ ដោយសារក្រសួងបានអនុវត្តនូវវិធានការទប់ស្កាត់ការពារជំងឺ ក្នុងនោះមានកម្មវិធីចាក់ថ្នាំការពារ វិធានជីវសុវត្ថិភាព ការត្រួតពិនិត្យអនាម័យសត្វនៅកន្លែងចិញ្ចឹម និងការត្រួតពិនិត្យចលនាសត្វ ផលិតផលមានដើមកំណើតពីសត្វ និងមានការអនុវត្តល្អប្រសើរការចិញ្ចឹមសត្វរបស់ប្រជាពលរដ្ឋ និងកសិដ្ឋានចិញ្ចឹមសត្វ ដោយមានការចូលរួមអនុវត្តពីសំណាក់ភ្នាក់ងារសុខភាព សត្វភូមិ និងប្រជាពលរដ្ឋអ្នកចិញ្ចឹមសត្វ។

ជំងឺអុតក្តាមបានផ្ទុះឡើងចំនួន២០៨កន្លែងនៅក្នុង១៧ខេត្ត ជំងឺសារទឹកបានផ្ទុះឡើងចំនួន១៦កន្លែង ដោយឡែកជំងឺបូសខ្យល់បានផ្ទុះឡើងចំនួន១៣កន្លែង នៅក្នុងខេត្តចំនួន២ គឺខេត្តសៀមរាប និងប៉ៃលិន។ ករណីផ្ទុះជំងឺផ្តាសាយបក្សីកើតមានចំនួន០៥កន្លែង ខេត្តកំពង់ចាម កំពង់ស្ពឺ កណ្តាល និងកំពត។ ក្រៅពីជំងឺឆ្លងសត្វដូចបានរៀបរាប់ខាងលើ នៅមានជំងឺឆ្លងសត្វមួយចំនួនទៀត រួមមានៈ ជំងឺប៉េស្ត កញ្ច្រឹល សារទឹក អូហេស្ស៊ី ត្រចៀកខៀវជ្រូក (PRRS) ញ៉ូវកាស អុតអាសន្នរោគ ប៉េស្តទា រលាកថ្លើមបក្សី និងជំងឺបង្កដោយបរាសិត។

ឆ្នាំ២០១៤ ចំនួនគោ ក្របី ដែលបានចាក់វ៉ាក់សាំងសារទឹកមាន ២៩,៣៧% អុតក្តាម១,០៨% និងបូសខ្យល់០,១៩%។ ការចាក់វ៉ាក់សាំងគោ ក្របី នេះត្រូវបានឧបត្ថម្ភគាំទ្រដោយរាជរដ្ឋាភិបាល ដោយឡែកការចាក់វ៉ាក់សាំង ជ្រូក និងបក្សី ជាបន្ទុករបស់ម្ចាស់សត្វ។

ក្រសួងបានចាត់មន្ត្រីជំនាញចុះអនុវត្តវិធានជីវសុវត្ថិភាព និងអនាម័យបាញ់ថ្នាំសម្លាប់មេរោគ នៅតាមកសិដ្ឋានចិញ្ចឹមសត្វ កន្លែងចិញ្ចឹមសត្វ ទីផ្សារ ផ្ទះប្រជាជនដែលចិញ្ចឹមសត្វ កន្លែងចិញ្ចឹមទាហ្វូង សត្តឃាតដ្ឋាន កន្លែងផ្ទុះជំងឺ កន្លែងស្តុកសត្វ និងលើមធ្យោបាយដឹកជញ្ជូនបានចំនួន៨.០០៥លើក ។

ការនាំចូល ការនាំចេញ និងការដឹកជញ្ជូនឆ្លងកាត់សត្វនិងផលិតផលសត្វ មានសកម្មភាពកើនឡើងនាឆ្នាំ ២០១៤។ ការនាំចូលសំខាន់ៗរួមមានជ្រូកពូជ ជ្រូកសាច់រស់ កូនមាន់ពូជ មាន់រស់ សម្រាប់យកសាច់ និងសាច់មាន់ ព្រមទាំងសាច់គោ ចៀម និងផលិតផលសត្វ ដែលមានគុណភាពខ្ពស់។ ទន្ទឹមនឹងនោះ សកម្មភាពនាំចេញសត្វ និងផលិតផលសត្វក៏ប្រព្រឹត្តទៅក្នុងបរិមាណគួរឱ្យកត់សម្គាល់ដែរ ដូចជាការនាំចេញគោ-ក្របីរស់ ជ្រូកពូជ ស្បែកគោ-ក្របីប្រឡាក់អំបិល ចំណីឆ្កែ ស្វាសម្រាប់ធ្វើពិសោធន៍ រោមសត្វ។ល។ ព្រមទាំងមានការនាំឆ្លងកាត់គោរស់ពីប្រទេសថៃឡង់ដ៍ទៅប្រទេសវៀតណាម។ អង្គភាពផលិតកម្ម និងបសុព្យាបាលបានចុះត្រួតពិនិត្យ យកវត្ថុវិភាគ ធ្វើវិភាគ និងចេញវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ ព្រមទាំងផ្តល់សេវាកម្មផ្សេងៗ ដើម្បីធ្វើការនាំចេញសត្វ និងផលិតផលសត្វ។ ជាមួយគ្នានោះដែរក៏បានធ្វើការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វយ៉ាងម៉ត់ចត់មុនអនុញ្ញាតឱ្យនាំចូល នាំចេញ និងនាំឆ្លងកាត់។

ផ្អែកលើវិធានបច្ចេកទេស និងវិធានច្បាប់ ក្រសួងបានចាត់អង្គភាពផលិតកម្មនិងបសុព្យាបាល ចុះទប់ស្កាត់ និងបង្ក្រាបបទល្មើស ៖

ក្រុមមន្ត្រីជំនាញចល័តផ្នែកផលិតកម្មនិងបសុព្យាបាលនិងក្រុមមន្ត្រីជំនាញរាជធានី ខេត្ត បានត្រួតពិនិត្យចលនាសត្វ និងផលិតផលមានដើមកំណើតពីសត្វបានចំនួន២៩១ករណី ក្នុងនោះ មានគោក្របី៧៣ករណី ជ្រូក១៤៥ករណី ស៊ុត ២៩ករណី បក្សី២៦ករណី ស្បែកគោធ្វើចំណីឆ្កែ១ករណី និងមានគោក្របីចំនួន៥៩ក្បាល បក្សីចំនួន១៤.៣០០ក្បាល ផលិតផលខូចគុណភាពចំនួន២៧០គ.ក្រ និងបានដុតបំផ្លាញចំនួន២ករណី។ ក្នុងការត្រួតពិនិត្យបានរកឃើញករណីបទល្មើសចំនួន២១ករណី និងបានធ្វើការផាកពិន័យជាទឹកប្រាក់ចំនួន១២៤.៦២០.០០០រៀល។

ក្នុងឆ្នាំ២០១៤ មានភ្នាក់ងារសុខភាពសត្វភូមិចំនួន១២.៣៨៦នាក់ ថយចុះ២,២៦% បើធៀបឆ្នាំមុនភ្នាក់ងារសុខភាពសត្វភូមិចំនួន១២.៦៧៣នាក់ ដោយសារការផ្លាស់ប្តូរមុខរបរ។

**គ.ការងារសុខនាពសាធារណៈ** ជាផ្នែកមួយដ៏សំខាន់នៃអនុវិស័យផលិតកម្មនិងបសុព្យាបាល បានរួមចំណែកក្នុងការទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វ លើកកម្ពស់សុខភាពសត្វ សុខភាពសាធារណៈ និងធានាគុណភាពសាច់ និងផលិតផលសត្វ តាមរយៈការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ នៅសត្តឃាតដ្ឋាន និងកន្លែងតាំងលក់។ រហូតមកទល់ពេលនេះ មានសត្តឃាតដ្ឋានដែលទទួលបានលិខិតអនុញ្ញាតពីអង្គភាពផលិតកម្ម និងបសុព្យាបាលចំនួន១៣៦កន្លែង ក្នុងនោះ ប្រភេទ "ក" មាន៦កន្លែង និងប្រភេទ "ខ" ចំនួន១៣០កន្លែង។ សត្វពិឃាតទូទាំងប្រទេស ដែលត្រូវបានរាយការណ៍ជាផ្លូវការនាឆ្នាំ២០១៤ រួមមាន គោ១០៤.១៣២ក្បាល ក្របី៣.៤៨៣ក្បាល ជ្រូក៨១១.៨៤១ក្បាល មាន់៩៣០.០៦០ក្បាល។ ចំពោះបក្សី (មាន់-ទា) ជាទូទៅធ្វើការពិឃាតនៅតាមផ្ទះ និងនៅតាមទីផ្សារ ដែលជំនាញអង្គភាពផលិតកម្មនិងបសុព្យាបាលមិនទាន់អាចចុះត្រួតពិនិត្យអនាម័យបាននៅឡើយ លើកលែងតែសត្តឃាតដ្ឋានបក្សីចំនួន២កន្លែង ដែលមានលិខិតអនុញ្ញាត។

មន្ត្រីជំនាញបសុព្យាបាលមានសមត្ថកិច្ចចំនួនជាង២០០នាក់ បានចុះធ្វើការត្រួតពិនិត្យជាប្រចាំ នូវអនាម័យសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និងផលិតផលសត្វ នៅតាមសត្តឃាតដ្ឋានដែលមានលិខិតអនុញ្ញាត ព្រមទាំងធ្វើការ

ត្រួតពិនិត្យអនាម័យសាច់ និងផលិតផលសត្វ នៅតាមកន្លែងតាំងលក់ដែលអាចធានាគុណភាព សុវត្ថិភាពសាច់ដល់អ្នកបរិភោគ។ ក្រសួងបានធ្វើការអប់រំ ផ្សព្វផ្សាយអនុក្រឹត្យលេខ១០៨អនក្រ.បក ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ និងប្រកាសពាក់ព័ន្ធជាច្រើនលើក នៅតាមបណ្តារាជធានីខេត្តមួយចំនួនដូចជាខេត្តសៀមរាប កំពង់ធំ ពោធិសាត់ និងកំពង់ស្ពឺ ក្នុងគោលបំណងពង្រឹងការអនុវត្តអនុក្រឹត្យលេខ១០៨ អនក្រ.បក ប្រកបដោយប្រសិទ្ធភាព។ បន្ថែមលើសពីនេះទៀតបានចុះត្រួតពិនិត្យទីតាំងសាងសង់សត្តឃាតដ្ឋាន តាមការស្នើសុំរបស់ការិយាល័យផលិតកម្មនិងបសុព្យាបាលរាជធានី ខេត្តចំនួន៤៥កន្លែង។

**ឃ.ការងារស្រាវជ្រាវបសុព្យាបាលនិងផលិតកម្មសត្វ៖** វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលបានទទួល និងធ្វើវិភាគសំណាកចំនួន៦.៦១០វិភាគ (ឆ្នាំ២០១៣ ចំនួន១០.៩៥០វិភាគ) ក្នុងនោះ បានវិភាគរកមេរោគ នៅក្នុងផ្នែកប៉ារ៉ាស៊ីតសាស្រ្តបានចំនួន១.២៩១វត្ថុវិភាគ ផ្នែកបាក់តេរីសាស្រ្តបានចំនួន១.៦៥៨វត្ថុវិភាគ ផ្នែកលោហិតសាស្រ្តបានចំនួន១.២៨៧វត្ថុវិភាគ ផ្នែកសេរ៉ូមសាស្រ្ត/វីរុសសាស្រ្តបានចំនួន២.២៥១វត្ថុវិភាគ និងផ្នែកសរីរៈរោគសាស្រ្តបានចំនួន១២៣វត្ថុវិភាគ។ ផ្នែកអេពីដេមីសាស្រ្ត បានចុះប្រមូលព័ត៌មាន និងអង្កេតតាមដានស្រាវជ្រាវជំងឺឆ្លងសត្វមានជាអាទិ៍ ជំងឺអុតក្តាម សារទឹក ប៉េស្តជ្រូក ផ្តាសាយបក្សី និងជំងឺមួយចំនួនទៀត នៅតាមបណ្តារាជធានី ខេត្ត ទូទាំងប្រទេស។

វិទ្យាស្ថានមានប្រព័ន្ធព័ត៌មានទាន់ហេតុការណ៍សម្រាប់ទទួលព័ត៌មានពីម្ចាស់សត្វ និងអ្នកពាក់ព័ន្ធ។ វិទ្យាស្ថានបានរៀបចំប្រូតូកូលអំពីការអង្កេតស្រាវជ្រាវជំងឺផ្តាសាយបក្សី។ បន្ថែមលើសពីនេះ បានធ្វើការតាមដានឃ្លាំមើលជំងឺផ្តាសាយបក្សីប្រភេទ A/H5N1 និង A/H7N9 នៅទីផ្សារក្នុងរាជធានីភ្នំពេញ ព្រៃវែង តាកែវ កំពង់ចាម កំពត និងសៀមរាប។ ក្រៅពីនេះក៏បានធ្វើការបណ្តុះបណ្តាលមន្ត្រីផលិតកម្មនិងបសុព្យាបាលស្រុកនិងខេត្ត អំពីការអង្កេតស្រាវជ្រាវករណីផ្ទុះជំងឺអុតក្តាមនៅក្នុងខេត្ត កំពង់ចាម ព្រៃវែង និងតាកែវ។ វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល បានបញ្ជូនមន្ត្រីជំនាញទៅចូលវគ្គបណ្តុះបណ្តាលរយៈពេលវែង-ខ្លី ចូលរួមប្រជុំ និងសិក្ខាសាលានានាក្នុងប្រទេសចំនួន៨០លើក និងក្រៅប្រទេសចំនួន៣១លើក។

វិទ្យាស្ថានស្រាវជ្រាវផលិតកម្មសត្វមានស្ថានីយចិញ្ចឹមជ្រូកពូជបង្ហាញកម្ពុជា-ចិន ផលិតបានកូនជ្រូកពូជចំនួន៩១៥ក្បាល ក្នុងនោះញី៤២០ក្បាល ដែលបានលក់ចែកចាយជូនប្រជាពលរដ្ឋសម្រាប់ធ្វើពូជ នៅតាមបណ្តារាជធានី-ខេត្ត។ ជ្រូក ពូជដែលលក់ចែកជូនប្រជាពលរដ្ឋ ជាតម្លៃគោលនយោបាយរដ្ឋ។

វិទ្យាស្ថានបាននិងកំពុងរៀបចំជំរុញការចិញ្ចឹមថែទាំពូជគោ ការបង្កាត់ពូជ ដោយសិប្បនិម្មិត កែលម្អពូជគោ និងការដាំដំណាំចំណីសត្វ ជាពិសេសការរៀបចំកែច្នៃចំណីគោត្រៀមសម្រាប់ការចិញ្ចឹមគោពូជក្នុងស្ថានីយ។ ស្ថានីយមិនគ្រាន់តែជាកន្លែងចិញ្ចឹមគោពូជប៉ុណ្ណោះទេ ថែមទាំងជាកន្លែងដាំផ្សព្វផ្សាយ និងចែកចាយដំណាំចំណីសត្វ ដូចជាពូជស្មៅយីងក្រាស ហ្គីណេ ម៉ារ៉ាន់ឌូ មុលឡាតូ ប៉ាស្តាឡូម និងស៊ីម្ពួង ដល់បណ្តារាជធានី-ខេត្ត។

**ង.ការងារផ្សព្វផ្សាយបច្ចេកទេសផលិតកម្ម និងបសុព្យាបាល៖** ការងារផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាលគឺជាមធ្យោបាយសម្រាប់ផ្ទេរចំណេះដឹងថ្មីតាមបែបវិទ្យាសាស្រ្តលើការងារចិញ្ចឹមសត្វ និងជាចលករដ៏សំខាន់ក្នុងការធ្វើឱ្យមានការផ្លាស់ប្តូរផ្នត់គំនិតនិងឥរិយាបទរបស់កសិករក្នុងការចិញ្ចឹមសត្វតាមបែបយថាផល និងទំនៀមទំលាប់ប្រពៃណីសម្រាប់តែតម្រូវការហូបចុកក្នុងគ្រួសារ ឱ្យទៅជាការចិញ្ចឹមសត្វតាមបែបបច្ចេកទេសសម្រាប់ធ្វើពាណិជ្ជកម្ម។ ដើម្បីសម្រេចគោលបំណងខាងលើនេះ មន្ត្រីទទួលបន្ទុកផ្ទាល់ ក៏ដូចអ្នកពាក់ពន្ធ័បានអនុវត្តនូវវិធីសាស្រ្ត និងមធ្យោបាយសមស្រប ដើម្បីឱ្យការផ្សព្វផ្សាយមានប្រសិទ្ធភាពដូចជា៖ ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ វេទិកាផ្សព្វផ្សាយ ទស្សនាវដ្តី ធ្វើបទសម្ភាសន៍ ការប្រជុំ និងការតាំងពិព័ណ៌។ល។ ប្រធានបទដែលយកមកផ្សព្វផ្សាយមានដូចជាជំងឺឆ្លងសត្វ អត្ថប្រយោជន៏នៃការចាក់ថ្នាំការពារជំងឺឆ្លងសត្វ ជំងឺផ្តាសាយបក្សី បច្ចេកទេសចិញ្ចឹមសត្វ ពូជនិងការជ្រើសរើសពូជ បច្ចេកទេសបង្កាត់ពូជសិប្បនិម្មិត បច្ចេកទេសដាំដំណាំចំណីសត្វ បច្ចេកទេសកែច្នៃចំណីសត្វ និងលិខិតបទដ្ឋានគតិយុត្ត។

ក្នុងឆ្នាំ២០១៤នេះ ការផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វ ការបង្ការ ការទប់ស្កាត់ និងការការពារជំងឺគោក្របីបានរៀបចំធ្វើដោយថ្នាក់កណ្តាលបានចំនួន១៨ដង មានអ្នកចូលរួមសរុប១.០២៤នាក់។ បន្ថែមលើសពីនេះទៀត ការផ្សព្វផ្សាយបច្ចេកទេសបង្ការទប់ស្កាត់ ការពារជំងឺផ្តាសាយបក្សីនិងមនុស្ស បានរៀបចំអនុវត្ត ដល់មន្ត្រីផលិតកម្មនិងបសុព្យាបាលភ្នាក់ងារសុខភាពសត្វភូមិ អ្នកចិញ្ចឹមមាន់ ទា អាជីវករទិញលក់បក្សី បានចំនួន១.៣៥៩នាក់។

ការផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វ បង្ការ ទប់ស្កាត់ និងការពារជំងឺ ដល់ភ្នាក់ងារសុខភាពសត្វ អ្នកចិញ្ចឹមសត្វ អាជីវករទិញលក់សត្វ។ល។ បានរៀបចំអនុវត្តដោយថ្នាក់ខេត្តបានចំនួន៨៥៤លើក ដែលមានអ្នកចូលរួមចំនួន៣៦.៩៤៨នាក់ ក្នុងនោះ មានស្រី៧.៩៩២នាក់ ។

សៀវភៅបច្ចេកទេសចំនួន៥ប្រភេទ៖ (១)ជំងឺអុតក្តាម (២)សារទឹក (៣)បច្ចេកទេសចិញ្ចឹមគោ-ក្របី (៤)ជំងឺផ្តាសាយបក្សី (៥)ជីវសុវត្ថិភាពក្នុងការចិញ្ចឹមបក្សី ចំនួន៦.០៥០ក្បាល ត្រូវបានបោះពុម្ពនិងចែកចាយ។ បន្ថែមលើសពីនេះ ខិតបណ្ណជំងឺឆ្លងគោ-ក្របី ផ្ទាំងរូបភាពផ្សព្វផ្សាយជំងឺឆ្លងគោ-ក្របី ប្រតិទិន្នចាក់ថ្នាំការពារ បដាផ្សព្វផ្សាយការចាក់ថ្នាំការពារ ចំនួន១៥៤.៨៥៦ច្បាប់ អាវយឺតស្តីពីអត្ថប្រយោជន៍នៃការចាក់ថ្នាំការពារជំងឺឆ្លងសត្វចំនួន៣.២៦០អាវ ត្រូវបានបោះពុម្ព និងចែកចាយ។ អត្ថបទបច្ចេកទេសសមិទ្ធផលស្តីពីវិស័យផលិកម្មសត្វ និងបសុព្យាបាល សម្រាប់ចុះក្នុងទស្សនាវដ្តី ផលិតវីឌីអូឃុតខ្លីដែលមានប្រធានបទស្តីពី "យើងរួមគ្នាការពារ និងទប់ស្កាត់ជំងឺផ្តាសាយបក្សីសម្រាប់ស្ព័តផ្សាយតាមទូរទស្សន៍" និងឌីសចំនួន១០០ ត្រូវបានផលិតនិងផ្សព្វផ្សាយ។

***ច.ការងារប្រមូលចំណូលពីផ្នែកផលិតកម្មនិងបសុព្យាបាល៖***

ផ្នែកផលិតកម្មនិងបសុព្យាបាល ប្រមូលចំណូលចូលថវិកាជាតិនាឆ្នាំ២០១៤ បានចំនួន៥.៣១៤.១១២.០៩១រៀល កើនឡើង១០,៥៤% បើធៀបនឹងឆ្នាំ២០១៣ ក្នុងនោះការប្រមូលចំណូលដោយនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល មានចំនួន៣.៧៨៣.៤៧៨.៩៩៧រៀល កើនឡើង៣៤,៩៦% ប៉ុន្តែការប្រមូលចំណូលរបស់ផលិតកម្មនិងបសុព្យាបាលរាជធានីខេត្តបានតែ ១.៥៣០.៦៣៣.០៩៤រៀល ថយចុះចំនួន២៣,៦៥%។

## V- ការអនុវត្តគោលនយោបាយកំណែទម្រង់វិស័យជលផល

ផ្នែកជលផលបានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការអនុវត្តតាមគោលនយោបាយកែទម្រង់ស៊ីជម្រៅវិស័យជលផលដំណាក់កាលទី២ ដោយទួលបានសមិទ្ធផលដូចខាងក្រោម៖

***ក. ការអភិវឌ្ឍន៍សហគមន៍នេសាទ***

ការអភិវឌ្ឍន៍សហគមន៍នេសាទសម្រេចបានចំនួន៥១៦ ក្នុងនោះសហគមន៍នេសាទទឹកសាបចំនួន៤៧៧ និងសហគមន៍នេសាទសមុទ្រចំនួន៣៩ ដែលមានសមាជិកសរុបចំនួន៣៣២.១៦៨នាក់ (ស្ត្រីប្រមាណ៣៥%) ត្រូវជា១៤៧.៥១៨គ្រួសារ។ ក្នុងចំណោមសហគមន៍ មានសហគមន៍នេសាទចំនួន៣៧០ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរួចហើយ សហគមន៍នេសាទចំនួន១៤ បានរៀបចំសំណុំឯកសារស្នើសុំចុះបញ្ជីបន្ថែមទៀត និងសហគមន៍នេសាទចំនួន២៣ កំពុងដំណើរការចុះហត្ថលេខានៅថ្នាក់ក្រោមជាតិ។

***ខ. ការអភិរក្សធនធានជលផល***

ក្រោយការកែទម្រង់ស៊ីជម្រៅផ្នែកជលផល ដោយរំសាយឡូត៍នេសាទទាំងអស់នៅទូទាំងប្រទេស មានកន្លែងអភិរក្សជលផលថ្មីចំនួន៥០កន្លែង សរុបទូទាំងប្រទេសមានចំនួន៤៩១កន្លែង (សហគមន៍៣៦៤កន្លែង)។ ក្នុងឆ្នាំ២០១៤ បានបោះបង្គោលបេតុងបានចំនួន៤១ដើម និងសាងសង់ស្នាក់ការបណ្តែតទឹកនិងស្នាក់ការបេតុងបានចំនួន១០ ព្រមទាំងបានដាក់កំលាំងយាមល្បាតជាប្រចាំ។ សកម្មភាពអភិរក្សជលផលផ្សេងៗទៀតមានដូចខាងក្រោម៖

- អភិរក្សផ្កាថ្ម ស្មៅសមុទ្រចំនួន៤.០០០ហ.ត នៅតាមតំបន់ឆ្នេរ
- ដាំព្រៃលិចទឹកនិងព្រៃកោងកាងបានចំនួន១០០ហ.ត និងបោះបង្គោលព្រំប្រទល់អភិរក្សព្រៃកោងកាង បានចំនួន២១បង្គោល
- រៀបចំអន្លង់ត្រីមេពូជបានចំនួន១៨កន្លែង នៅតំបន់មេគង្គលើ
- បាននិងកំពុងអភិរក្សផ្សោតមេគង្គ ក្រពើត្រី សេះសមុទ្រ កន្ធាយក្បាលកង្កែប អណ្តើកសរសៃ ត្រីនាគ ដែលធ្វើឱ្យផលស្តុកកើនឡើង
- បានសាងសង់ប៉មត្រួតពិនិត្យការពារភ្លើងឆេះព្រៃចំនួន០១

- បានរៀបចំទិវាមច្ឆជាតិ ០១ កក្កដា នៅអាងទឹកកុល ភូមិក្រាំងកន្ត្រោល ឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
- បានលែងកូនត្រីនិងកូនបង្កងចំនួន៥.០០០.០០០ក្បាល ទៅក្នុងបឹងធម្មជាតិ។

**គ. ការបង្ក្រាបបទល្មើសជលផល**

ដោយមានបទបញ្ជា០១បប និងច្បាប់ជលផលជាបង្អែក មន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់បានសហការជាមួយអាជ្ញាធរដែនដី និងសមត្ថកិច្ចពាក់ព័ន្ធខិតខំបំពេញការងារយ៉ាងសកម្ម ជាពិសេសបានយកចិត្តទុកដាក់ការពារកន្លែងអភិរក្សជលផលមិនឱ្យមានការលួចចូលធ្វើនេសាទអាណាធិបតេយ្យឡើយ។ ប៉ុន្តែទោះជាខិតខំយ៉ាងណាក៏ដោយ ជាមួយដែននេសាទដ៏ធំធេងនោះ ក៏មិនទាន់អាចទប់ស្កាត់នូវបទល្មើសនេសាទបាន១០០%នៅឡើយ។

ឯលទ្ធផលជាក់ស្តែង គឺបង្ក្រាបបទល្មើសបានចំនួន៣.៦៨៦ករណី ប្រៀបធៀបឆ្នាំមុនថយចុះចំនួន១៨០ករណី ក្នុងនោះបានបំផ្លាញចោលវត្ថុតាងចំនួន៣.១៦០ករណី ពិន័យអន្តរការណ៍ចំនួន៤០៨ករណី បញ្ជូនទៅតុលាការចំនួន១១៨ករណី ដាក់ពន្ធនាគារចំនួន១៥២នាក់ ប្រាក់ពិន័យនិងលក់វត្ថុតាងចំនួន៥៧០.៣៩៥.៥០០រៀល។

បានប្រជុំផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនៅតាមមូលដ្ឋានចំនួន១៣៤វគ្គ អ្នកពាក់ព័ន្ធចូលរួមចំនួន១១.៧៣៧នាក់ ក្នុងនោះស្ត្រីចំនួន ២.៦៤០នាក់។

**ឃ. ការអភិវឌ្ឍវារីវប្បកម្ម**

- ការចិញ្ចឹមត្រីអនុវត្តបានចំនួន១២០.០៥៥តោន ស្មើនឹង១២០%នៃផែនការ១០០.០០០តោន បើប្រៀបធៀបរយៈពេលដូចគ្នាកើនឡើងចំនួន៣០.០៥៥តោន
- ការចិញ្ចឹមក្រពើឆ្នាំ២០១៤ អនុវត្តបានចំនួន២១៥.៥០០តោន ស្មើនឹង៧១,៨៣%នៃផែនការ៣០០.០០០ក្បាល បើប្រៀបធៀបរយៈពេលដូចគ្នាថយចុះចំនួន១០៤.៥០០ក្បាល
- ការផលិតកូនត្រីពូជឆ្នាំ២០១៤ អនុវត្តបានចំនួន១២០លានកូន ស្មើនឹង៦៦,៦៧%នៃផែនការ១៨០លានកូន ប្រៀបធៀបរយៈពេលដូចគ្នាថយចុះចំនួន៣០លានកូន
- កន្លែងភ្ញាស់ត្រីសរុបមានចំនួន៣០១កន្លែង ក្នុងនោះ មាន២៨៨កន្លែង ជារបស់ប្រជាពលរដ្ឋតាមរយៈការផ្តល់បច្ចេកទេសពីមន្ត្រីរដ្ឋបាលជលផល
- មានប្រជាពលរដ្ឋប្រមាណ៦៥.០០០គ្រួសារ បានចូលរួមក្នុងសកម្មភាពចិញ្ចឹមត្រី ដោយបានទទួលការបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមត្រីជាបន្តបន្ទាប់ ក្នុងនោះមានកសិករ១៥៤នាក់ ជាគ្រូបង្គោល និងជាគ្រូផ្សព្វផ្សាយនៅមូលដ្ឋាន។

**ង. ការបង្កើតស្រះជម្រកត្រីសហគមន៍**

អនុវត្តតាមអនុសាសន៍របស់**សម្តេចតេជោ** កាលពីឆ្នាំ២០០៩ នៅខេត្តកែប ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានបង្កើតស្រះជម្រកត្រីសហគមន៍បាន៨០២កន្លែង នៅខេត្តកំពង់ស្ពឺមានចំនួនច្រើនជាងគេរហូតដល់១៧៣កន្លែង។

**ច. ការអភិវឌ្ឍន៍បច្ចេកវិទ្យាកែច្នៃនិងគុណភាព**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានអង្គភាពជំនាញជលផល កំពុងពន្យល់និងផ្សព្វផ្សាយ ដើម្បីឱ្យគ្រប់កន្លែងផលិតនិងកែច្នៃត្រី គោរពទៅតាមស្តង់ដារអនាម័យឱ្យបានត្រឹមត្រូវ ក្នុងន័យធានាសុខភាពសាធារណៈ និងទីផ្សារនាំចេញ ដោយរួមទាំងសកម្មភាពភូមិ១ ផលិតផលជលផល១ផងដែរ។ បានបង្កើតសមាគមអ្នកកែច្នៃចំនួន១៦ និងបានរៀបចំស្តង់ដារផលិតផលចំនួន៣ រួមមានស្តង់ដារប្រហុក ស្តង់ដារងៀតត្រីរ៉ស់-ឆ្ដោ និងស្តង់ដារបង្គាបង្កករហ័ស។

**ឆ. ការសិក្សាស្រាវជ្រាវជលផល**

ការសិក្សាស្រាវជ្រាវលើប្រភពធនធានជលផលទាំងទឹកសាបនិងសមុទ្របានដំណើរការល្អ ដោយសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍនានាដូចជា JICA, MRC, FAO, EU, World Fish Center ជាដើម។ល។ ដោយ

មានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍនេសាទទឹកសាប និងសមុទ្រជាអង្គភាពអនុវត្តផ្ទាល់។ ចំពោះលទ្ធផលស្រាវជ្រាវ ត្រូវបានបោះពុម្ពសៀវភៅផ្សព្វផ្សាយជាច្រើនពាន់ក្បាល និងប៉ុស្ទ័រជាច្រើនម៉ឺនសន្លឹក។

### ជ. ស្ថិតិផលផល

- ស្ថិតិផលនេសាទទឹកសាបឆ្នាំ២០១៤ អនុវត្តបានចំនួន៥០៥.០០៥តោន ក្នុងនោះមានដូចខាងក្រោម៖
  - នេសាទដាយត្រី អនុវត្តបានចំនួន១២.២៨៥តោន ស្មើនឹង៨១,៩០% នៃផែនការ១៥.០០០តោន បើប្រៀបធៀបរយៈពេលដូចគ្នាថយចុះ៧១៥តោន
  - នេសាទគ្រួសារក្នុងដែននេសាទ អនុវត្តបានចំនួន៣៤២.៦០០តោន ស្មើនឹង៨៧,៨៥% នៃផែនការ ៣៩០.០០០តោន បើប្រៀបធៀបរយៈពេលដូចគ្នាថយចុះ១២.៤០០តោន
  - នេសាទគ្រួសារក្នុងវាលស្រែ២០១៤ អនុវត្តបានចំនួន១៥០.១២០តោន ស្មើ៨៣,៤០% នៃផែនការ ១៨០.០០០តោន បើប្រៀបធៀបរយៈពេលដូចគ្នាថយចុះ៩.៨៨០តោន។
- ស្ថិតិផលនេសាទសមុទ្រ អនុវត្តបានចំនួន១២០.២៥០តោន ស្មើនឹង១០៩,៣២% នៃផែនការ១១០.០០០តោន បើប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង១០.២៥០តោន
- ស្ថិតិវារីវប្បកម្ម អនុវត្តបានចំនួន១២០.០៥៥តោន ស្មើនឹង១២០,០៦% នៃផែនការ១០០.០០០តោន បើប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង៣០.០៥៥តោន។

### ឈ. ការងារប្រមូលចំណូលផ្នែកផលផល

ប្រាក់ចំណូលពីពីវិស័យជលផលគ្រប់រាជធានី ខេត្ត ប្រមូលបាន**៣.៦១៦.៦៦០.៣៨២រៀល** ក្នុងនោះ មានប្រាក់ចំណូលពី៖

| | |
|---|---|
| – ថ្លៃឈ្នួលឡូត៍ដាយត្រី ដាយបង្កង | ២.១៧៦.២៨៩.០០០រៀល |
| – ថ្លៃឈ្នួលដែននេសាទសមុទ្រ | ៥០៥.២៨៤.១០០រៀល |
| – ប្រាក់ពិន័យ និងលក់វត្ថុតាង | ៥៧០.៣៩៥.៥០០រៀល |
| – សេវាសាធារណៈ | ១៣៤.១៤០.០០០រៀល |
| – ចំណូលផ្សេងៗ ក្នុងនោះ ការឈ្នួលអាគារ រោងចក្រ | ២៣០.៥៥១.៧៨២រៀល |

## VI- ការអនុវត្តគោលនយោបាយកំណែទម្រង់វិស័យព្រៃឈើ

អនុវត្តតាមកម្មវិធីកំណែទម្រង់វិស័យព្រៃឈើ ផ្នែកព្រៃឈើ បានខិតខំយកចិត្តទុកដាក់បំពេញការងាររបស់ខ្លួន ដោយទទួលបាននូវលទ្ធផលគួរឱ្យកត់សម្គាល់ដូចខាងក្រោម៖

### ក. ការបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍

ឆ្នាំ២០១៤ ការបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ សម្រេចបានប្រវែងសរុប១៦០,១៤គីឡូម៉ែត្រ ក្នុងនោះ ថវិការដ្ឋបានចំនួន៥៧៤បង្គោលត្រូវនឹងប្រវែង៨២គីឡូម៉ែត្រ និងថវិកាដៃគូអភិវឌ្ឍន៍ (JICA-CAM-REDD អង្គការពន្លឺកុមារ និង ADB) បានចំនួន៨៩៩បង្គោលត្រូវនឹងប្រវែង ៧៨,១៤គីឡូម៉ែត្រ ស្ថិតក្នុងខេត្តកំពង់ធំ ព្រះវិហារ សៀមរាប បាត់ដំបង ប៉ៃលិន កោះកុង និងមណ្ឌលគិរី ។

### ខ. សហគមន៍ព្រៃឈើ

បានចេញប្រកាសស្ដីពីការបង្កើតនិងគ្រប់គ្រងតំបន់ព្រៃសហគមន៍សរុបមានចំនួន១៩កន្លែង គ្របដណ្ដប់នៅលើផ្ទៃដីចំនួន២១.០២៤,០៦ហ.ត ស្ថិតក្នុងខេត្តស្ទឹងត្រែង ក្រចេះ កំពង់ធំ និងខេត្តរតនគិរី ហើយមានការចុះកិច្ចព្រមព្រៀងព្រៃសហគមន៍រវាងខណ្ឌរដ្ឋបាលព្រៃឈើសាមី ជាមួយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើបានចំនួន២២សហគមន៍ព្រៃឈើគ្របដណ្ដប់លើផ្ទៃដី ២៦.៤៩២ ហ.ត ស្ថិតក្នុងខេត្ត ព្រះវិហារ កំពង់ធំ កំពង់ស្ពឺ និងខេត្តកែប និងបានអនុម័តផែនការគ្រប់គ្រងព្រៃសហគមន៍ត្រពាំងល្ពាក់ចំនួន០១ មានផ្ទៃដី៣៨៣,៣៩ហ.ត ស្ថិតក្នុងខេត្តកំពង់ធំ។

### គ. ការប្រមូលចំណូលពីវិស័យព្រៃឈើ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈរដ្ឋបាលព្រៃឈើ បានប្រមូលចំណូលពីវិស័យព្រៃឈើចំនួន ៧០.០៦៣.៥៥៧.៦៣៥រ ស្មើនឹង១៧១.៧០% នៃផែនការ ក្នុងនោះ បានបង់ចូលថវិការដ្ឋចំនួន៥៥.៧០៤.៧៣៣.៤៧២រៀល និងបង់ចូលគណនីមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិចំនួន៣.៤១៩.៧៩៧.៥៥៥រៀលនិងប្រាក់រង្វាន់ចំនួន១០.៩៣៩.០២៦.៦០៩រៀល។

### ឃ. ការងារដាំដើមឈើ

- បានបណ្តុះកូនឈើសរុបចំនួន៤.៣៧៨.៩៩០ដើម ក្នុងនោះស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើ រួមជាមួយថ្នាលបណ្តុះកូនឈើរបស់រដ្ឋបាលព្រៃឈើបណ្តុះបានកូនឈើចំនួន២.៦៤៧.៧៩០ដើម ថ្នាលបណ្តុះកូនឈើ **សម្តេចតេជោហ៊ុន សែន** បណ្តុះបានកូនឈើចំនួន២១០.៣០០ដើម និងថ្នាលបណ្តុះកូនឈើបុគ្គលជាលក្ខណៈគ្រួសារបានចំនួន១.៥២០.៥០០ដើម ព្រមទាំងបានចែកចាយជូនប្រជាពលរដ្ឋចំនួន ៤.៦៨៧.៧៧២ដើម
- បានដាំដើមឈើសរុបចំនួន៥.៤២២ហ.ត ក្នុងនោះ ស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើរបស់រដ្ឋបាលព្រៃឈើដាំដើមឈើបានចំនួន៤០០ហ.ត ក្រុមហ៊ុនដាំឈើជាលក្ខណៈដៃគូសហការជាមួយរដ្ឋបាលព្រៃឈើដាំបានចំនួន១.១២០ហ.ត ដាំជាលក្ខណៈគ្រួសារដាំបានចំនួន៣៩ហ.ត និងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដាំបានចំនួន៣.៨៦៣ហ.ត
- បានប្រារព្ធពិធីបុណ្យរុក្ខទិវា នាថ្ងៃទី០៧ ខែកក្កដា នៅភូមិកណ្តឹងធំ ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ លើផ្ទៃដីទំហំ ២០ហ.ត ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។**

### ង. ការងារស្រាវជ្រាវ និងបណ្តុះបណ្តាល

បានអនុវត្តនូវគម្រោងសិក្សាស្រាវជ្រាវចំនួន០៦ រួមមាន (១) គម្រោងសិក្សាស្រាវជ្រាវពីបម្រែបម្រួលទឹកក្នុងតំបន់អាងទន្លេមេគង្គ (២) គម្រោងសិក្សាស្រាវជ្រាវអំពីវិធីសាស្ត្រស្តារព្រៃរេចរឹលសម្រាប់ការប្រើប្រាស់ច្រើនយ៉ាង (៣) គម្រោងស្រាវជ្រាវនិងស្តារព្រៃឈើឡើងវិញលើតំបន់អតីតព្រៃស្រោងនិងព្រៃល្បោះនៅខេត្តសៀមរាប (៤) គម្រោងស្រាវជ្រាវស្តីអំពីការបង្កើតប្រព័ន្ធតាមដាន ធ្វើរបាយការណ៍ និងផ្ទៀងផ្ទាត់ (MRV) សម្រាប់ការអភិវឌ្ឍយន្តការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់និងរេចរឹលព្រៃឈើ (៥) គម្រោងច្រករបៀងអភិរក្សជីវចម្រុះនៅមហាអនុតំបន់មេគង្គ (៦) គម្រោងសិក្សាស្រាវជ្រាវអំពីប្រភេទឈើងាយរងគ្រោះ។

### ច. ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ

- បានទទួលសំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃនិងកាប់រានដីព្រៃសរុបចំនួន២.៤០០ករណី ដែលក្នុងនោះ សំណុំរឿងបទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន៦២៩ករណី និងសំណុំរឿងបទល្មើសព្រៃឈើ ដែលត្រូវបញ្ជូនទៅតុលាការចំនួន១.៧៧១ករណី។ ចំពោះវត្ថុតាងបទល្មើសព្រៃឈើនិងសត្វព្រៃដែលបានចាប់ឃាត់ និងដកហូតរួមមាន ឈើមូល-ជ្រុង១.៧៥៤ម៉ែត្រត្រីគុណ ឈើអារ៥.៦១៧ម៉ែត្រត្រីគុណ ឈើគ្រាក់គ្រញូង១១៧ម៉ែត្រត្រីគុណ និង ១២.០១៨គីឡូក្រាម សត្វព្រៃចម្រុះប្រភេទចំនួន១.៨២៧គីឡូក្រាមនិង១.០៥៣ក្បាល និងអនុផលព្រៃឈើព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត។ ដីព្រៃឈើដែលបានកាប់រានចំនួន២.៨២៨ហ.ត ត្រូវបានបញ្ជូនសំណុំរឿងទៅតុលាការ និងបានដកហូតរណារយន្តបានចំនួន២២០គ្រឿង
- បានបញ្ចូលរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃ ដែលបានទទួលទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ (Case Tracking System-CTS) ដើម្បីរៀបចំឱ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប
- បានចុះស្រាវជ្រាវ ស៊ើបអង្កេត ត្រួតពិនិត្យ និងពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនៅខេត្តកំពង់ស្ពឺ កំពង់ធំ

ក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី។ ជាលទ្ធផល ក្រុមការងារបង្ក្រាបបានចំនួន២៧ករណី និងចាប់ឃាត់វត្ថុតាង ឈើចម្រុះប្រភេទចំនួន៣៨៦ម៉ែត្រគ្រីគុណ។

**ឆ. ការងារអភិរក្សព្រៃឈើ និងសត្វព្រៃ**

– បានអភិរក្សតំបន់ព្រៃការពារទំហំ១៦.២៨០ហ.ត ដើម្បីការពារធនធានព្រៃឈើ និងជីវចម្រុះ ដែលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្ររបស់សហគមន៍មូលដ្ឋាន តាមរយៈការប្រមូលផល អនុផលព្រៃឈើ ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងរួមចំណែកដល់ការធ្វើនិយតកម្មប្រភពទឹកសម្រាប់វារីអគ្គិសនី ដែលមានលទ្ធភាពផលិតចំនួនជិត១.០០០មេហ្គាវ៉ាត់ នៅតំបន់ជួរភ្នំក្រវាញ ដើម្បីជួយលើកកម្ពស់កំណើនសេដ្ឋកិច្ចនិងបរិស្ថាន ផ្តល់ទឹកសាបសម្រាប់ប្រើប្រាស់ និងស្រោចស្រពដំណាំកសិកម្ម

– បានបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃសៀមប៉ាង ខេត្តស្ទឹងត្រែងដែលមានផ្ទៃដីទំហំ៦៦.៩៣២ហ.តដើម្បីអភិរក្សសត្វព្រៃសំខាន់ៗ ជាពិសេសក្រុមប្រភេទមានដោយកម្រ និងជិតផុតពូជ។ រៀបចំតំបន់សម្រាកលំហែទស្សនាចរណ៍កំសាន្ត០២កន្លែងនៅក្នុងតំបន់ព្រៃការពារ និងតំបន់អភិរក្សសត្វព្រៃ ដើម្បីលើកស្ទួយវិស័យទេសចរណ៍ និងជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ការអភិវឌ្ឍសហគមន៍ និងជួយដល់ការគ្រប់គ្រង និងអភិរក្សជីវចម្រុះដោយប្រសិទ្ធភាព

– បានថែរក្សាការពារសត្វព្រៃគ្រប់ប្រភេទចំនួន១.២២៤ក្បាល (បក្សី៤៨ប្រភេទ ថនិកសត្វ៣៨ប្រភេទ និងល្មូន ១១ប្រភេទ) សង្គ្រោះសត្វព្រៃគ្រប់ប្រភេទចំនួន៩៥៤ក្បាល ស្តារលទ្ធភាពជីវសាស្ត្រ និងការដោះលែងទៅព្រៃធម្មជាតិវិញ ចំនួន៨៧០ក្បាល ព្យាបាលសត្វព្រៃរបួស ឈឺ ពិការចំនួន៣០០ក្បាល ធ្វើការអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្ស និស្សិតក្នុងនិងក្រៅប្រទេសបានចំនួន៨.៥៥០នាក់ បណ្តុះនិងដាំកូនឈើចំនួន១៨.២៥០ដើម សាងសង់សំណង់ទ្រុងសត្វ និងសំណង់ផ្សេងៗបានជាច្រើនទៀត

– បានអភិរក្សតំបន់ដែនជម្រកសត្វក្រពើសំខាន់ៗចំនួន០៤កន្លែង គឺនៅខេត្តកោះកុង (តំបន់អារ៉ែង ឆាយរាប តំបន់ស្តារក្រពើក្នុងឃុំតាតៃលើ) និងនៅខេត្តពោធិ៍សាត់ (តំបន់អូរសោម) និងបានដោះលែងក្រពើភ្នំចំនួន២៨ក្បាល ចូលបឹងធម្មជាតិនៅក្នុងខេត្តកោះកុង ព្រមទាំងបានបំពាក់ឧបករណ៍វិទ្យុសម្លេងតាមដានសត្វក្រពើ ដែលបានដោះលែងចំនួន១៥ក្បាល។

**ជ. ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម**

- មានរោងចក្រកែច្នៃឈើ រោងម៉ាស៊ីនអារឈើ រោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទធំ មធ្យម តូចសរុបចំនួន៤៦៧កន្លែង ដើម្បីកែច្នៃផល អនុផលព្រៃឈើ ស្របច្បាប់សម្រាប់សេចក្តីត្រូវការប្រើប្រាស់ក្នុងស្រុក និងធ្វើការនាំចេញតាមការចាំបាច់ និងមានរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើទូទាំងប្រទេសសរុបមានចំនួន ៦៩០កន្លែង

- មានក្រុមហ៊ុនចំនួន០៦ បាននាំចេញទៅបរទេស នូវឈើកែច្នៃគ្រប់ប្រភេទចំនួន ៧៥.២៩១ម៉ែត្រគ្រីគុណ ឈើអាកាស្យាកាត់កង់ៗចំនួន៥០០ស្ទែរ ចំណិតឈើដាំចំនួន៣.៩៣១តោន ធ្យូងអាកាស្យាចំនួន៣២តោន និងមានក្រុមហ៊ុនចំនួន០១ បាននាំចូលឈើអារនិងឈើឡាំងប្រភេទ CHANFUTA ចំនួន១.៣០០ម៉ែត្រគ្រីគុណ។

## VII- លទ្ធផលសម្រេចបានផ្នែកសេវាកម្មគាំទ្រនិងអភិវឌ្ឍន៍ធនធានមនុស្ស

### ក-លទ្ធផលសម្រេចបានលើការអនុវត្តគម្រោងវិនិយោគឯកជន

រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចផ្តល់ដីសម្បទានសេដ្ឋកិច្ច ក្នុងគោលបំណងលើកទឹកចិត្ត និងទាក់ទាញការវិនិយោគ ឯកជនទាំងក្នុងនិងក្រៅប្រទេស សំដៅអភិវឌ្ឍន៍វិស័យកសិកម្ម កសិ-ឧស្សាហកម្ម ជាលក្ខណៈប្រពលវប្បកម្មនិងពិពិធកម្ម ដែលរួមចំណែកដល់ការបង្កើតការងារធ្វើនៅជនបទ លើកស្ទួយជីវភាពប្រជាពលរដ្ឋឱ្យមានលក្ខណៈប្រសើរឡើងជាងមុន បង្កើនការនាំចេញផលិតផលកសិកម្ម និងការបង្កើនចំណូលរដ្ឋសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

គិតមកទល់ឆ្នាំ២០១៤ ក្រុមហ៊ុនដែលបានចុះកិច្ចសន្យារួចជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងកំពុងនៅមានសុពលភាពមានចំនួនសរុប១២១ក្រុមហ៊ុន ស្ថិតនៅក្នុង១៨ខេត្ត-ក្រុង លើផ្ទៃដីសរុបតាមកិច្ចសន្យាចំនួន ១.៣១៥.៤៨២ហិកតា និងផ្ទៃដីអាជីវកម្ម-ផលិតកម្មសរុបចំនួន ៨១១.២៦៦ហិកតា។

- **ការងារឈូសឆាយដាំដុះ**៖ ឈូសឆាយបានលើផ្ទៃដីចំនួន ៣៤២.៦៦៧ហិកតា និងដាំដុះដំណាំកសិ-ឧស្សាហកម្មបានចំនួន ២៨៨.៧៨៨ហិកតា
- **ការងារសាងសង់**៖ សាងសង់ប្រព័ន្ធផ្លូវគ្រប់ប្រភេទសរុបចំនួន ១០.៤៩៥គីឡូម៉ែត្រ
- **ការប្រើប្រាស់កម្លាំងពលកម្ម**៖ ពលកម្មសរុបមានចំនួន ៥៣.៦៧៧នាក់ ក្នុងនោះមាន បុគ្គលិកខ្មែរចំនួន ១២.៨១៣នាក់ កម្មករខ្មែរចំនួន ១៤.៥៦៩នាក់ កម្មករអណ្តែតចំនួន២៤.៥១៦នាក់ និងអ្នកជំនាញបច្ចេកទេសបរទេសចំនួន ១.៧៧៩នាក់។

បន្ថែមលើនេះ ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចដែលមានផ្ទៃដីតូចជាង១.០០០ហិកតា សរុបមានចំនួន៣៤ក្រុមហ៊ុន លើផ្ទៃដីចំនួន ៣៨.៨១៨ហិកតា។

ក្រុមហ៊ុនដែលបានទទួលគោលការណ៍វិនិយោគមុនបទបញ្ជាលេខ ០១ប.ប ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ តែមិនទាន់បានចុះកិច្ចសន្យាមានចំនួន១៣ក្រុមហ៊ុន។ រាជរដ្ឋាភិបាលកម្ពុជាបានពិនិត្យនិងវាយតម្លៃឡើងវិញលើក្រុមហ៊ុនទាំង១៣នេះ និងបានសម្រេចនិរាករណ៍គោលការណ៍វិនិយោគចំនួន៥ក្រុមហ៊ុន។ បច្ចុប្បន្ន ក្រុមហ៊ុនដែលនៅសល់ទាំង៨ (លើទំហំផ្ទៃដីចំនួន ៥៤.៤៨៧ហិកតា) បាននិងកំពុងបន្តអនុវត្តនីតិវិធី តាមខ្លឹមសារគោលការណ៍វិនិយោគរបស់រាជរដ្ឋាភិបាល។

**ស្ថានភាពក្រុមហ៊ុនបានលុបគោលការណ៍និងកិច្ចសន្យា**៖ ដោយក្រុមហ៊ុនមួយចំនួនមានភាពអសកម្ម លើកិច្ចដំណើរការគម្រោងវិនិយោគរបស់ខ្លួន និងក្រុមហ៊ុនមួយចំនួនត្រូវបានរាជរដ្ឋាភិបាលលុបគោលការណ៍ និងកិច្ចសន្យាវិនិយោគ គិតមកដល់ឆ្នាំ២០១៤នេះ ក្រុមហ៊ុនដែលត្រូវបានលុបគោលការណ៍ និងកិច្ចសន្យាមានសរុបចំនួន៦៩ក្រុមហ៊ុន លើផ្ទៃដីសរុបចំនួន ៥៨៧.៥៨០ហិកតា ក្នុងនោះមាន៖

- ក្រុមហ៊ុនមានផ្ទៃដីធំជាងមួយពាន់ហិកតាមានចំនួន៦១ក្រុមហ៊ុន លើផ្ទៃដីចំនួន ៥៨០.៦៦៧ហិកតា
- ក្រុមហ៊ុនមានផ្ទៃដីតូចជាងមួយពាន់ហិកតាមានចំនួន៨ក្រុមហ៊ុន លើផ្ទៃដីចំនួន ៦.៩១៣ហិកតា។

**ស្ថានភាពក្រុមហ៊ុនបានបង់ប្រាក់កក់**៖ ក្រុមហ៊ុនដែលបានបង់ប្រាក់កក់ធានាកិច្ចសន្យាជូនរដ្ឋ នៅធនាគារជាតិសរុបមានចំនួន ១៣៣ ក្រុមហ៊ុន៖

- ក្រុមហ៊ុនកំពុងវិនិយោគ បានបង់ប្រាក់កក់ធានាកិច្ចសន្យាចំនួន១១៩ក្រុមហ៊ុន មានទឹកប្រាក់សរុបចំនួន ៥.៩២៨.៤០៩,៨៦ USD និង៨០,៦៨ លានរៀល
- ក្រុមហ៊ុនបានបង់ប្រាក់កក់តែបានលុបគោលការណ៍និងកិច្ចសន្យាចំនួន១៤ក្រុមហ៊ុន មានទឹកប្រាក់សរុបចំនួន ៣១០.២៤៣ USD ។

**ការងារចុះបញ្ជីដីជាដីទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ** ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានស្នើសុំចុះបញ្ជីដីជាដីទ្រព្យសម្បត្តិឯកជនរបស់រដ្ឋបានចំនួន១២៧ក្រុមហ៊ុនលើផ្ទៃដីសរុបចំនួន១.១៩៧.៨១៧ហិកតា។ កន្លងមក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចាត់តាំងមន្ត្រីជំនាញជានីតិបុគ្គល ដើម្បីចូលរួមបំពេញឯកសារចុះបញ្ជីដីជាដីទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ គិតមកដល់ឆ្នាំ២០១៤ ក្រសួងបានចាត់មន្ត្រីចូលរួមបំពេញបែបបទស្នើសុំចុះបញ្ជីដីឯកជនរបស់បានចំនួន៣៤ក្រុមហ៊ុន ក្នុងនោះបានទទួលប័ណ្ណសម្គាល់សិទ្ធិអចលនវត្ថុបានចំនួន១៨ក្រុមហ៊ុនរួចហើយ។

## ១- ការរៀបចំលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យកសិកម្ម

ទន្ទឹមនឹងការអនុវត្តកម្មវិធីនីតិកម្មឆ្នាំ២០១៤ អង្គភាពជំនាញនីមួយៗក៏បានចូលរួមយ៉ាងសកម្ម ក្នុងការអភិវឌ្ឍបទដ្ឋានគតិយុត្ត ដែលជាកម្មវិធីនីតិកម្មវិស័យកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងក្របខណ្ឌសុវត្ថិភាពស្បៀង និងការអភិវឌ្ឍផលិតកម្មកសិកម្ម រួមមាន៖

### ខ.១. ការរៀបចំលិខិតបទដ្ឋានគតិយុត្តផ្នែកដំណាំ

សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងដីកសិកម្ម សេចក្តីស្តីពីការការពាររុក្ខជាតិនិងភូតគាមអនាម័យ សេចក្តីព្រាងច្បាប់ស្តីពីគុណភាពនិងសុវត្ថិភាពផលិតផលកសិកម្ម និង បទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីសហគមន៍កសិកម្ម កំពុងត្រូវបានរៀបចំយ៉ាងសកម្ម។ បន្ថែមពីនេះ ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ បាននិងកំពុងជំរុញការងាររៀបចំលិខិតបទដ្ឋានសំខាន់ៗមួយចំនួនទៀតដូចជា៖ សេចក្តីព្រាង គោល នយោបាយស្តីពីពូជដំណាំកម្ពុជា សេចក្តីព្រាងប្រកាសស្តីពីស្តង់ដារពូជដំណាំជាតិ សេចក្តីព្រាងប្រកាស សេចក្តីណែនាំ ទូទៅដើម្បីវាយតម្លៃភាពខុសប្លែក ឯកសណ្ឋានភាព និងស្ថេរភាពសម្រាប់ពូជថ្មីនៃដំណាំ សេចក្តីព្រាងប្រកាសស្តីពីនីតិវិធី នៃការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ សេចក្តីព្រាងប្រកាសរួមស្តីពី សោហ៊ុយសេវាកម្មត្រួតពិនិត្យភូតគាម អនាម័យនិងកម្វាត់សមាសភាពចង្រៃ សេចក្តីព្រាងប្រកាសស្តីពីបញ្ជីរាយមុខទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ និងសេចក្តីព្រាងប្រកាសស្តីពីការតែងតាំងនគរបាលយុត្តិធម៌ និងវិសោធនកម្មប្រកាសស្តីពី ការបង្កើតឯកសណ្ឋានសញ្ញា សម្គាល់ និងត្រារបស់មន្ត្រីភូតគាមអនាម័យ។

### ខ.២. ការរៀបចំលិខិតបទដ្ឋានគតិយុត្តផ្នែកកៅស៊ូ

ក្រសួងដែលមានអគ្គនាយកដ្ឋានកៅស៊ូជាសេនាធិការ បាននិងកំពុងរៀបចំចងក្រងសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូដែលបានចាប់ផ្តើមដំណើរការចាប់តាំងពីឆ្នាំ២០១០មករហូតដល់បច្ចុប្បន្ននេះ។ សេចក្តីព្រាងច្បាប់ត្រូវបានបញ្ចប់នៅត្រឹមថ្នាក់អគ្គនាយកដ្ឋានកៅស៊ូដែលរួមមាន១១ជំពូក ៩២មាត្រា និងឧបសម្ព័ន្ធ១ ដែលបច្ចុប្បន្នកំពុងពិនិត្យពិភាក្សានៅក្រសួង។

### ខ.៣.ការរៀបចំលិខិតបទដ្ឋានគតិយុត្តផ្នែកផលិតកម្ម និងបសុព្យាបាល

សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ មាន២២ជំពូក ដែលមានចំនួន១២៥មាត្រា។ សេចក្តីព្រាងច្បាប់នេះ ត្រូវបានប្រជុំចប់ក្នុងកម្រិតអន្តរក្រសួងរួចហើយ ហើយរង់ចាំដាក់ប្រជុំពេញអង្គនៅគណៈរដ្ឋមន្ត្រី មុននឹងបញ្ជូនទៅរដ្ឋសភាដើម្បីពិនិត្យនិងអនុម័ត។ បន្ថែមលើសពីនេះ ក្រសួងក៏បានពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វផងដែរ។

សេចក្តីព្រាងប្រកាសអន្តរក្រសួងរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីកិច្ចសម្របសម្រួលក្នុងការបង្កើតនិងការគ្រប់គ្រងសត្តឃាតដ្ឋានត្រូវបានរៀបចំ។ បន្ថែមលើសពីនេះទៀត ក្រសួងបានស្នើឱ្យរៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វបន្ថែមទៀត។ លិខិតបទដ្ឋាន និងសេចក្តីណែនាំទាក់ទងការបែងចែកនិងការប្រើប្រាស់ត្រាបសុពេទ្យ សម្រាប់បោះសម្គាល់លើផ្ទាំងសាច់ ដើម្បីបញ្ជាក់អនាម័យសាច់ និងពង្រាងផែនការយុទ្ធសាស្ត្រលុបបំបាត់ជំងឺផ្តែផ្តួតអាស៊ាន២០២០ កំពុងត្រូវបានរៀបចំ។

គោលនយោបាយ និងផែនការយុទ្ធសាស្ត្រស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ត្រូវបានពិនិត្យ ប្រជុំពិភាក្សាជាមួយបណ្តាអ្នកពាក់ព័ន្ធ ហើយឯកសារនេះ នឹងទទួលបាននូវការអនុម័តពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនាឆ្នាំ២០១៥។ លើសពីនេះទៀត សិក្ខាសាលា ផ្សព្វផ្សាយអនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានគតិយុត្តទាក់ទងការងារផលិតកម្មនិងបសុព្យាបាល ដល់មន្ទីរកសិកម្ម និងការិយាល័យផលិតកម្មនិងបសុព្យាបាលរាជធានីខេត្ត ក្រុមហ៊ុន អាជីវករពាណិជ្ជករ និងអ្នកពាក់ព័ន្ធដទៃទៀត ត្រូវបានអនុវត្ត ក្នុងគោលដៅដើម្បីអនុវត្តការងារផលិតកម្មនិងបសុព្យាបាល ឱ្យបានរលូន អនុវត្តតាមច្បាប់និងបច្ចេកទេស មានតម្លាភាព និងមានប្រសិទ្ធភាព។

### ខ.៤. ការរៀបចំលិខិតបទដ្ឋានគតិយុត្តផ្នែកជលផល

ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តផ្នែកជលផល ក្រសួងបានចេញសេចក្តីប្រកាសស្តីពីការបង្កើតការិយាល័យអភិរក្ស និងអភិវឌ្ឍន៍សត្វផ្សោតចំណុះក្រោមនាយកដ្ឋានអភិរក្សរដ្ឋបាលជលផល។

### ខ.៥.ការរៀបចំលិខិតបទដ្ឋានគតិយុត្តផ្នែកព្រៃឈើ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជំរុញការរៀចំសេចក្តីព្រាងច្បាប់ស្តីពីសត្វព្រៃនិងជីវចម្រុះព្រៃឈើ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀត ដើម្បីគាំទ្រដល់កម្មវិធីកំណែទម្រង់វិស័យព្រៃឈើ។

## ខ.៦.ការរៀបចំលិខិតបទដ្ឋានគតិយុត្តផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស

ក្រសួងបានស្នើសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល ស្តីពីការសុំប្រែក្លាយសាលាជាតិកសិកម្មព្រែកលៀប និង សាលាជាតិកសិកម្មកំពង់ចាម ទៅជាវិទ្យាស្ថានជាតិកសិកម្ម។

គួរកត់សម្គាល់ថា ទន្ទឹមនឹងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានចូលជាធរមាន ព្រះរាជាណាចក្រកម្ពុជាត្រូវបានយល់ព្រមឱ្យចូលរួមជាសមាជិកទី១៥១ នៃអនុសញ្ញារ៉ូថឺដាម ស្តីពីនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុនចំពោះសារធាតុគីមី និងថ្នាំកសិកម្ម គ្រោះថ្នាក់ក្នុងពាណិជ្ជកម្មអន្តរជាតិ នាថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣។ បច្ចុប្បន្ននេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបំពេញតួនាទីជាអាជ្ញាធរជាតិនៅក្នុងការអនុវត្តអនុសញ្ញានេះ។

## គ- ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំបំពេញភារកិច្ចយ៉ាងសកម្ម និងយកចិត្តទុកដាក់ជាសំខាន់ក្នុងការអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ តាមរយៈការបង្កើនចំណូលនិងវិចារណកម្មនៃចំណាយ ជាពិសេសបានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍវិស័យកសិកម្ម ក្នុងគោលដៅពង្រឹងនិងពង្រីកសេវាសាធារណៈ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

ការអនុវត្ត**ចំណាយថវិកាឆ្នាំ**២០១៤មានទឹកប្រាក់សរុបចំនួន**១៦៧.០៨៩.៨៧៤.០៥២រៀល** ស្មើនឹង១០៤,៩% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៤ ក្នុងនោះ (១)រដ្ឋបាលកណ្តាលអនុវត្តបានចំនួន**១២៧.៦៤៦.៥៩២.០៥២រៀល** ស្មើនឹង១០៨,១% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៤ (២)មន្ទីររាជធានីខេត្តអនុវត្តបានចំនួន**៣៩.៤៤៣.២៨២.០០០រៀល** ស្មើនឹង៩៥,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៤។ ជាទូទៅការអនុវត្តចំណាយថវិកាឆ្នាំ២០១៤ លើសច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយសារការបន្ថែមឥណទានជំពូក៦៤ សម្រាប់មុខចំណាយប្រាក់រង្វាន់ជូនមន្ត្រីរាជការ ដែលបានខិតខំប្រមូលចំណូលពីសេវាសាធារណៈបង់ចូលថវិការដ្ឋ និងការចំណាយអចលកម្មរូបីយ៍។ ដោយឡែកការអនុវត្តចំណាយថវិកាជំពូកផ្សេងៗទៀតទាបជាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយសារការសន្សំថវិកាពីការធ្វើលទ្ធកម្ម និងដោយសារអង្គភាពខ្លះមិនបានធ្វើសកម្មភាពតាមការគ្រោងទុក។

ការអនុវត្តប្រមូល**ចំណូលឆ្នាំ**២០១៤ មានទឹកប្រាក់សរុបចំនួន**៨៧.៤៦៨.០៦៥.៩១០រៀល** ស្មើនឹង១៧២,២% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ក្នុងនោះ (១)រដ្ឋបាលកណ្តាលអនុវត្តបានចំនួន**៨៥.២៨៤.៤០១.៩១០រៀល** ស្មើនឹង១៧១,២% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ (២)មន្ទីររាជធានី ខេត្ត អនុវត្តមានចំនួន**២.១៨៣.៦៦៤.០០០រៀល** ស្មើនឹង២២០,៤% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។ ការអនុវត្តចំណូលលើសច្បាប់ហិរញ្ញវត្ថុ ដោយសារការចុះពិនិត្យនិងជំរុញការបង់ចំណូលពីសម្បទានដីសេដ្ឋកិច្ចដែលដឹកនាំដោយគណៈកម្មការអន្តរក្រសួងចុះពិនិត្យ និងប្រមូលចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ចបង់ចូលថវិការដ្ឋ និងដោយសារការបង់ចំណូលពីការត្រួតពិនិត្យគុណភាពសាច់ ជី និងថ្នាំកសិកម្ម និងចំណូលពីការផាកពិន័យលើការកាប់ឈើ ដឹកឈើ និងដឹកសត្វខុសច្បាប់។

## ឃ- ការងារសហប្រតិបត្តិការអន្តរជាតិ

### ឃ.១. លទ្ធផលនៃកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាន

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទទួលសិទ្ធិប្រទានពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ានលើកទី៣៦ ព្រមទាំងកិច្ចប្រជុំអមមួយចំនួនទៀតនៅទីក្រុងណៃពីដោរ (Nay Pyi Taw) សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ដោយបានចុះហត្ថលេខា និង អនុម័តឯកសារមួយចំនួនដូចខាងក្រោម ៖

– **ឯកសារដែលបានចុះហត្ថលេខា ៖**

១. អនុស្សរណៈ នៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការអាស៊ាន និងអភិក្រមចម្រុះ ក្នុងការជំរុញផលិតផលកសិកម្ម និងព្រៃឈើឆ្នាំ២០១៥-២០១៩។

២. អនុស្សរណៈ នៃការយោគយល់គ្នារវាងរដ្ឋាភិបាល នៃប្រទេសសមាជិកអាស៊ាន និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិនស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការអនាម័យ និងភូតគាមអនាម័យ។

**–ឯកសារដែលបានអនុម័ត ៖**

១. ក្របខ័ណ្ឌសមាហរណកម្មសន្តិសុខស្បៀងអាស៊ាន និងផែនការសកម្មភាពយុទ្ធសាស្ត្រសម្រាប់សន្តិសុខស្បៀងឆ្នាំ២០១៥-២០២០។

២. បញ្ជីកម្រិតកាកសំណល់ជាតិពុលអតិបរមាចំនួន៧៣ប្រភេទនៃប្រភេទថ្នាំពុលកសិកម្មចំនួន១២ប្រភេទ។

៣. វិធីសាស្ត្រក្នុងការធ្វើវិភាគហានីភ័យសមាសភាពចង្រៃ។

៤. សេចក្តីណែនាំអាស៊ានស្តីពីលិខិតបទដ្ឋាន ការប្រើប្រាស់ និងពាណិជ្ជកម្មនៃភ្នាក់ងារត្រួតពិនិត្យជីវសាស្ត្រ។

៥. បមាណីអាស៊ានសម្រាប់ដំណាំកាកាវ ផ្សិត សណ្តែកដី ផ្លែទៀប ដំឡូងជ្វា អម្ពិលផ្អែម និងតែ។

៦. បមាណីអាស៊ានសម្រាប់កសិកម្មសរីរាង្គ។

៧. ផែនការសកម្មភាពយុទ្ធសាស្ត្រសម្រាប់កិច្ចសហប្រតិបត្តិការលើកសិកម្មសរីរាង្គ។

៨. ការទទួលស្គាល់ឡើងវិញនៃផ្នែកធ្វើតេស្តជីវសាស្ត្របសុព្យាបាលនៅប៉ាក់ចុង ប្រទេសថៃ ជាមន្ទីរពិសោធន៍ធ្វើតេស្តវ៉ាក់សាំងសត្វអាស៊ាន។

៩. បមាណីអាស៊ាននៃវ៉ាក់សាំងជំងឺអុតក្តាមសម្រាប់គោ និងក្របី ដែលបានបន្ថយសកម្មភាព (បានកែសម្រួល)

១០. បមាណីអាស៊ាននៃវ៉ាក់សាំងជំងឺអុតក្តាមសម្រាប់ជ្រូក ដែលបានបន្ថយសកម្មភាព (បានកែសម្រួល)។

១១. សេចក្តីណែនាំអាស៊ានស្តីពីការអនុវត្តផលិតកម្មល្អសម្រាប់ផលិតវ៉ាក់សាំង។

១២. ការអនុវត្តចិញ្ចឹមសត្វល្អអាស៊ានសម្រាប់មាន់ សាច់មាន់ ស៊ុត គំរូសុវត្ថិភាពចំណីអាហារ។

១៣. ផែនការយុទ្ធសាស្ត្រអាស៊ានសម្រាប់ការអនុវត្តចិញ្ចឹមសត្វល្អ។

១៤. យុទ្ធសាស្ត្រអាស៊ានលុបបំបាត់ជំងឺឆ្កែឆ្កួត។

១៥. សេចក្តីណែនាំអាស៊ានស្តីពីការអនុវត្តវារីវប្បកម្មល្អ ដែលទាក់ទងនឹងចំណីអាហារពីត្រី។

**–គម្រោងកិច្ចសហប្រតិបត្តិការក្រោមក្របខ័ណ្ឌអាស៊ាន ៖**

គម្រោង "ការពង្រឹងសមត្ថភាពលើវិស័យកសិកម្មក្នុងប្រទេសសមាជិកអាស៊ាន" ដំណាក់កាលទី២ ចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧ ដែលឧបត្ថម្ភថវិកាដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជប៉ុន។

**–ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំក្រុមការងារជំនាញអាស៊ាន ៖**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយដល់វេន ព្រមទាំងទទួលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល បានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំក្រុមការងារជំនាញបច្ចេកទេសអាស៊ានចំនួន៣ និងកិច្ចប្រជុំឧត្តមមន្ត្រីអាស៊ាន រួមជាមួយកិច្ចប្រជុំអមមួយចំនួនទៀតដូចខាងក្រោម ៖

១. កិច្ចប្រជុំក្រុមការងារបមាណីអាស៊ានលើកទី១០ ស្តីពីផលិតផលសាកវប្បកម្ម និងកិច្ចប្រជុំពាក់ព័ន្ធ។

២. កិច្ចប្រជុំក្រុមការងារជំនាញការលើកទី១៦ និងកិច្ចប្រជុំក្រុមការងារដំណាំអាស៊ានលើកទី២១។

៣. កិច្ចប្រជុំឧត្តមមន្ត្រីព្រៃឈើអាស៊ានលើកទី១៧ និងកិច្ចប្រជុំពាក់ព័ន្ធ។

៤. សិក្ខាសាលាស្តីពីកម្រិតកាកសំណល់ជាតិពុល និងកិច្ចប្រជុំក្រុមជំនាញបច្ចេកទេសលើកទី១៧ ស្តីពីការធ្វើសុខដុមនីយកម្មកម្រិតកាកសំណល់ជាតិពុលនៃថ្នាំពុលកសិកម្ម។

## ឃ.២. លទ្ធផលនៃកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី និងជាមួយអង្គការអន្តរជាតិ ៖

នៅក្នុងអំឡុងឆ្នាំ២០១៤-២០១៥ នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជួបពិភាក្សា ចរចារពិគ្រោះយោបល់ និងសម្របសម្រួលជាមួយប្រទេស ស្ថាប័ននានា សហគមន៍ផ្តល់ជំនួយក្នុងលក្ខណៈជាទ្វេភាគី និងពហុភាគី ព្រមទាំងជាមួយអង្គការអន្តរជាតិនានា ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍន៍ បច្ចេកទេស វិទ្យាសាស្ត្រ ស្រាវជ្រាវ និងការចុះហត្ថលេខាលើអនុស្សរណៈ ពិធីសារ កិច្ចព្រមព្រៀងដូចខាងក្រោម ៖

– ចុះហត្ថលេខាលើអនុស្សរណៈ ពិធីសារ ឯកសារគម្រោង និងកិច្ចព្រមព្រៀងគម្រោង ៖

## *១. ចុះហត្ថលេខាលើអនុស្សរណៈ កិច្ចព្រមព្រៀង ពិធីសារ ៖*

| ល.រ | អនុស្សរណៈ ពិធីសារ កិច្ចព្រមព្រៀង ផែនការសកម្មភាព | ជាមួយ | កាលបរិច្ឆេទចុះហត្ថលេខា |
|---|---|---|---|
| ១ | អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម និងផ្នែកពាក់ព័ន្ធ។ | ប្រទេស Seychelles | ២០១៤ |
| ២ | កិច្ចព្រមព្រៀងសហប្រតិបត្តិការស្តីពីការបណ្តុះបណ្តាលបច្ចេកទេសដាំឈើហូបផ្លែ និងបន្លែ។ | ក្រុមហ៊ុន ហ្វ៊ូវើង នៃ សាធារណរដ្ឋប្រជាមានិតចិន | ២៣ ធ្នូ ២០១៤ |
| ៣ | អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកទេសក្នុងវិស័យកសិកម្ម។ | ប្រទេសបង់ក្លាដេស | ១៧ មិថុនា ២០១៤ |
| ៤ | ពិធីសារស្តីពីការនាំចេញអង្ករ និងកញ្ចុំងអង្ករកម្ពុជាទៅកាន់ប្រទេសចិន។ | ប្រទេសចិន | ២៤ កញ្ញា ២០១៤ |
| ៥ | ពិធីសារស្តីពីការនាំចេញពោតកម្ពុជាទៅកាន់ប្រទេសចិន។ | ប្រទេសចិន | ២៤ កញ្ញា ២០១៤ |
| ៦ | ផែនការសកម្មភាពនៃកិច្ចសហប្រតិបត្តិការស្តីពីតម្រូវការភូតគាមអនាម័យ ដើម្បីនាំចេញផ្លែចេក ផ្លែស្វាយ និងសណ្តែកសៀងកម្ពុជាទៅកាន់ប្រទេសចិន។ | ប្រទេសចិន | ២៤ កញ្ញា ២០១៤ |
| ៧ | អនុស្សរណៈនៃការយោគយល់គ្នារវាងសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងសាកលវិទ្យាល័យនៃប្រទេសម៉ាឡេស៊ី និងចក្រភពអង់គ្លេស។ | University of Malaysia | ២០១៤ |
| ៨ | | BENA, Malaysia | ២០១៤ |
| ៩ | | Inter. Uni. of Malaya-Wales | ២០១៤ |
| ១០ | | Swansea Uni. of UK | ២០១៤ |

## *២. គម្រោងកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី ៖*

| ល.រ | ឈ្មោះគម្រោង | ប្រទេសផ្តល់ថវិកា | កាលបរិច្ឆេទចុះហត្ថលេខា | ថវិកាសរុប |
|---|---|---|---|---|
| ១ | Korea-Cambodia REDD+ Joint Project | Korea Forest Service of the Republic of Korea | ១០. ១២. ២០១៤ | 900.000 USD |
| ២ | Project on Safety Improvement of Agricultural and Processed Food Products in Cambodia | JICA, Japan | ១៩. ០៨. ២០១៤ | N/A |
| ៣ | Contract on the Implementation of Cambodia China Agriculture Promotion Center Project | Ministry of Commerce China | ២៣. ១២. ២០១៤ | N/A |

## *៣. កិច្ចព្រមព្រៀងអនុវត្តគម្រោងជាមួយអង្គការអន្តរជាតិ ៖*

| ល.រ | ឈ្មោះអង្គការ | ឈ្មោះគម្រោង | ថវិកា | សុពលភាពគម្រោង |
|---|---|---|---|---|
| ១ | PIN | Development of the Biodigester Sector in Cambodia | 500.000 USD | ០១. ០៣. ២០១៤ ដល់ ៣១. ១២. ២០១៦ |
| ២ | School Aid Japan | School Aid Japan Farm (SAJ Farm) | 252.755 USD | ០១. ០៤. ២០១៤ ដល់ ៣១. ០៣. ២០១៧ |
| ៣ | JVC | Community Livelihood Improvement through Ecological Agriculture and Natural Resources Management (CLEAN) | 337.290 USD | ០១. ០៤. ២០១៣ ដល់ ៣១. ០៣. ២០១៥ |
| ៤ | IVY | Poverty Reduction in Rural Area through Establishment of Sustainable Management of Svay Rieng Agro-products Cooperative (Phase II) | N/A | |

### ឃ.៣. គម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូ

ក្នុងឆ្នាំ២០១៤នេះ គម្រោងបានបញ្ចប់ការចុះកំណត់ទំហំសំណាកច្បារពូជរបស់កសិករកៅស៊ូគ្រួសារ និងច្បារពូជរបស់ចម្ការកៅស៊ូកសិឧស្សាហកម្មសរុបបានចំនួន១២៦គ្រួសារ ស្មើនឹងផ្ទៃដីទំហំ១០២,៦៤ហ.ត នៅក្នុងខេត្តចំនួន១០គឺ រតនគិរី ស្ទឹងត្រែង ក្រចេះ សៀមរាប ឧត្តរមានជ័យ ព្រះវិហារ កំពង់ចាម បាត់ដំបង ប៉ៃលិន និងកំពង់ធំ។ ចំពោះលទ្ធផលនៃការវិភាគ DNA លើច្បារពូជកៅស៊ូគ្រួសារឯកជនចំនួន១២៣ច្បារពូជ ស្មើនឹង៩៤,៨៤ហ.ត បានបង្ហាញថាក្នុងចំណោមសំណាកចំនួន២៤៧៩ដែលបានយកទៅធ្វើវិភាគមានសំណាកចំនួន២១០០ ដែលស្មើនឹង៨៥% ជាក្លូនដែលត្រឹមត្រូវ (TTT: True to type)។ លទ្ធផលបានបង្ហាញថាក្លូនខ្លះមានភាពត្រឹមត្រូវ (TTT) កម្រិតខ្ពស់រហូតដល់១០០%។

– **សមាគមន៍បណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ** (ANRPC: Association of Natural Rubber Producing Countries) គឺជាអង្គការអន្តររដ្ឋាភិបាល ដែលបានបង្កើតឡើងកាលពីឆ្នាំ១៩៧០។ សមាជិករបស់សមាគមន៍ត្រូវបានបើកទូលាយចំពោះរដ្ឋាភិបាលនៃបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ។ សមាគមន៍នេះ មានប្រទេសជាសមាជិកចំនួន១១ រួមមាន៖ កម្ពុជា ចិន ឥណ្ឌា ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ប៉ាពួញូហ្គីណេ ហ្វីលីពីន សឹង្ហបុរី ស្រីលង្កា ថៃ និងវៀតណាម។ កម្ពុជាបានចូលរួមវគ្គបណ្តុះបណ្តាល នៅប្រទេសវៀតណាម ថៃ រយៈពេលបីថ្ងៃ ស្តីពីការរៀបចំម៉ូឌែលស្ថិតិផ្គត់ផ្គង់ និងតម្រូវការកៅស៊ូធម្មជាតិ (Supply-Demand Statistics Modeling) និងបានចូលរួមក្នុងកិច្ចប្រជុំនិងសន្និសីទកៅស៊ូឆ្នាំ របស់សមាគមន៍នៃបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិនៅទីក្រុងគូឡាលំពួរនៃប្រទេសម៉ាឡេស៊ី ដែលបានប្រព្រឹត្តទៅអស់រយៈពេល៦ថ្ងៃគឺចាប់ពីថ្ងៃទី១៣-១៨ ខែតុលា ឆ្នាំ២០១៤។ នៅឆ្នាំ២០១៥នេះ ប្រទេសកម្ពុជាត្រូវទទួលវេនធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំ សន្និសីទ និងសន្និបាតប្រចាំឆ្នាំ២០១៥ ដែលជាព្រឹត្តការណ៍សំខាន់ជាប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា។

– **ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ** (IRRDB: International Rubber Research and Development Board) គឺជាបណ្តាញស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូ ដែលប្រមូលផ្តុំរាល់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូធម្មជាតិស្ទើរតែគ្រប់ប្រទេសផលិតកៅស៊ូធម្មជាតិទាំងអស់ ដែលមាន៩៥%នៃបរិមាណផលិតផលកៅស៊ូធម្មជាតិ នៅក្នុងពិភពលោកបានកើតឡើងតាំងពីឆ្នាំ១៩៣៤។ កម្ពុជាបានចូលជាសមាជិកទី១៦នៃក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ ក្នុងសម័យប្រជុំប្រចាំឆ្នាំរបស់ខ្លួនកាលពីថ្ងៃទី២៧-២៨ខែកញ្ញាឆ្នាំ២០០១នៅទីក្រុង Montpellier នៃសាធារណរដ្ឋបារាំង។

សន្និសីទកៅស៊ូអន្តរជាតិនិងកិច្ចប្រជុំប្រចាំឆ្នាំ បានប្រព្រឹត្តនៅចាប់ពីថ្ងៃទី២៤-២៨ ខែវិច្ឆិកា នៅឆ្នាំ២០១៤ នៅទីក្រុងម៉ានីលប្រទេសហ្វីលីពីន។ លទ្ធផលសំខាន់ៗ ដែលសម្រេចបានពីកិច្ចប្រជុំនៃគណៈកម្មាធិការនាយក និងនាយកប្រតិបត្តិនិងកិច្ចប្រជុំក្រុមប្រឹក្សានៃ IRRDB រួមមាន៖(១).កម្មវិធីប្តូរក្លូនកៅស៊ូពហុភាគី (២).បេសកកម្មទៅប្រមូលគ្រាប់កៅស៊ូនៅប្រទេសប៉េរ៉ូ សម្រាប់ប្រើប្រាស់ក្នុងការបង្កាត់ពូជកៅស៊ូនៅពេលអនាគត (៣)វិទ្យាស្ថានស្រាវជ្រាវកៅស៊ូវៀតណាមនឹងធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទកៅស៊ូ អន្តរជាតិនិងកិច្ចប្រជុំប្រចាំឆ្នាំ២០១៥ របស់ IRRDB នៅប្រទេសវៀតណាម (៤).ប្រទេសកម្ពុជាត្រូវទទួលវេនធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទកៅស៊ូអន្តរជាតិ និងកិច្ចប្រជុំប្រចាំឆ្នាំ២០១៦ របស់IRRDB (៥).ការប្រកាសចូលកាន់តំណែងថ្មីនៃប្រធាន IRRDB ដោយបានជ្រើសរើសលោកបណ្ឌិត James Jacob ជំនួសលោកស្រីបណ្ឌិត Datuk Dr. Salmiah Ahmad ។

– **ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍** (AFD: Agence Française de Développement) បានបន្តគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជា បានបង្កើតឡើងតាមអនុសញ្ញាហិរញ្ញប្បទានលេខ CKH 1123 01 H ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១២ រវាងព្រះរាជាណាចក្រកម្ពុជានិងទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ(AFD)។ គម្រោងនេះ មានរយៈពេល៣ឆ្នាំ (២០១៣-២០១៥) និងប្រើប្រាស់ថវិកាសរុបចំនួន២.៦៨៨.០០០អឺរ៉ូ ក្នុងគោលបំណងកែលម្អផលិតភាពនៃដំណាំកៅស៊ូនៅកម្ពុជា តាមរយៈការជំនួសច្បារពូជមិនត្រឹមត្រូវប្រមាណជាង៧០ហ.ត និងរៀបចំរុក្ខសម្ភារដោយមានការបញ្ជាក់ត្រឹមត្រូវ។ សកម្មភាពគម្រោង ដែលត្រូវអនុវត្តរួមមាន៖ (១).ការធ្វើបញ្ជីសារពើភ័ណ្ឌច្បារពូជកៅស៊ូនៅទូទាំងប្រទេស (២).ការបង្កើតច្បារពូជនិងថ្នាលកូនកៅស៊ូសម្រាប់ជួសកូនកៅស៊ូក្នុងច្បារពូជណាដែលមិនត្រឹមត្រូវ (៣).ការធ្វើវិភាគ ADN ទៅលើច្បារពូជ (៤).យុទ្ធនាការនៃការជួសកូនកៅស៊ូក្នុងច្បារពូជ (៥).ការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃច្បារពូជ។

– **កិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យអន្តរជាតិ** រួមមាន (១).បានចូលរួមសហកាជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ Nagoya នៃប្រទេសជប៉ុនក្នុងការថែទាំ និងជួសជុលឧបករណ៍ Sap flow, CO2 profile នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (២).សហការការងារជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ Kuyshu ដើម្បីស្រាវជ្រាវអំពី leaf photosynthesis និង(៣).សហការការងារជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ Hawaii សហរដ្ឋអាមេរិកដើម្បីថែទាំ និងជួសជុលឧបករណ៍Flux Tower នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

– **កិច្ចសហប្រតិបត្តិការជាមួយក្រសួងកសិកម្មនៃសាធារណរដ្ឋប្រជាមានិតចិន** រួមមាន (១).វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកប្រទេសចិន (CATAS) បានចុះកិច្ចព្រមព្រៀងកាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៣ នៅទីក្រុងកូឡុំបូប្រទេសស្រីលង្កា ក្នុងការធ្វើសហប្រតិបត្តិការស្រាវជ្រាវកៅស៊ូ។ ផ្អែកលើកិច្ចព្រមព្រៀងនេះ គណៈប្រតិភូ CATAS បានអញ្ជើញមកធ្វើទស្សនកិច្ចរយៈពេល៥ថ្ងៃគឺពីថ្ងៃទី១៧-២១ ខែធ្នូ ឆ្នាំ២០១៤ ដើម្បីស្វែងយល់ពីដំណើរការស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូនៅកម្ពុជា។ ក្នុងដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ CATAS មកកាន់កម្ពុជា វ.ស.ក.ក.បានសំណូមពរដល់ភាគី CATAS កសាងមជ្ឈមណ្ឌលមួយនៅកម្ពុជាសម្រាប់ធ្វើសហប្រតិបត្តិការស្រាវជ្រាវរួមគ្នា រួមទាំងការជួយបណ្តុះបណ្តាលធនធានមនុស្សនៃវ.ស.ក.ក (២).តាមរយៈកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយរវាងកម្ពុជា-ចិន និងតាមកិច្ចប្រជុំលើកទី២ កាលពីថ្ងៃទី៩-១០ ខែឧសភាឆ្នាំ២០១៣ របស់ក្រុមការងារទ្វេភាគីកម្ពុជា-ចិន សម្រាប់កិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម ភាគីចិនបានយល់ព្រមពិភាក្សាលម្អិត និងឈានទៅចុះហត្ថលេខាលើអនុស្សរណៈយោគយល់ (MoU) ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យឧស្សាហកម្មកៅស៊ូធម្មជាតិ។ សេចក្តីព្រាងអនុស្សរណៈបានរៀបចំនិងបានដាក់ជូនភាគីចិនរួចហើយ តែមិនទាន់ទទួលបានការចុះហត្ថលេខាជាផ្លូវការនៅឡើយទេ (៣).ជាមួយគ្នានោះដែរ ក្រសួងក៏បានលើកជាសំណើជូនភាគីចិន ក្នុងការជួយគាំទ្រនូវគម្រោងមួយចំនួនរួមមាន៖ ការបង្កើតការិយាល័យកៅស៊ូនៅតាមខេត្ត ការគ្រប់គ្រងចម្ការកៅស៊ូគ្រួសារតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS: Geographical Information System) និងការបង្កើនគុណភាពកៅស៊ូធម្មជាតិកម្ពុជាតាមរយៈការពង្រឹងបរិក្ខាសម្រាប់ធ្វើតេស្ត និងការស្រាវជ្រាវ (Improving the quality of cambodian natural rubber through enhancing rubber testing facilities and researches)។

## ឃ.៤. កិច្ចសហប្រតិបត្តិការផលិតកម្មនិងបសុព្យាបាល

វិទ្យាស្ថានក៏បានចូលរួមសហការជាមួយអង្គការ FAO ដើម្បីរៀបចំវេទិកាផ្សព្វផ្សាយជំងឺផ្តាសាយបក្សីដល់សិស្សសាលានៅខេត្តតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ដែលមានអ្នកចូលរួមសរុបចំនួន២.៩៩០នាក់ និងចែកជូនឃីតមួយចំនួន។

វិទ្យាស្ថានក៏បានចូលរួមក្នុងការអនុវត្តលំហាត់សាកល្បង អំពីជំងឺផ្តាសាយបក្សីនៅតាមបណ្តាខេត្តមួយចំនួន ដោយមានការចូលរួមពីក្រសួងសុខាភិបាល មន្ទីរកសិកម្មខេត្ត មន្ទីរសុខាភិបាលខេត្ត ការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត-ស្រុក អង្គការ FAO, WHO, USAID។

## ឃ.៥. កិច្ចសហប្រតិបត្តិការផ្នែកជលផល

ការសិក្សាស្រាវជ្រាវលើប្រភពធនធានជលផលទាំងទឹកសាបនិងសមុទ្របានដំណើរការល្អ ដោយមានការគាំទ្រ និងសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍនានាដូចជា JICA, MRC, FAO, EU, World Fish Center ជាដើម។ល។

## ឃ.៦. កិច្ចសហប្រតិបត្តិការផ្នែកព្រៃឈើ

ដៃគូអភិវឌ្ឍន៍ដែលគាំទ្រដល់កម្មវិធីព្រៃឈើជាតិមានចំនួន១៤ ស្មើនឹង៥៤គម្រោង មានថវិកាសរុបចំនួន១៨លានដុល្លារអាមេរិក អង្គការមិនមែនរដ្ឋាភិបាលមានចំនួន១៤ មានថវិកាសរុបចំនួន១៣,៥លានដុល្លារអាមេរិក សម្រាប់អនុវត្ត៣៩គម្រោង រាជរដ្ឋាភិបាលកម្ពុជាមានចំនួន០៩គម្រោង មានថវិកាសរុបចំនួន១,៣២លានដុល្លារអាមេរិក។ ក្រសួងបានសហការជាមួយដៃគូពីសាធារណរដ្ឋកូរ៉េ ដើម្បីសាងសង់អាគារវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើសត្វព្រៃមួយដែលមានកម្ពស់ពីរជាន់នៅភ្នំពេញ និងស្ថានីយស្រាវជ្រាវមួយកន្លែងទៀតនៅខេត្តសៀមរាប ដែលអាគារទាំងពីរនេះជួយបង្កលក្ខណៈងាយស្រួលដល់ការសិក្សាបច្ចេកទេសព្រៃឈើ។ បន្ថែមលើនេះ ក្រសួងក៏បានសហការជាមួយដៃគូអភិវឌ្ឍន៍គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងគ្រឹះស្ថានសិក្សាអប់រំមួយចំនួន ទាំងក្នុងនិងក្រៅប្រទេស ក្នុងការរៀបចំនិងបើកវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាមួយ

ចំនួន ដើម្បីពង្រឹងសមត្ថភាពបច្ចេកទេស ក៏ដូចជាផ្លាស់ប្តូរនូវចំណេះដឹងក្នុងវិស័យព្រៃឈើ ព្រមទាំងបានធ្វើការទំនាក់ទំនង និងរៀបចំបញ្ជូនមន្ត្រីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ សត្វព្រៃ និងមន្ត្រីពីអង្គភាពក្រោមរដ្ឋបាលព្រៃឈើទៅសិក្សានៅក្រៅប្រទេស។

### ឃ.៧. កិច្ចសហប្រតិបត្តិជាមួយដៃគូអភិវឌ្ឍនានា

#### ឃ.៧.១. គម្រោងកសាងសមត្ថភាពក្នុងការ ប្រើប្រាស់ជីវម៉ាសសម្រាប់ជីវថាមពល ឱ្យមានប្រសិទ្ធិភាពនិងសន្តិសុខស្បៀងក្នុង ប្រទេសមហាអនុតំបន់ទន្លេមេគង្គ [TA7833-REG]

គម្រោង [TA7833-REG] នៃធនាគារអភិវឌ្ឍន៏អាស៊ី (ADB) ក្រោមជំនួយថវិកាពី Nordic Development Foundation (NDF) ដើម្បីអនុវត្តគម្រោងកសាងសមត្ថភាពក្នុងការប្រើប្រាស់ជីវម៉ាសសម្រាប់ជីវឧស្ម័នឱ្យមានប្រសិទ្ធិភាព និងសន្តិសុខស្បៀងក្នុងប្រទេសអនុតំបន់ទន្លេមេគង្គ កម្ពុជា ឡាវ និង វៀតណាម។ រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា ឡាវ និងវៀតណាម បានចូលរួមចំណែកថវិកាប្រមាណជា៦សែនដុល្លារអាមេរិក ទៅនឹងថវិកាគម្រោង ដែលមានទឹកប្រាក់សរុបចំនួន៤.៦លានដុល្លារអាមេរិក សម្រាប់ដំណើរការគម្រោង។ គម្រោងនេះ មានរយពេលចាប់ពីខែធ្នូ ឆ្នាំ២០១១ រហូតដល់ ខែមិថុនា ឆ្នាំ២០១៤ នឹងត្រូវបានដោយក្រុមហ៊ុន Landell Mills Ltd (LML) នៃប្រទេសអង់គ្លេស ដែលជាក្រុមហ៊ុនទទួលផ្តល់ទីប្រឹក្សាបច្ចេកទេសសម្រាប់ការអនុវត្តន៏គម្រោងសហការជាមួយក្រសួងកសិកម្មនៃប្រទេសទាំងបី។ គម្រោងនេះ បានចាប់ផ្តើមបន្តដំណើរការគម្រោងរហូតដល់ ខែមិថុនា ឆ្នាំ២០១៥។ គម្រោងនេះត្រូវបានដឹកនាំ និងផ្តល់យោបល់ដោយគណៈកម្មការដឹកនាំក្រុមការងារកសិកម្ម GMS-WGA ដែលជាអ្នកគ្រប់គ្រងទូទៅ និងផ្តល់ជាយោបល់សម្រាប់តំរង់ទិសនៃការអនុវត្តគម្រោង។

សកម្មភាពការងារដែលបានអនុវត្តន៍ក្នុងឆ្នាំ២០១៤រួមមាន៖

- បានរៀបចំសន្និបាទ សិក្ខាសាលា ថ្នាក់តំបន់ និងថ្នាក់ជាតិ ដែលទាក់ទងទៅនឹងការពង្រីកការប្រើប្រាស់ចង្ក្រានសន្សំអុសឲ្យង ការប្រើប្រាស់ជីវម៉ាសប្រកបដោយប្រសិទ្ធភាព សម្រាប់ផលិតកម្មជីវឧស្ម័ន និងការប្រើប្រាស់ជីវឧស្ម័នសម្រាប់ផលិតជីសរីរាង្គ
- បានរៀបចំស្តង់ដារជាតិចំនួនពីរបាន រៀបរៀងឡើងដែលក្នុងនោះរួមមានស្តង់ដារ ឡជីវឧស្ម័ន និងស្តង់ដារស្រូវអង្ករសរីរាង្គកម្ពុជា សម្រាប់ស្តង់ដារស្រូវអង្ករសរីរាង្គកម្ពុជា ទទួលបាននូវអនុសាសមួយចំនួន និងបានរៀបចំផែនទី បង្ហាញផ្លូវសម្រាប់បន្តដំណើរការរហូតដល់ការងារអនុវត្តន៍
- បានរៀបចំឯកសារចំណេះដឹងទាក់ទង នឹងអត្ថប្រយោជន៍នៃជីវម៉ាសផ្សារភ្ជាប់ជាមួយកសិកម្មសមស្រប និងសន្តិសុខស្បៀងដែរ។ ស៊េរីព័ត៌មានស្តីពីជីវថាមពល ១២ប្រធានបទ ត្រូវបានចែកចាយទៅជូនស្ថាប័នរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ សង្គម ស៊ីវិល និងវិស័យឯកជនពាក់ព័ន្ធក្នុងក្របខណ្ឌជាតិ និងមហាអនុតំបន់។

ការសិក្សាស្រាវជ្រាវពីលទ្ធភាពដែលអាចធ្វើទៅបាន (Feasibility Study) ត្រូវបានជ្រើសរើសសម្រាប់ធ្វើការសិក្សាស្រាវជ្រាវពីលទ្ធភាពដែលអាចធ្វើទៅបាន (Feasibility Study) សម្រាប់ការវិនិយោគទៅលើគម្រោងសាកល្បង Pilot ចំនួន៣ដូចជា: (១) CelAgid សិក្សាស្រាវជ្រាវនិងអនុវត្តការទៅលើធ្វើបង្ហាញពីផលិតកម្មជីវឧស្ម័ន និងការប្រើប្រាស់ជីវឧស្ម័នលើដំណាំកសិកម្ម (ស្រូវ ពោត បន្លែ។ល។ (២) Mekong Carbon ជាអ្នកអនុវត្តការសិក្សាស្រាវជ្រាវទៅលើការពង្រីកវិសាលភាពបច្ចេកវិទ្យារបស់ឡជីវឧស្ម័នដោយមានការគ្រប់គ្រងកាកសំណល់ចេញពីឡជីវឧស្ម័ននិង(៣) Mekong Think Tank ការសិក្សាស្រាវជ្រាវទៅលើការពង្រីកគម្រោងការប្រើប្រាស់ចង្ក្រានគំរូ និងមានប្រសិទ្ធិភាពល្អ (ICS) ដែលមានស្រាប់នៅប្រទេសកម្ពុជា។ លទ្ធផលបានមកពីការសិក្សាស្រាវជ្រាវត្រូវបានទទួលស្គាល់ និងរៀបចំសាកល្បងសំណាកចំនួនបីដោយផ្តោតទៅលើ:

**១. គម្រោងសាកល្បងផលិតជីសរីរាង្គ និងធ្វើស្រែពិសោធន៍:**

ក្រុមហ៊ុន Mekong Carbon កំពុងសហការណ៍ជាមួយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍកសិកម្មកម្ពុជា CARDI អង្គការ COMPED និងក្រុមហ៊ុនផលិតជីភ្នំបៃតង (Green Mountain) ដើម្បីអនុវត្តការផលិតជីសរីរាង្គនិងធ្វើស្រែពិសោធន៍ដោយផ្តោតទៅលើរូមមន្តជីសរីរាង្គ៤រូបមន្តសម្រាប់ពិសោធន៍ លើបន្លែនិង៤រូបមន្តផ្សេងទៀតសម្រាប់ពិសោធន៍លើស្រូវ។

អង្គការ COMPED ជាអ្នកផ្គត់ផ្គង់ជីកំប៉ុស ទៅឱ្យក្រុមហ៊ុនភ្នំបៃតងដើម្បីផលិតជីសរីរាង្គទៅតាមរូបមន្តជីទាំង៨នេះ។ វិទ្យាស្ថាន CARDI ជាអ្នកអនុវត្តពិសោធន៍បែប វិទ្យាសាស្ត្រ ដោយប្រើរូបមន្តជីសរីរាង្គទាំងនេះទៅលើបន្លែនិងស្រូវ។ នៅពេលនេះ វិទ្យាស្ថាន CARDI បានចាប់ផ្តើមអនុវត្តពិសោធន៍រូបមន្តជីសរីរាង្គទាំង៤ទៅលើដំណាំបន្លែ នៅវិទ្យាស្ថាន CARDI ខេត្តកំពង់ឆ្នាំង និងបាត់ដំបង។

**២. គម្រោងសាកល្បង ទៅលើការធ្វើស្រែបង្ហាញដោយប្រើជីសរីរាង្គ:**

អង្គការ CelAgrid ជាអ្នកអនុវត្តគម្រោង សាកល្បងទៅលើការធ្វើស្រែបង្ហាញដោយប្រើជី សរីរាង្គទាំង៤រូបមន្ត ដែលដូចនឹងរូបមន្តពិសោធន៍របស់វិទ្យាស្ថាន CARDI លើបន្លែនិងស្រូវ ជាមួយនឹងកសិករគំរូ។ ការធ្វើបង្ហាញលើដំណាំបន្លែ និងស្រូវ ធ្វើនៅក្នុងឃុំចំនួនពីរនៃខេត្ត តាកែវ កំពង់ឆ្នាំង និងបាត់ដំបង។ គម្រោងក៏បានផ្តល់ឡជីវឧស្ម័នអង្គាមចំនួន១៣គ្រឿង ដែលផលិតដោយនាយកដ្ឋាន គ្រឿងយន្តកសិកម្មនៃក្រសួងកសិកម្ម ទៅឱ្យក្រុមកសិករនៅ តាមឃុំគោលដៅទាំងពីរនៃខេត្តតាកែវ និងបានផ្តល់វគ្គបណ្តុះបណ្តាលពី ការប្រើប្រាស់មុខងារបច្ចេកទេសរបស់ឡ និងអត្ថប្រយោជន៍របស់ជីវឧស្ម័នអង្គាមដល់ក្រុមកសិករទាំងនោះ។ សកម្មភាពស្រែបង្ហាញកសិករបានចាប់ផ្តើមដោយប្រើរូបមន្តជីសរីរាង្គ៤រូបមន្ត ដែលដូចនឹងរូបមន្តពិសោធន៍របស់វិទ្យាស្ថាន CARDI លើការដាំដុះបន្លែ ក្នុងតំបន់ អនុវត្តគម្រោងនៃខេត្តទាំងបី។

**៣. គម្រោងសាកល្បងចង្ក្រានឡូវថ្មី ICS:**

ផ្តោតទៅលើការពង្រឹកទ្រទ្រង់ទ្រាយនៃការប្រើប្រាស់ចង្ក្រានឡូវថ្មីនេះ នៅក្នុងឃុំចំនួនពីរនៃខេត្តកណ្តាលនិងកំពង់ធំ។ គម្រោងបានចុះកិច្ចព្រមព្រៀងជាមួយក្រុមស្ត្រីភូមិនិងឃុំ និងអ្នកផលិតចង្ក្រាន ដោយផ្តល់ជាថវិកាគាំទ្រ ដែលជាជំនួយដើម្បីបង្កើតទុនបង្វិល ទៅដល់អ្នកផលិត និងក្រុមស្ត្រីភូមិនិងឃុំ ដែលជាអ្នកលក់ចង្ក្រាននៅតាមភូមិ។ គម្រោងនេះ ត្រូវបានអនុវត្តដោយ ក្រុមហ៊ុន Mekong Think Tank ។

### ឃ.៧.២. គម្រោងកម្មវិធីជំរុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាពនិងបរិយាប័ន្ន នៃអនុវិស័យជលផលនិងផលិតកម្មសត្វ

សហភាពអឺរ៉ុបបានផ្តល់ហិរញ្ញប្បទានឥតសំណងសម្រាប់កម្មវិធី ***"ជំរុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាព និងបរិយាប័ន្ន នៃអនុវិស័យជលផលនិងផលិតកម្មសត្វ"*** ដែលមានទឹកប្រាក់សរុបចំនួន ២៦លានអឺរ៉ូ ក្នុងនោះ សហភាពអឺរ៉ុបផ្តល់ចំនួន ២០លានអឺរ៉ូ និងរាជរដ្ឋាភិបាលកម្ពុជាផ្តល់៦លានអឺរ៉ូ សម្រាប់អនុវត្តរយៈពេល៥ឆ្នាំ (២០១៣-២០១៨)។ គោលបំណងនៃគម្រោងនេះគឺ សំដៅរួមចំណែកជំរុញកំណើនក្នុងវិស័យកសិកម្ម ដោយផ្តោតជាសំខាន់លើការអភិវឌ្ឍអនុវិស័យជលផលនិងផលិតកម្មសត្វ។

ដោយឡែកសមាសភាគសំខាន់ៗនៃកម្មវិធីនេះរួមមាន សមាសភាគទី១៖ ការគាំទ្រគោលនយោបាយវិស័យកសិកម្ម: មានថវិកាសរុបចំនួន៤.១២០.០០០,០០អឺរ៉ូ (ថវិកាសហភាពអឺរ៉ុបផ្តល់ចំនួន៣.១២០.០០០អឺរ៉ូ និងរាជរដ្ឋាភិបាលកម្ពុជាផ្តល់ចំនួន១.០០០.០០០អឺរ៉ូ) និងអនុវត្តដោយនាយកដ្ឋានផែនការនិងស្ថិតិ សមាសភាគទី២៖ អនុវិស័យជលផល: មានថវិកាសរុបចំនួន១០.៣០០.០០០,០០អឺរ៉ូ (ថវិកាសហភាពអឺរ៉ុបផ្តល់ចំនួន ៧.៣០០.០០០អឺរ៉ូ និងរាជរដ្ឋាភិបាលកម្ពុជាផ្តល់ចំនួន ៣.០០០.០០០អឺរ៉ូ) និងអនុវត្តដោយរដ្ឋបាលជលផល និងសមាសភាគទី៣៖ អនុវិស័យផលិតកម្មសត្វ: មានថវិកាសរុបចំនួន៧.៨៥០,០០អឺរ៉ូ (ថវិកាសហភាពអឺរ៉ុបផ្តល់ចំនួន ៥.៨៥០.០០០អឺរ៉ូ និងរាជរដ្ឋាភិបាលកម្ពុជាផ្តល់២.០០០.០០០អឺរ៉ូ) និងអនុវត្តដោយនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល។

ក្រោយពីបានចុះកិច្ចព្រមព្រៀងហិរញ្ញប្បទាននេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចាត់ចែងអនុវត្តកម្មវិធីនេះ ដោយបានរៀបចំបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងនិងអនុវត្តកម្មវិធីនេះ រៀបចំនិងអនុវត្តផែនការសកម្មភាព៦ខែដំបូង (Start Up Programme Estimate-SUPE, 17 February to 16 August 2014) ក៏ដូចជាផែនការសកម្មភាពរយៈពេល១៦ខែ (ខែកញ្ញា ឆ្នាំ២០១៤ ដល់ខែធ្នូ ឆ្នាំ២០១៥) ដែលផែនការនេះ ត្រូវបានរៀបចំ និងកំពុងត្រូវបានអនុវត្តយ៉ាងល្អប្រសើរ ដោយក្រុមការងារអនុវត្តកម្មវិធីទាំងបីសមាសភាគ។

### ឃ.៧.៣. គម្រោងជំរុញការអនុវត្តកសិកម្មនិងការគ្រប់គ្រងទឹកធន់នឹងអាកាសធាតុនៅតំបន់ជនបទនៃប្រទេសកម្ពុជា (NAPA Follow Up Phase II)

គម្រោងនេះ បានអនុវត្តសកម្មភាពសំខាន់ៗមួយចំនួន ទាក់ទងទៅនឹងប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ ប្រព័ន្ធកសិកម្មចម្រុះ កែលម្អហេដ្ឋារចនាសម្ព័ន្ធដើម្បីទទួលបានទឹកតាមរយៈការជីកស្រះ អណ្តូងស្នប់ ការបូមទឹកដោយប្រើថាមពលព្រះអាទិត្យ និងប្រព័ន្ធស្រោចស្រព ផ្តល់ជំនាញបច្ចេកទេសដល់នាយកដ្ឋានជំនាញ។ ក្នុងឆ្នាំ២០១៤ គម្រោងសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ក្រុមប្រឹក្សាឃុំ ថ្នាក់ដឹកនាំក្រុម និងសមាជិកសហគមន៍ចំនួន១.៤៨៩ ក្នុងស្រុកគោលដៅចំនួន៤ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ និងបានយល់ដឹងអំពីបញ្ហាយេនឌ័ ការប្រែប្រួលអាកាសធាតុ
- មន្ត្រីស្រុក ក្រុមប្រឹក្សាឃុំ គណកម្មការផែនការនិងថវិកា និងអ្នកទទួលផលពីគម្រោងចំនួន១៤៣នាក់ ត្រូវបានអញ្ជើញឲ្យចូលរួមសិក្ខាសាលាស្តីពី VRA and RGA និងសិក្ខាសាលា/វគ្គបណ្តុះបណ្តាលស្តីពី CDP/CIP formulation in the planning cycles។
- គ្រួសារកសិករចំនួន១៨.០១៩ ក្នុងភូមិគោលដៅចំនួន៨០ ទទួលបានព័ត៌មានអាកាសធាតុនិងការបន្សាំទៅនឹងអាកាសធាតុ
- បានចុះពង្រឹងសមត្ថភាពអ្នកស្ម័គ្រចិត្តថ្នាក់ភូមិ EWS តាមរយៈការជួយប្រជុំប្រចាំខែ ធ្វើបច្ចុប្បន្នភាព ព័ត៌មាន ពិភាក្សាបញ្ហាបច្ចេកទេស
- អ្នកពាក់ព័ន្ធទាំងថ្នាក់ជាតិនិងថ្នាក់ខេត្ត និងក្រុមការងារគម្រោងចំនួន ១២០ មកពីខេត្តគោលដៅចំនួន៥ បានចូលរួមសិក្ខាសាលាផ្តោតលើបទពិសោធន៍ផ្នែកផ្សព្វផ្សាយកសិកម្ម និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- គម្រោងបានរួមចំណែកដល់ការរៀបចំបង្កើតផែនការសកម្មភាព សម្រាប់ការប្រែប្រួលអាកាសធាតុរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងទទួលបានការអនុម័តកាលពីដើមឆ្នាំ២០១៤កន្លងទៅ។ បញ្ហាប្រែប្រួលអាកាសធាតុត្រូវបានបញ្ចូលទៅក្នុងផែនការវិនិយោគឃុំ ចំនួន៣២។

### ឃ.៧.៤. គម្រោងអភិវឌ្ឍន៍កសិកម្មនិងជំរុញកំណើនសេដ្ឋកិច្ច (PADEE)

គម្រោងអភិវឌ្ឍន៍កសិកម្មនិងជំរុញកំណើនសេដ្ឋកិច្ច ផ្តល់មូលនីធិដោយមូលនីធិអន្តរជាតិ សម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម និងអនុវត្តនៅខេត្តចំនួន៥ គឺខេត្តកណ្តាល តាកែវ កំពត ព្រៃវែង និងស្វាយរៀង។ គម្រោងនេះ មានបីផ្នែកសំខាន់ៗគឺ (១).ទាក់ទងទៅនឹងការកែលម្អលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ ដោយសម្រេចលទ្ធផលការងារបាន៩៣% នៃវឌ្ឍនភាពជារូបវន្តនិង៨៥%នៃវឌ្ឍនភាពហិរញ្ញវត្ថុ (២).ពាក់ព័ន្ធនឹងលទ្ធភាពទទួលបានបច្ចេកវិទ្យានិងប្រកបចូលទីផ្សារ ដោយសម្រេចលទ្ធផលការងារបាន៩៦%នៃវឌ្ឍនភាពជារូបវន្ត និង៧៨%នៃវឌ្ឍនភាពហិរញ្ញវត្ថុ។ (៣).ទាក់ទងនឹងការគ្រប់គ្រងនិងការសម្របសម្រួលគម្រោង ដោយសម្រេចលទ្ធផលការងារបាន៨៦%នៃវឌ្ឍនភាពជារូបវន្ត និង៧៧%នៃវឌ្ឍនភាពហិរញ្ញវត្ថុ។

## ខ- ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យកសិកម្ម

ក្នុងឆ្នាំ២០១៤នេះ ក្រសួងមានមន្ត្រីរាជការសរុបចំនួន៦៨២២នាក់ នារី១៣៦៥នាក់ ស្មើនឹង២០% ក្នុងនោះថ្នាក់កណ្តាលមានចំនួន៤១៤៨នាក់ នារី៧៨៧នាក់ ស្មើ១៩%ថ្នាក់រាជធានីខេត្តមានចំនួន២៦៧៦នាក់ នារី៥៧៨នាក់ស្មើនឹង១៧.៨៦%។ ទន្ទឹមនឹងនេះ ក្រសួងបានដាក់មន្ត្រីឱ្យចូលនិវត្តន៍ចំនួន១៨២នាក់ដាក់ក្នុងភាព ទំនេរគ្មានបៀវត្សចំនួន២០៩នាក់ និងបានលុបឈ្មោះចេញពីក្របខ័ណ្ឌចំនួន៨៤នាក់ (បោះបង់ការងារលាឈប់មរណៈភាព)។ ក្រសួងបានធ្វើការប្រឡងប្រជែងប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការចំនួន៣៤៤នាក់ (ប្រភេទក្របខ័ណ្ឌ"ក"ចំនួន២៣០នាក់ និង"ខ"ចំនួន១១៤នាក់) និងបានធ្វើការប្រឡងប្រជែងជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មីចំនួន៣០៧នាក់ (ក្របខ័ណ្ឌ"ក"ចំនួន២១៨នាក់ និង"ខ"ចំនួន៨៩នាក់)។

ក្រសួងបានរៀបចំបើកគណនេយ្យបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារ ជូនមន្ត្រីរាជការទូទាំងក្រសួងបានចំនួន៦២៦៨នាក់ ព្រមទាំងបាននឹងកំពុងធ្វើនិយ័តកម្ម សមាហរណកម្មថ្នាក់ និងក្របខ័ណ្ឌមន្ត្រីរាជការ ដោយសហការជាមួយក្រសួងមុខងារសាធារណៈ។

ដើម្បីប្រសិទ្ធភាពការងារ និងជាការលើកទឹកចិត្តដល់មន្ត្រីរាជការ ក្រសួងបានតែងតាំង និងផ្ទេរភារកិច្ចមន្ត្រីរាជការបានចំនួន៤៣៩នាក់ ព្រមទាំងបានផ្តល់គ្រឿងឥស្សរិយយសជូនដល់មន្ត្រីរាជការ ដែលមានស្នាដៃឆ្នើមចំនួន

១៣៦៩នាក់ នារី២៦០នាក់ (ពីមេដាយសំរិទ្ធដល់ជាតូបការ)។ ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ក្រសួងបានបណ្តុះបណ្តាលមន្ត្រីរាជការបានចំនួន៣៩៧នាក់ (នារី៦៩នាក់) ដែលក្នុងនោះការបណ្តុះបណ្តាលរយៈពេលខ្លីក្នុងប្រទេសចំនួន៥០នាក់ និងក្រៅប្រទេស៣២៩នាក់ រយៈពេលវែង១៨នាក់ ថ្នាក់បណ្ឌិត២នាក់ និងបរិញ្ញាជាន់ខ្ពស់១៦នាក់។ ព្រមជាមួយនោះដែរ ក្រសួងបានរៀបចំកម្មវិធីបណ្តុះបណ្តាល ស្តីពីការពង្រឹងសមត្ថភាពមន្ត្រីកសិកម្មដល់មន្ត្រីរាជការថ្នាក់មូលដ្ឋាន មានចំនួន១៥៨នាក់ (នារី១៧នាក់) ពីថ្នាក់ការិយាល័យកសិកម្មស្រុកដល់ប្រធានមន្ទីរកសិកម្មខេត្ត ។

ក្នុងទិសដៅបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងលើកកម្ពស់ការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ ដើម្បីចូលរួមចំណែកអនុវត្តន៍គោលនយោបាយកាត់បន្ថយភាពក្រីក្រ របស់រាជរដ្ឋាភិបាលអណត្តិទី៥ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំកែសម្រួលរចនាសម្ព័ន្ធ នៅថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្ត រួមមានៈ រចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានកសិកម្ម រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល (ខណ្ឌផ្នែករដ្ឋបាលព្រៃឈើ និងជលផល) និងមន្ទីរកសិកម្មរាជធានី ខេត្ត ។ ជាពិសេស ក្រសួងបានរៀបចំលើកសំណើសុំការសម្រេចពីរាជរដ្ឋាភិបាល ដើម្បីសុំប្រែក្លាយសាលាជាតិកសិកម្មព្រែកលៀប និងសាលាជាតិកសិកម្មកំពង់ចាម ទៅជាវិទ្យាស្ថានជាតិ ឬសាកលវិទ្យាល័យជាតិកសិកម្ម ។

**ខ. ១. ការងារបណ្តុះបណ្តាលនិស្សិត**

គ្រឹះស្ថានឧត្តមសិក្សាទាំងបី មានសាស្ត្រាចារ្យ គ្រូបង្រៀន និងបុគ្គលិក សរុបចំនួន៣២៤នាក់ នារី៩៣នាក់ និងមាននិស្សិតកំពុងសិក្សាសរុបចំនួន៨៧៥៩នាក់ នារី២២៩៨នាក់ ដែលចែកចេញជាថ្នាក់បរិញ្ញារងចំនួន៤៦៤នាក់ បរិញ្ញាចំនួន៨០៦៥នាក់ បរិញ្ញាជាន់ខ្ពស់ចំនួន២១៥នាក់ និងថ្នាក់បណ្ឌិតចំនួន១៥នាក់ សិក្សាលើមុខជំនាញឯកទេសចំនួន១០ រួមមានៈ វិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍនន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមុខជំនាញវិទ្យាសាស្ត្រកៅស៊ូ។ ក្នុងឆ្នាំ២០១៤ មាននិស្សិតចំនួន១៧៦៩នាក់ នារី៤២៦នាក់ បានបញ្ចប់ការសិក្សាដោយជោគជ័យពីគ្រឹះស្ថានសិក្សាទាំងបី ។

ចំនួននិស្សិតចូលសិក្សាក្នុងថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ឆ្នាំសិក្សា២០១៤-២០១៥នេះ មានចំនួន១២០៩នាក់ នារី៤៧២នាក់ ប្រៀបធៀបនឹងឆ្នាំសិក្សា២០១៣-២០១៤ មានការថយចុះប្រមាណជាង៤០%ដោយសារកំណែទម្រង់ប្រព័ន្ធប្រឡងយកសញ្ញាបត្រទុតិយភូមិ ប្រកបដោយគុណភាពខ្ពស់ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

ក្រៅពីការងារបណ្តុះបណ្តាលនិស្សិត គ្រឹះស្ថានអប់រំទាំងបីក៏បានធ្វើការអភិវឌ្ឍន៍ធនធានសាស្ត្រាចារ្យ និងគ្រូបង្រៀនរបស់ខ្លួនឱ្យកាន់តែមានសមត្ថភាពបន្ថែមទៀត ដោយបានបញ្ជូនមន្ត្រីសាស្ត្រាចារ្យ និងគ្រូបង្រៀនចូលរួមសន្និសីទ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗ ទាំងក្នុងនិងក្រៅប្រទេស និងបានបញ្ជូនឱ្យទៅបន្តការសិក្សាថ្នាក់បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិតបន្ថែមទៀត នៅសាកលវិទ្យាល័យដៃគូ ។ ដោយឡែក គ្រឹះស្ថានទាំងបីក៏បានបញ្ជូននិស្សិតទៅធ្វើកម្មសិក្សា នៅសាកលវិទ្យាល័យដៃគូ នៅបរទេសបានចំនួន២១៧នាក់ ផងដែរ ។

គ្រឹះស្ថានអប់រំទាំងអស់បានធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សារបស់ខ្លួន ឱ្យមានលក្ខណៈសមស្របនឹងតម្រូវការទីផ្សារការងារ តាមរយៈកិច្ចសហប្រតិបត្តិការ និងការជួយឧបត្ថម្ភគាំទ្រពីដៃគូជាតិ-អន្តរជាតិ និងគម្រោងអភិវឌ្ឍន៍ផ្សេងៗ ជាពិសេសគម្រោង កែលម្អគុណភាពអនាម័យនិងភូតគាមអនាម័យ(SPS) មូលនិធិរបស់ធនាគារពិភពលោក តាមរយៈក្រសួងអប់រំ យុវជន និងកីឡា។ល។ គ្រឹះស្ថានសិក្សាបានបំពាក់នូវមធ្យោបាយ និងសម្ភារសិក្សាមួយចំនួនទៅលើមន្ទីរពិសោធន៍ បណ្ណាល័យ និងស្ថានីយ៍អនុវត្តន៍ជាក់ស្តែងដែលមានស្រាប់ និងបានជួសជុលអាគារមន្ទីរ ពិសោធន៍ អាគារគ្លីនិកសត្វ អាគារសិក្សា និងសាលប្រជុំ សរុបចំនួន៥ខ្នង ព្រមទាំងបានសាងសង់អាគារមន្ទីរ ពិសោធន៍ថ្មី១ខ្នង អាគារស្នាក់នៅ១ខ្នង ផ្លូវ១ខ្សែប្រវែង១០០០ម៉ែត្រ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗមួយចំនួនទៀត ដូចជា សួនច្បារ សួនដំណាំ ស្ថានីយ៍ចិញ្ចឹមសត្វ និងមច្ឆា ។

លើផ្នែកកិច្ចសហប្រតិបត្តិការអន្តរជាតិ មានអ្នកជំនាញការបរទេសចំនួន១២នាក់ កំពុងបម្រើការនៅក្នុងគ្រឹះស្ថានសិក្សា ក្នុងនោះមានជនជាតិជប៉ុន កូរ៉េ អាល្លឺម៉ង់ ឆេកូ សហរដ្ឋអាមេរិក កាណាដា ហ្វីលីពីន និងមានគ្រឹះស្ថានដៃគូរសហប្រតិបត្តិការអន្តរជាតិ ទាំងទ្វេរភាគី និងពហុភាគី សរុបចំនួន៥៦សាកលវិទ្យាល័យ ។

ចំពោះការងារស្រាវជ្រាវ គ្រឹះស្ថានសិក្សាទាំងបី បាននឹងកំពុងអនុវត្តន៍គម្រោងស្រាវជ្រាវចំនួន២៨គម្រោង ពាក់ព័ន្ធលើផ្នែកវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ ព្រៃឈើ ជលផល កសិឧស្សាហកម្ម រៀបចំដែនដី។ល។ ប្រភពហិរញ្ញវត្ថុសំខាន់ៗទទួលបានពី ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងបរិស្ថាន សហគមអឺរ៉ុប ប្រទេសកូរ៉េ ប្រទេសជប៉ុន សហរដ្ឋអាមេរិក ។ល។

**ខ. ២. ការងារយេនឌ័រនិងកុមារ**

- បានរៀបចំ Concept Note និងផែនការសកម្មភាពស្តីពីការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យកសិកម្ម ដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មឆ្នាំ២០១៤-២០១៨
- បានទទួលការគាំទ្រពីសហភាពអឺរ៉ុប (EU) ទាំងផ្នែកបច្ចេកទេសនិងថវិកា ដើម្បីរៀបចំធ្វើបច្ចុប្បន្នភាពគោលនយោបាយនិងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មឆ្នាំ២០១៥-២០១៨
- បានបើកសិក្ខាសាលាពិគ្រោះយោបល់លើ សេចក្តីព្រាងគោលនយោបាយនិងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មនា ដែលមានមន្ត្រីមកពីមន្ទីរកសិកម្ម រាជធានី ខេត្តទាំង២៥ចូលរួម
- បានផ្សារភ្ជាប់ទំនាក់ទំនងជាមួយដៃគូរអភិវឌ្ឍន៍មួយចំនួនដូចជា FAO UN WOMEN SNV USAID និង UNDP ដើម្បីទាក់ទាញការគាំទ្រទាំងផ្នែកបច្ចេកទេស និងថវិកាសម្រាប់អនុវត្តគោលនយោបាយនិងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មឆ្នាំ២០១៥-២០១៨
- បច្ចុប្បន្នបានកសាងគោលនយោបាយនិងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យកសិកម្មឆ្នាំ២០១៥-២០១៨ ជាភាសាអង់គ្លេសនិងបានបញ្ចប់សព្វគ្រប់ហើយគ្រោងនឹងធ្វើការបកប្រែជាភាសាជាតិដាក់ឆ្លងប្រជុំអចិន្ត្រៃយ៍ក្នុងពេលឆាប់ៗខាងមុខនេះ
- បានអនុវត្តការងារចុះបើកវគ្គបណ្តុះបណ្តាលស្តីពី ចំណេះដឹងយេនឌ័រ និងផ្សព្វផ្សាយអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ(ស៊ី-ដ) នៅតាមមន្ទីរកសិកម្មដូចជា ប៉ៃលិន ឧត្តរមានជ័យ ព្រះវិហារ ខេត្តស្ទឹងត្រែង ខេត្តរតនគីរី និងខេត្តមណ្ឌលគីរី សរុប២៩៤នាក់ ជាស្ត្រី ចំនួន៧១នាក់។
- បានរៀបចំ Concept Note និងផែនការសកម្មភាពស្តីពីកិច្ចគាំពារនិងអភិវឌ្ឍន៍កុមារក្នុងវិស័យកសិកម្ម និងដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្មឆ្នាំ២០១៥-២០១៨
- បានរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រគាំពារនិងអភិវឌ្ឍន៍កុមារក្នុងវិស័យកសិកម្មឆ្នាំ២០១៥-២០១៨ ក្រោមការឧបត្ថម្ភគាំទ្រទាំងផ្នែកបច្ចេកទេសនិងថវិកាសហភាពអឺរ៉ុប (EU) បច្ចុប្បន្នកំពុងស្វែងរកទីប្រឹក្សាជនជាតិខ្មែរនិងបរទេសដើម្បីរៀបចំគោលនយោបាយនិងផែនការយុទ្ធសាស្ត្រ
- បានរៀបចំដាក់បញ្ចូលសកម្មភាពគាំពារកុមារទៅក្នុងផែនការសកម្មភាពជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច ឆ្នាំ២០១៤ -២០១៨។

## VIII. បញ្ហាប្រឈម

### ក. បញ្ហាប្រឈមក្នុងផលិតកម្មដំណាំកសិកម្ម

- កង្វះធនធានមនុស្ស អ្នកភ្នាក់ងារបច្ចេកទេស អ្នកបច្ចេកទេសមធ្យមនៅមូលដ្ឋានថ្នាក់ក្រោម ដើម្បីអប់រំផ្សព្វផ្សាយបច្ចេកទេសឱ្យដល់កសិករ
- ភាពងាយរងគ្រោះនៃប្រព័ន្ធដាំដុះ ដោយសារកត្តាប្រែប្រួលអាកាសធាតុ និងកង្វះខាតប្រព័ន្ធស្រោចស្រពគឺជាបញ្ហាមួយដែលបានជួបប្រទះជារៀងរាល់ឆ្នាំ បន្ថែមលើនេះ កង្វះខាតធនធានសម្រាប់ការងារស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេសទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ គឺជាបញ្ហាមួយទៀតដែលត្រូវពិនិត្យពិចារណាបន្ថែមឱ្យស្របតាមទំហំការងារដែលចេះតែកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ ការស្រាវជ្រាវ អភិវឌ្ឍន៍ ផលិត និងផ្សព្វផ្សាយពូជដំណាំដែលមានគុណភាពនៅមានកម្រិត
- សមត្ថភាពសហគមន៍កសិកម្មដែលជាតួអង្គសេដ្ឋកិច្ចជនបទនៅមានកម្រិតនៅឡើយ ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់នាពេលខាងមុខ។ ម៉្យាងទៀត លទ្ធភាពទទួលបានសេវាផ្សព្វផ្សាយកសិកម្មក៏នៅមានកម្រិតដែរ។

សមត្ថភាពស្រូបយកចំណេះដឹងបច្ចេកទេសដាំដុះ និងការប្រើប្រាស់ធាតុចូលកសិកម្មឱ្យបានត្រឹមត្រូវតាមបទដ្ឋាន បច្ចេកទេស ក៏ដូចជាក្នុងការកែច្នៃផលិតផលក្នុងចំណោមប្រជាកសិករនៅមានកម្រិត។ សមត្ថភាពសហគមន៍កសិកម្ម ដែលប្រមូលផ្តុំគ្រួសារកសិករ អ្នកផលិតករ ត្រូវយកចិត្តទុកដាក់ការវិនិយោគលើកទឹកចិត្តដើម្បីពង្រឹងសមត្ថភាពនិងលទ្ធភាពផលិតកម្ម កែច្នៃ និងលក់ដូរ

– ការចូលរួមវិនិយោគក្នុងវិស័យកសិកម្មរបស់ផ្នែកឯកជនក្នុងការអភិវឌ្ឍផលិតកម្មដំណាំកសិកម្មនៅមានទំហំតូច បើប្រៀបធៀបនឹងវិស័យពីរផ្សេងទៀត ជាពិសេសការវិនិយោគជាលក្ខណៈសហគ្រាសខ្នាតមធ្យម និងធំក្នុងការកែច្នៃផលិតផលកសិកម្មដើម្បីបង្កើនតម្លៃបន្ថែម នៅមានកម្រិតទាប

– ចំពោះផលិតកម្មដំណាំកៅស៊ូ បញ្ហាកំពុងគំរាមកំហែងការអភិវឌ្ឍន៍ដំណាំនេះ។

## ខ. បញ្ហាប្រឈមក្នុងផលិតកម្មសត្វ

– ផលិតកម្មសត្វមិនសូវមានការរីកចម្រើនខ្លាំងក្លានៅឡើយ ផលិតកម្មគោក្របីមានការថយចុះ ដោយសារកំណើនគ្រឿងយន្តកសិកម្ម ការថយចុះវាលស្មៅចិញ្ចឹមសត្វ ការបំរែបំរួលអាកាសធាតុ ខ្វះប្រភពទឹក ខ្វះកំលាំងពលកម្មចំណាកស្រុក កំណើននៃការនាំចេញ និងកំណើននៃតម្រូវការសាច់ក្នុងស្រុក

– អត្រាឈឺ ស្លាប់សត្វ និងជំងឺឆ្លងសត្វនៅតែជាការគំរាមកំហែងដល់ផលិតកម្មសត្វធ្វើឱ្យផលិតភាពសត្វថយចុះ ខ្វះខាតថ្នាំការពារ ព្យាបាលសត្វ និងឧបករណ៍សម្ភារបរិក្ខាបសុពេទ្យ

– នៅមានបទល្មើសដឹកជញ្ជូនសត្វ និងផលិតផលសត្វ ការគ្រប់គ្រងសត្តឃាតដ្ឋាន និងការត្រួតពិនិត្យអនាម័យសត្វនៅអនុវត្តមិនទាន់មានប្រសិទ្ធភាពនៅឡើយ

– ការស្រាវជ្រាវផលិតកម្មនិងបសុព្យាបាល ការផ្សព្វផ្សាយបច្ចេកទេសផលិតកម្មបសុព្យាបាលអនុវត្តនៅមានកម្រិតអាស្រ័យដោយធនធាននិងមធ្យោបាយមានកម្រិត។

## គ. បញ្ហាប្រឈមក្នុងផ្នែកជលផល

– បទល្មើសនេសាទនៅតែកើតមាន និងការទន្ទ្រានយកដីក្នុងដែននេសាទធ្វើជាកម្មសិទ្ធឯកជន នៅតែមានសកម្មភាព

– ការយល់ដឹងរបស់ប្រជានេសាទពីសារៈប្រយោជន៍នៃធនធានជលផលនៅមានកម្រិត

– ការអនុវត្តច្បាប់នៅមានកម្រិត និងកិច្ចសហការពីអាជ្ញាធរពាក់ព័ន្ធមួយចំនួននៅមានកម្រិត

– សហគមន៍នេសាទពុំមានធនធានគ្រប់គ្រាន់ សម្រាប់អនុវត្តផែនការសកម្មភាពរបស់ខ្លួន និងសមត្ថភាពរបស់សមាជិកសហគមន៍នេសាទនៅមានកម្រិត។

## ឃ. បញ្ហាប្រឈមក្នុងផ្នែកព្រៃឈើ

– ការយល់ដឹងពីសារៈសំខាន់ធនធានព្រៃឈើក្នុងចំណោមប្រជាជនមូលដ្ឋានពឹងអាស្រ័យ អនុផលព្រៃឈើនៅមានកម្រិតទាបនៅឡើយ ដែលទាមទារឱ្យមានការពន្យល់ផ្សព្វផ្សាយបន្ថែមទៀត

– ការងារបង្រ្កាបបទល្មើស និងការកាប់រានដីព្រៃយកដីធ្វើជាកម្មសិទ្ធិល្មើសច្បាប់ មានការលំបាក ពីព្រោះជនប្រព្រឹត្តបទល្មើសតែងតែផ្លាស់ប្តូរវិធីសាស្រ្តក្នុងការដឹកជញ្ជូន និងបំផ្លាញព្រៃឈើក្រោមរូបភាពផ្សេងៗ

– កង្វះខាតកិច្ចសហប្រតិបត្តិការនិងការចូលរួមពេញលេញពីអាជ្ញាធរមូលដ្ឋាននិងស្ថាប័នពាក់ព័ន្ធ

– ការតាំងទីលំនៅរបស់ជនចំណាកស្រុកក្នុងតំបន់ព្រៃការពារនិងតំបន់អភិរក្សសត្វព្រៃ និងថវិកាដៃគូអភិវឌ្ឍន៍ចូលរួមក្នុងការបោះបង្គោលព្រំនៅមានកម្រិត

– សហគមន៍ព្រៃឈើដែលមានទីតាំងក្នុងព្រៃសម្បទាន ឬសម្បទានដីសេដ្ឋកិច្ច ពុំមានប្រកាសទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឡើយ ប្រសិនបើគ្មានការឯកភាពពីសម្បទានិក

– ថវិការដ្ឋដែលគាំទ្រដល់ដំណើរការអនុវត្តសហគមន៍ព្រៃឈើមានចំនួនតិចតួច ស្របពេលការគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍មានការថយចុះ

– អង្គការសង្គមស៊ីវិលរៀបចំសហគមន៍ព្រៃឈើ ពុំមានកិច្ចសហការពីមន្រ្តីខណ្ឌរដ្ឋបាលព្រៃឈើ ក្នុងការកំណត់ទីតាំងត្រូវបង្កើត

– ដំណើរការនៃការរៀបចំបង្កើតព្រៃការពារមានភាពស្មុគ្រស្មាញ និងត្រូវការពេលវេលាយូរ។

## IX- ទិសដៅអនុវត្តឆ្នាំ២០១៥-២០១៦

សម្រាប់ឆ្នាំ២០១៥-២០១៦នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់ចេញនូវទិសដៅ និងផែនការអនុវត្តដូចខាងក្រោម ៖

### ១. ផែនការផលិតកម្មដំណាំស្រូវ ដំណាំរួមផ្សំនិងឧស្សាហកម្ម

#### ក. សូចនាករទិសដៅ

- ជំរុញការដាំដុះដំណាំស្រូវទូទាំងប្រទេសឆ្នាំ២០១៥-២០១៦ ឱ្យបាន៣,០៥៨លានហ.ត (កំណើន០,១%) ដោយត្រូវបង្កើនផ្ទៃដីស្រូវបង្កើនរដូវលើផ្ទៃដីស្រូវរដូវវស្សានិងប្រាំង។ ទិន្នផលស្រូវប្រចាំឆ្នាំ ត្រូវជំរុញឱ្យមានកំណើន២,៣% គឺកើនពី៣,០៧៩តោន/ហតឆ្នាំ២០១៤-២០១៥ ទៅដល់៣,១២២តោន/ហត នៅឆ្នាំ២០១៥-២០១៦ ក្នុងនោះទិន្នផលស្រូវវស្សាត្រូវជំរុញឱ្យកើនដល់២,៩តោន/ហត និងទិន្នផលស្រូវប្រាំង៤,៤៤៨តោន/ហត
- បរិមាណផលស្រូវសរុបនឹងត្រូវបង្កើនឱ្យបានយ៉ាងតិច៩,៥៤លានតោននាឆ្នាំ២០១៥-២០១៦ ពោលគឺត្រូវឱ្យកើនប្រមាណជា៣%ធៀបនឹងឆ្នាំមុន ក្នុងនោះបរិមាណផលស្រូវវស្សាត្រូវសម្រេចឱ្យបាន៧,៣៨លានតោន និងស្រូវប្រាំង២,១៦លានតោន
- ជំរុញការដាំដុះដំណាំរួមផ្សំនិងឧស្សាហកម្ម (ពោត ដំឡូងឈើ ដំឡូងជ្វា បន្លែ សណ្តែកបាយ សណ្តែកដី សណ្តែកសៀង អំពៅ ល្ង) ឱ្យបានកើនឡើងពី៩៥៣ពាន់ហ.ត ទៅដល់៩៧២ពាន់ហ.តនៅឆ្នាំ២០១៥-២០១៦ ពោលគឺត្រូវបង្កើនផ្ទៃដីដាំដុះក្នុងកម្រិត២%។

#### ខ. វិធានការអនុវត្តដើម្បីសម្រេចបានទិសដៅកំណត់

- បង្កើនការផលិតនិងចែកចាយផ្សព្វផ្សាយពូជស្រូវ១០មុខ (ដែលមានគុណភាពល្អ) ឱ្យចូលជ្រៅដល់ស្រទាប់កសិករ និងបន្តផ្សព្វផ្សាយប្រភេទអង្ករប្រណិតខ្មែរលើទីផ្សារ។ ដូចនេះ ត្រូវបង្កើនធនធានដល់បណ្តាស្ថានីយ៍ពិសោធន៍ ស្រាវជ្រាវ មណ្ឌលអភិវឌ្ឍន៍កសិដ្ឋាន ឱ្យមានដំណើរការសកម្មជាងមុន ពិសេសស្ថានីយ៍ស្រាវជ្រាវដំណាំបន្លែ
- ពង្រឹងសមត្ថភាពគ្រប់គ្រងនិងបង្កើនធនធានហិរញ្ញវត្ថុគាំទ្រដល់សហគមន៍កសិកម្ម ដោយផ្តល់សេវាផ្សព្វផ្សាយកសិកម្ម និងធនធានដល់សហគមន៍ទាំងនោះ។ អគ្គនាយកដ្ឋានកសិកម្ម ត្រូវខិតខំរៀបចំនិងផ្តល់ការបំពាក់បំប៉នសម្រាប់បង្កើនសមត្ថភាពគ្រប់គ្រង និងប្រតិបត្តិដល់សហគមន៍អភិវឌ្ឍន៍កសិកម្មឱ្យមានប្រសិទ្ធភាព និងត្រូវបង្កើតសហគមន៍អភិវឌ្ឍន៍កសិកម្មបន្ថែមទៀតនៅឆ្នាំ២០១៥
- ពង្រឹងសេវាផ្សព្វផ្សាយកសិកម្មនៅថ្នាក់មូលដ្ឋាន ពិសេសថ្នាក់ស្រុក ដោយត្រូវខិតខំយកចិត្តទុកដាក់ដល់មន្ត្រីផ្សព្វផ្សាយ និងបង្កើនធនធានហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់។ អគ្គនាយកដ្ឋានកសិកម្ម ត្រូវជំរុញការបណ្តុះបណ្តាលបច្ចេកទេសបន្ថែមដល់មន្ត្រី និងភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ឱ្យបានកាន់តែច្រើនថែមទៀតនៅឆ្នាំ២០១៥
- ខិតខំរៀបចំយន្តការអនុវត្ត ផលិតកម្មកសិកម្មតាមកិច្ចសន្យា ឱ្យមានដំណើរការល្អប្រសើរ ពិសេសការរៀបចំបង្កើតទម្រង់កិច្ចសន្យាសម្រាប់សហគមន៍កសិករ ក្រុមអ្នកប្រមូលទិញ ដើម្បីជាមូលដ្ឋានអនុវត្ត
- ស្វះស្វែងរកប្រភពធនធានដើម្បីរៀបចំកំណត់តំបន់ដាំដុំ និងការកសាងផែនទីប្រើប្រាស់ដីកសិកម្ម
- បង្កើនការរៀបចំបញ្ចប់សេចក្តីព្រាងច្បាប់ពាក់ព័ន្ធនឹងការងារផលិតកម្មកសិកម្ម
- ត្រៀមលក្ខណៈឱ្យបានល្អក្នុងការជួយអន្តរាគមន៍សង្គ្រោះ ពីផលប៉ះពាល់ដោយគ្រោះធម្មជាតិ និងកត្តាចង្រៃផ្សេងៗនៃដំណាំ ដោយត្រូវត្រៀមបំរុងស្រូវពូជ ពូជបន្លែឱ្យបានគ្រប់គ្រាន់
- ជំរុញការកសាងច្បាប់ដូចជាច្បាប់ការពារដំណាំ ច្បាប់ដីកសិកម្ម។ល។ និងបទដ្ឋានក្រោមច្បាប់នានា ដើម្បីដឹកនាំគ្រប់គ្រងឱ្យមានប្រសិទ្ធភាពខ្ពស់

## ២ ផែនការផលិតកម្មដំណាំកៅស៊ូ

### ក. សូចនាករទិសដៅ

– ជំរុញផលិតកម្មនិងបង្កើនផ្ទៃដីដំណាំកៅស៊ូនៅឆ្នាំ២០១៥ ក្នុងកំណើនប្រមាណ២% ធៀបនឹងឆ្នាំ២០១៤ ដោយត្រូវសម្រេចឱ្យបានការដាំដុះលើផ្ទៃដី៣៦៥៣ពាន់ហ.ត ពិសេសបង្កើនការជំរុញការដាំដុះកៅស៊ូកសិឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋ និងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច) និងកៅស៊ូគ្រួសារ
– ផលិតផលកៅស៊ូស្ងួតនៅក្នុងឆ្នាំ២០១៥ នឹងត្រូវបង្កើនដល់១០៦ពាន់តោន
– បង្កើនការនាំចេញកៅស៊ូឱ្យបានប្រមាណ១១២ពាន់តោននៅឆ្នាំ២០១៥។

### ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់

– ជំរុញការពង្រីកផ្ទៃដីដំណាំកៅស៊ូរបស់ក្រុមហ៊ុនឯកជននិងកៅស៊ូគ្រួសារ ពិសេសចូលរួមពិនិត្យ តាមដានការអនុវត្តផែនការកម្មវិធីវិនិយោគកៅស៊ូលើដីសម្បទានសេដ្ឋកិច្ច សង្គមកិច្ច និងវាយតម្លៃលទ្ធផលដែលសម្រេចបាន
– ធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជា២០១១-២០២០
– ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារ និងអង្គការកៅស៊ូអន្តរជាតិនានា លើកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌការងារស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិជ្ជាវិទ្យាសាស្ត្រ ព័ត៌មានអំពីការផ្គត់ផ្គង់ និងតម្រូវការប្រើប្រាស់កៅស៊ូ អំពីនិន្នាការនៃតម្លៃកៅស៊ូលើទីផ្សារក្នុងនិងក្រៅប្រទេស ដើម្បីជំរុញនិងសម្របសម្រួលតម្លៃលក់កៅស៊ូឱ្យបានសមស្របតាមតម្លៃលើទីផ្សារអន្តរជាតិ
– បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវ ការផ្សព្វផ្សាយនិងបណ្តុះបណ្តាលស្តីពីការដាំដុះ ថែទាំកូនកៅស៊ូ ការប្រើប្រាស់ថ្នាំ សម្លាប់ស្មៅ ការគ្រប់គ្រងសមាសភាពចង្រៃនិងជំងឺកៅស៊ូ ការប្រមូលផល និងការកែច្នៃដល់កសិករ
– អនុវត្តបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ (CSR) សម្រាប់នាំចេញជ័រកៅស៊ូ អនុវត្តបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពច្បារពូជ ជំរុញការអនុវត្តកម្មវិធីផ្លាស់ប្តូរក្លូនពហុភាគីក្នុងរង្វង់ប្រទេសជាសមាជិកនៃ IRRDB
– បន្តការប្រមូលយកគំរូស្លឹកកៅស៊ូ នៅតាមបណ្តាច្បារពូជតាមបណ្តាខេត្តដើម្បីធ្វើការវិភាគ DNA តាមផែនការនិងជួសក្លូនដែលបានកំណត់ក្នុងគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជា
– បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវ និងកសាងលិខិតគតិយុត្តមួយចំនួន ពាក់ព័ន្ធវិធានទប់ស្កាត់ការនាំចេញកៅស៊ូ និងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេស
– ជំរុញការចងក្រងសហគមន៍កសិករកៅស៊ូគ្រួសារ
– បន្តទំនាក់ទំនងជាមួយចម្ការកៅស៊ូកសិឧស្សាហកម្ម និងចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ចនៅ ទូទាំងប្រទេស ក្នុងការចុះធ្វើបញ្ជីសារពើភ័ណ្ឌនិងវិភាគADN លើបណ្តាច្បារពូជទាំងនោះ ក្នុងក្របខណ្ឌគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជា
– បន្តពិនិត្យនិងរៀបចំឯកសារនានាពាក់ព័ន្ធនឹងការចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ជាមួយអតីតចម្ការកៅស៊ូរដ្ឋដែលបានធ្វើអវិនិយោគនិងក្រុមហ៊ុនដែលជួលដីចម្ការកៅស៊ូរដ្ឋ
– បង្កើនកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន (ខេត្ត ស្រុក និងសមត្ថកិច្ចនៅតាមច្រកព្រំដែន) ដើម្បីជួយទប់ស្កាត់សកម្មភាពការបើកស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារដែលគ្មានលិខិតអនុញ្ញាត និងការនាំចេញកៅស៊ូ និងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេសដោយខុសច្បាប់
– ពង្រីកដៃគូសហប្រតិបត្តិការក្នុងការគាំទ្រថវិកា និងបច្ចេកទេសដើម្បីគាំទ្រអភិវឌ្ឍន៍កៅស៊ូគ្រួសារ និងបន្តចូលរួមសហការជាមួយគ្រឹះស្ថានសិក្សានានា ក្នុងការបណ្តុះបណ្តាលធនធានមនុស្សខាងវិស័យកៅស៊ូ
– បន្តចុះផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក (USS) ដល់សហគមន៍កៅស៊ូគ្រួសារ។

## ៣ ផែនការផលិតកម្មសត្វ

### ក. សូចនាករទិសដៅ

– ជំរុញការចិញ្ចឹមគោទូទាំងប្រទេសឱ្យបានដល់ចំនួន៣លានក្បាល (កំណើន១%) និងការចិញ្ចឹមក្របីឱ្យបានដល់ចំនួន៥៨៤ពាន់ក្បាល (កំណើន០,៥%) នៅឆ្នាំ២០១៥

- ជំរុញការចិញ្ចឹមជ្រូកទូទាំងប្រទេសនៅឆ្នាំ២០១៥ ឱ្យបានដល់ចំនួន២,៧៩លានក្បាល (កំណើន២%)
- ជំរុញការចិញ្ចឹមបក្សីទូទាំងប្រទេសនៅឆ្នាំ២០១៥ ឱ្យបានដល់ចំនួន៣៣លានក្បាល (កំណើន៥%)
- ជំរុញការចាក់វ៉ាក់សាំងគោក្របីឱ្យបាន១,៦៩លានក្បាលនៅឆ្នាំ២០១៥
- បង្កើនការអនុវត្តវិធានការនានា ដើម្បីឱ្យសត្តឃាតដ្ឋានចំនួន៥០កន្លែង បានអនុវត្តអនាម័យសាច់សត្វស្របតាមស្តង់ដារបច្ចេកទេសសមស្រប។

### ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅគំណាត់

- ជំរុញការកសាងច្បាប់ លិខិតបទដ្ឋានផលិតកម្ម និងបសុព្យាបាល ជាពិសេស បន្តការងារពិភាក្សាបញ្ចប់លើសេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មកម្មសត្វ ប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ និងជំរុញការរៀបចំឯកសារគោលនយោបាយ និងផែនការយុទ្ធសាស្រ្ត ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ
- ពង្រឹងសមត្ថភាពមន្ត្រីរាជការ ផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីបង្កើនប្រសិទ្ធភាពការងារ សំដៅជំរុញការអភិវឌ្ឍផ្នែកផលិតកម្ម និងបសុព្យាបាលឱ្យមានការរីកចម្រើន ផ្តល់សេវាកម្មគាំទ្រលើផ្នែកចិញ្ចឹមសត្វគ្រប់ប្រភេទ ឱ្យមានការរីកចម្រើន ទាំងបរិមាណនិងគុណភាព តាមរយៈការផ្តល់បច្ចេកទេសសមស្របដូចជាការកែលម្អពូជ ចំណី ការចាក់ថ្នាំការពារ ជីវសុវត្ថិភាពជាដើម
- ជំរុញការចិញ្ចឹមសត្វតាមគ្រប់រូបភាព ដើម្បីទទួលបាននូវផលិតភាពខ្ពស់ មានគុណភាពនិងសុវត្ថិភាព ធ្វើការកែទម្លាប់កសិករពីការចិញ្ចឹមសត្វលែង មកជាការចិញ្ចឹមសត្វដាក់ទ្រុង ការចិញ្ចឹមសម្រាប់ការហូបចុកប្រចាំថ្ងៃមកជាការចិញ្ចឹមបែបពាណិជ្ជកម្ម ជំរុញនិងលើកទឹកចិត្តការវិនិយោគផលិតចំណីសត្វ និងជំរុញបន្ថែមទៀតលើការគ្រប់គ្រងកាកសំណល់សត្វ និងសាងសង់ឡជីវឧស្ម័ន
- ពង្រឹងការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ ទប់ស្កាត់ការរីករាលដាលជំងឺឆ្លងសត្វ និងជំងឺសូណូសតាមរយៈការអនុវត្តវិធានបសុពេទ្យ រួមមាន ការចាក់ថ្នាំការពារសត្វ ការព្យាបាលសត្វ ការគ្រប់គ្រងជីវសុវត្ថិភាព ការធ្វើអនាម័យ និងការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ ចេញ-ចូល និងឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា និងពង្រឹងការត្រួតពិនិត្យគុណភាព សុវត្ថិភាពចំណីសត្វ និងបសុឱសថ
- ពង្រឹងសមត្ថភាពបន្ថែមដល់ភ្នាក់ងារសុខភាពសត្វភូមិ តាមរយៈការបណ្តុះបណ្តាល និងការបំពាក់បំប៉នបន្ថែមដល់ភ្នាក់ងារសុខភាពសត្វភូមិ និងខិតខំធ្វើយ៉ាងណាឱ្យមាននិរន្តរភាព
- ចងក្រងសហគមន៍អ្នកចិញ្ចឹមសត្វនិងភ្នាក់ងារសុខភាពសត្វភូមិ
- ពង្រឹងការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ និងការធ្វើអាជីវកម្មពិឃាដសត្វ សំដៅធានាបាននូវគុណភាពសាច់មានអនាម័យគ្រប់គ្រាន់សម្រាប់បរិភោគ
- បង្កើនការងារស្រាវជ្រាវ អង្កេតតាមដាន ឃ្លាំមើលលើសុខភាពសត្វ និងជំងឺឆ្លងសត្វដើម្បី ទប់ស្កាត់ការរាលដាលជំងឺឆ្លងសត្វ និងរៀបចំចងក្រង បោះពុម្ពឯកសារបច្ចេកទេស ផលិតកម្ម និងបសុព្យាបាល ដើម្បីជំរុញនិងបង្កើនការងារផ្សព្វផ្សាយបច្ចេកទេសសុខភាពសត្វ និងផលិតកម្មសត្វ
- ជំរុញការលើកទឹកចិត្តដល់ផ្នែកឯកជននិងអ្នកវិនិយោគលើវិស័យចិញ្ចឹមសត្វ និងសេវាកម្មសុខភាពសត្វនិងជួយស្វែងរកទីផ្សារសត្វឱ្យប្រជាកសិករចិញ្ចឹមសត្វដោយយកចិត្តទុកដាក់បំផុត
- បន្តនិងធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការលើវិស័យផលិតកម្ម និងបសុព្យាបាលជាមួយបណ្តាប្រទេសជាមិត្ត ដៃគូរអភិវឌ្ឍន៍ អង្គការជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ស្ថាប័នពាក់ពន្ធ័ និងកិច្ចសហការជាមួយផ្នែកឯកជន។

## ៤ ទិសដៅនិងផែនការក្នុងវិស័យជលផល

### ក. សូចនាករទិសដៅ

- ការប្រមូលផលនេសាទទឹកសាបទូទាំងប្រទេសនឹងត្រូវរក្សាឱ្យបានក្នុងរង្វង់៥១២ពាន់តោន នៅឆ្នាំ២០១៥ ដោយផ្អែកលើកំណើនប្រមាណ១,៣៩%ធៀបនឹងឆ្នាំមុន

- ការធ្វើផលិតកម្មនេសាទសមុទ្រទូទាំងប្រទេសនឹងត្រូវរក្សាឱ្យបានក្នុងរង្វង់១១០ពាន់តោន នៅឆ្នាំ២០១៥
- ជំរុញការធ្វើផលិតកម្មវារីវប្បកម្មឱ្យបានដល់ចំនួន១៤៤ពាន់តោន (កំណើន២០%ធៀបនឹងឆ្នាំមុន) ផលិតកូនត្រីពូជឱ្យបាន១៨០លានកូន
- ដាំព្រៃលិចទឹកនិងព្រៃកោងកាងឱ្យបាន១០០ហ.តក្នុងឆ្នាំ២០១៥
- សហគមន៍នេសាទចំនួន១០០ ក្នុង២០១៥ នឹងត្រូវបានពង្រឹងសមត្ថភាពគ្រប់គ្រងនិងប្រតិបត្តិប្រសើរជាងមុន

### ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់ និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល និងរៀបចំពង្រឹងសង្កាត់រដ្ឋបាលជលផលគ្មានបទល្មើស
- ជំរុញការត្រួតពិនិត្យ និងតាមដានការបង្ក្រាបបទល្មើសជលផល
- រៀបចំបោះបង្គោលបេតុងចំនួន៥១បង្គោល និងសាងសង់ស្លាក់ការល្បាតចំនួន០៧កន្លែង នៅកន្លែងអភិរក្សជលផល ក្នុងនោះស្នាក់ការបណ្តែតទឹក០៤កន្លែង
- រៀបចំបោះបង្គោលអភិរក្សព្រៃកោងកាង៥០បង្គោល
- ទំលាក់ប្រអប់ថ្មចំនួន៨០០ប្រអប់ ក្នុងកន្លែងអភិរក្សជលផលទឹកសាប
- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទឱ្យក្លាយជាសហគមន៍ដែលមានការទទួលខុសត្រូវ និងគ្មានបទល្មើស
- រៀបចំនិងអនុវត្តវិធានការការពារដែននេសាទនិងធនធានជលផល
- បន្តស្រាវជ្រាវដកហូត និងបោះបង្គោលដីព្រៃលិចទឹក ដែលកាន់កាប់អនាធិបតេយ្យ ដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ
- បន្តជំរុញការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មឱ្យបានខ្លាំងក្លាបន្ថែមទៀត
- បន្តការផ្សព្វផ្សាយដល់អ្នកកែច្នៃផលនេសាទគ្រប់ប្រភេទអំពី អនាម័យនិងគុណភាព ដើម្បីសុវត្ថិភាពចំណីអាហាររបស់ប្រជាពលរដ្ឋ
- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀត
- បន្តរៀបចំទិវាមច្ឆជាតិ ១កក្កដា ឆ្នាំ២០១៥ទូទាំងប្រទេស សំដៅបង្កើនការយល់ដឹងអំពី សារៈសំខាន់ដល់ធនធានជលផល
- ខិតខំប្រមូលចំណូលឱ្យបាន ៣.០០០លានរៀល នៅឆ្នាំ២០១៥។

## ៥. ទិសដៅនិងផែនការក្នុងវិស័យព្រៃឈើ

### ក. សូចនាករទិសដៅ

- បង្កើតតំបន់ព្រៃការពារ និងអភិរក្សសត្វព្រៃ ឱ្យសម្រេចបានលើផ្ទៃដីប្រមាណ១,៦លានហ.ត នៅឆ្នាំ២០១៥
- សកម្មភាពនៃការដាំដើមឈើឡើងវិញនឹងត្រូវសម្រេចឱ្យបានប្រមាណ២២.៣០០ហ.ត ដោយត្រូវយកចិត្តទុកដាក់លើការជំរុញការដាំដុះពីវិស័យឯកជននិងគ្រួសារ និងត្រូវបណ្តុះកូនឈើឱ្យបាន១០លានដើមក្នុងឆ្នាំ២០១៥
- ចំនួនសហគមន៍ព្រៃឈើនៅ២០១៥ នឹងកើនដល់៥២០ សហគមន៍ (៤៤សហគមន៍នឹងត្រូវបានបង្កើតនៅឆ្នាំ២០១៥)
- ការបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ នឹងត្រូវអនុវត្តឱ្យបានប្រមាណ៤៥៥គីឡូម៉ែត្រ ក្នុងឆ្នាំ២០១៥

### ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់

- បង្កើនសកម្មភាពអាទិភាព ការអនុវត្តច្បាប់ស្តីពីព្រៃឈើ ដើម្បីធ្វើឱ្យសម្រេចបាននូវការពង្រីកគម្របព្រៃឈើពិសេស ការបង្កើនការបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃ ទប់ស្កាត់ឱ្យមានប្រសិទ្ធភាព លើការហ៊ុមព័ទ្ធដីព្រៃ ការឈូសឆាយដីព្រៃធ្វើជាកម្មសិទ្ធិ
- ធ្វើការបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ឱ្យបានប្រវែង៤៥៥គីឡូម៉ែត្រ
- បន្តរៀបចំបង្កើតតំបន់ព្រៃការពារ និងតំបន់អភិរក្សសត្វព្រៃបន្ថែម
- បន្តសិក្សាស្រាវជ្រាវ និងកំណត់តំបន់ព្រៃឈើដែលមានសក្តានុពលសម្រាប់ទេសចរណ៍ធម្មជាតិ
- បន្តពង្រឹងការគ្រប់គ្រងតំបន់ព្រៃការពារ និងតំបន់អភិរក្សសត្វព្រៃ

– បន្តផ្សព្វផ្សាយដល់សាធារណៈជនអំពី សារៈសំខាន់នៃតំបន់ព្រៃការពារ
– បន្តរៀបចំផែនការគ្រប់គ្រងព្រៃការពារ
– បន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ដើម្បីគ្រប់គ្រង និងអភិរក្សព្រៃការពារ
– ជំរុញការចូលរួមពីអ្នកពាក់ពន្ធ័ពិសេសវិស័យឯកជនឱ្យចូលរួមក្នុងសកម្មភាពដាំឈើ សម្រាប់ផលប្រយោជន៍សេដ្ឋកិច្ចដើម្បីសម្រេចបានតាមផែនការ ២២.៣០០ហ.ត
– ជំរុញការបង្កើតថ្នាលបណ្តុះកូនឈើជាលក្ខណៈគ្រួសារនិងឯកជន។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងសហការជាមួយស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ បន្តអនុវត្តដោយយកចិត្តទុកដាក់ខ្ពស់ និងប្រកបដោយប្រសិទ្ធភាពលើកិច្ចការទាំងអស់នេះ ហើយសមិទ្ធផលថ្មីៗដែលនឹងបង្កើតឡើងពិតជានឹងរួមចំណែកយ៉ាងសំខាន់ដល់កិច្ចអភិវឌ្ឍនិងវិបុលភាព នៅលើមូលដ្ឋានកាន់តែទូលាយជាងមុនប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈកាន់តែអំណោយផលដល់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចជាតិប្រកបដោយចិរភាព។

## X- សេចក្តីសន្និដ្ឋាន

ផ្អែកលើសមិទ្ធផលដែលទទួលបានក្នុងរយៈពេលពេញមួយឆ្នាំ នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា យើងអាចវាយតម្លៃជារួមថា បើទោះបីជាបានជួបប្រទះនូវគ្រោះធម្មជាតិរួមមានគ្រោះរាំងស្ងួត គ្រោះជំនន់ទឹកភ្លៀងរដូវវស្សា ការបំផ្លាញដោយសត្វល្អិតចង្រៃ តែក្រោមការខិតខំប្រឹងប្រែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការណែនាំនិងតម្រង់ទិស ក៏ដូចជាវិធានការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយមានការចូលរួមដ៏សកម្មពីគ្រប់ក្រសួងស្ថាប័ន អាជ្ញាធរមូលដ្ឋានកងកម្លាំងប្រដាប់អាវុធ ព្រមទាំងការរួមចំណែកពីដៃគូអភិវឌ្ឍន៍ គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយបាននូវការលំបាកផ្សេងៗដូចបានរៀបរាប់ខាងលើ បានធ្វើឱ្យផលិតកម្មកសិកម្ម មានការរីកចម្រើនគួរឱ្យកត់សម្គាល់។

ជារួមផលិតកម្មដំណាំ ពិសេសដំណាំស្រូវតាមការកត់សម្គាល់ឃើញថា បានទទួលលទ្ធផលគួរជាទីពេញចិត្ត ហើយអាចសល់ស្បៀង (ជាអង្ករ) សរុបចំនួនជាង៣លានតោន (ឬ៤,៧លានតោនស្រូវ) នៅឆ្នាំ២០១៤ ដែលនេះជាជោគជ័យមួយគួរជាទីមោទនៈបំផុតសម្រាប់កម្ពុជា។ ជារួមកត្តាកើនឡើងនៃទិន្នផលផលិតកម្មកសិកម្មកម្ពុជា ពិសេសផលិតកម្មស្រូវពីមួយឆ្នាំទៅមួយឆ្នាំ មានការវិវឌ្ឍឈានឡើងជាលំដាប់ ដោយសារកត្តា២យ៉ាងគឺ (១) ការពង្រីកផ្ទៃដីដាំដុះដែលរួមទាំងការធ្វើបង្កើនរដូវនិងប្រពលវប្បកម្ម (២) សមិទ្ធផលនៃការសិក្សាស្រាវជ្រាវ ផ្សព្វផ្សាយពូជថ្មី បច្ចេកទេសដាំដុះសមស្រប ការថែទាំប្រកបដោយប្រសិទ្ធភាពពិសេសការកែប្រែទម្លាប់របស់ប្រជាកសិករ។

ដំណាំឧស្សាហកម្ម ដំណាំឈើហូបផ្លែនិងដំណាំអចិន្ត្រៃយ៍ កំពុងមានការរីកចម្រើនជាបន្តបន្ទាប់ ជាលក្ខណៈគ្រួសារនិងជាលក្ខណៈវិនិយោគខ្នាតតូច មធ្យម និងធំ។ ជាក់ស្តែង ផ្ទៃដីកៅស៊ូមានសន្ទុះកើនឡើង ពិសេសការអភិវឌ្ឍកៅស៊ូគ្រួសារ មានការវិវឌ្ឍតាមសន្ទុះមួយគួរឱ្យចាប់អារម្មណ៍។

ផលិតកម្មសត្វ គោ ក្របី ជ្រូក មាន់ ទា មានការវិវឌ្ឍរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយសារការបង្កើនការងារផ្សព្វផ្សាយពូជ ការបង្ការជំងឺឆ្លងសត្វ និងការពង្រីកចំណេះដឹងផ្នែកបច្ចេកទេសនៃការចិញ្ចឹមសត្វដល់ប្រជាកសិករបានទូលាយជាងមុន។

ការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងជលផល ពិសេសកំណែទម្រង់ក្នុងវិស័យទាំងពីរនេះ កំពុងស្ថិតនៅតែជាប្រធានបទតឹងតែង ស្មុគស្មាញ ហើយដែលត្រូវតែខិតខំបន្តសកម្មភាព ជាមួយនឹងការបន្តពង្រឹងការអនុវត្តច្បាប់និងបទដ្ឋានផ្សេងៗក្នុងស្មារតីទទួលខុសត្រូវខ្ពស់បំផុត។

ដោយឡែក កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា រួមទាំងវិស័យឯកជនផងដែរ កំពុងត្រូវបានពង្រឹងនិងយកចិត្តទុកដាក់ខ្ពស់រួមទាំងការអភិវឌ្ឍន៍ធនធានមនុស្ស ដែលជាកត្តាគន្លឹះសំខាន់មិនអាចមើលរំលងបានឡើយ។ រីឯដំណើរការប្រព្រឹត្តទៅនៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាការលើកកម្ពស់ការពង្រឹងរចនាសម្ព័ន្ធចាត់តាំងក្បាលម៉ាស៊ីនដឹកនាំរបស់ក្រសួងទាំងថ្នាក់កណ្តាល រួមទាំងមន្ទីរកសិកម្មរាជធានី ខេត្តទាំងអស់ ក៏ត្រូវបានពង្រឹងក្នុងស្មារតីយកចិត្តទុកដាក់ខ្ពស់និងប្រព្រឹត្តទៅប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។

លើសពីនេះទៅទៀត ផ្នែកសេវាកម្មនិងការគាំទ្រផ្សេងៗ ក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរ ស្របតាមគោលការណ៍ និងទិសដៅរបស់រាជរដ្ឋាភិបាល ពិតមែនតែនៅជួបប្រទះបញ្ហាប្រឈមខ្លះៗក៏ដោយ។ គ្រប់ផ្នែកទាំងអស់ក៏មិនដែលមើលរំលងអំពីការចូលរួមយ៉ាងសកម្មរបស់កិច្ចការយេនឌ័រផងដែរ។ ទន្ទឹមនឹងនេះអង្គភាពជំនាញនីមួយៗជាសេនាធិការនឹងបន្តអនុវត្តតាមទិសដៅ និងផែនការយុទ្ធសាស្ត្រដែលបានដាក់ចុះសម្រាប់ឆ្នាំ ២០១៥-២០១៦ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់។ តែទោះយ៉ាងណាក្តី ផ្លូវនៅវែងឆ្ងាយទៀត ដើម្បីសម្រេចបានគោលដៅនិងមហិច្ឆតាធំធេងដែលយើងចង់បាន សម្រាប់ការអភិវឌ្ឍវិស័យកសិកម្មកម្ពុជាមួយតាមលក្ខណៈវិទ្យាសាស្ត្រទំនើបនិងមានប្រសិទ្ធភាពខ្ពស់ ជាពិសេសការចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ការលើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិតាមទិសដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ក៏ដូចជាក្នុងបរិបទនៃសកលភាវូបនីយកម្ម ក្រោមការដឹកនាំតម្រង់ទិសប្រកបដោយគតិបណ្ឌិតដ៏ត្រឹមត្រូវ និងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

រាជធានីភ្នំពេញ,ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

# ឧបសម្ព័ន្ធ

# ផែនការផលិតកម្មដំណាំស្រូវឆ្នាំ២០១៥-២០១៦

ឧបសម្ព័ន្ធទី ១

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានឆ្នាំ២០១៤-២០១៥ | | | ទិសដៅសម្រាប់ឆ្នាំ២០១៥-២០១៦ | |
|---|---|---|---|---|---|---|---|
| | | | ផែនការ | សម្រេចបាន | % ធៀប ផែនការ | ផែនការ | បញ្ជាក់មូលហេតុ បម្រែបម្រួល |
| ១ | **ផ្ទៃដីដាំដុះស្រូវប្រចាំឆ្នាំ** | **ហ.ត** | **2,827,137** | **3,055,507** | **108.08** | **3,058,563** | លក្ខខណ្ឌធម្មជាតិ (ជំនន់និងរាំងស្ងួត) មិនអាចព្យាករណ៍ជាមុនបាន។ ដូចនេះផែនការដាំដុះគ្រោងកើន០,១% ធៀបនឹងលទ្ធផលសម្រេចបានឆ្នាំ២០១៤។ |
| | ផ្ទៃដីដាំដុះស្រូវវស្សា | ហ.ត | 2,411,207 | 2,564,572 | 106.36 | 2,567,137 | |
| | ផ្ទៃដីដាំដុះស្រូវប្រាំង | ហ.ត | 415,930 | 490,935 | 118.03 | 491,426 | |
| ២ | **ទិន្នផលស្រូវ** | **តោន/ហ.ត** | **3.160** | **3.052** | **96.58** | **3.122** | គ្រោងកើន២,៣% ធៀបនឹងទិន្នផលឆ្នាំ២០១៤ |
| | ទិន្នផលស្រូវវស្សា | តោន/ហត | 2.920 | 2.815 | 96.40 | 2.900 | |
| | ទិន្នផលស្រូវប្រាំង | តោន/ហត | 4.383 | 4.443 | 101.37 | 4.448 | |
| ៣ | **បរិមាណផលប្រចាំឆ្នាំ** | **តោន** | **8,863,746** | **9,233,976** | 104.18 | **9,550,320** | គ្រោងកើន៣,៤% ធៀបនឹងបរិមាណផលសម្រេចបានឆ្នាំ២០១៤ ប្រសិនបើការខូចខាតមានចំនួន២៥ពាន់ហត។ |
| | បរិមាណផលស្រូវវស្សា | តោន | 7,040,724 | 7,089,248 | 100.69 | 7,386,697 | |
| | បរិមាណផលស្រូវប្រាំង | តោន | 1,823,021 | 2,144,728 | 117.65 | 2,163,623 | |

# ផែនការផលិតកម្មដំណាំរួមផ្សំ និងឧស្សាហកម្ម២០១៥-២០១៦

ឧបសម្ព័ន្ធទី ២

| ល.រ | ប្រភេទដំណាំ | ឯកតា | លទ្ធផលសម្រេចបានឆ្នាំ២០១៤-១៥ | | | ទិសដៅសម្រាប់ផែនការឆ្នាំ២០១៥-១៦ | |
|---|---|---|---|---|---|---|---|
| | | | ផែនការ ២០១៤-១៥ | សម្រេចបាន ២០១៤-១៥ | % ធៀបផែនការ | ផែនការ ២០១៥-១៦ | បញ្ជាក់បម្រែបម្រួល |
| ១ | ពោត | ហ.ត | 218,200 | 143,517 | 65.77 | 146,387 | កំណើននឹងសម្រេចបានកើនឡើង២% |
| ២ | ដំឡូងមី | ហ.ត | 421,000 | 521,459 | 123.86 | 531,888 | ក្នុងលក្ខខណ្ឌធម្មជាតិអំណោយផល |
| ៣ | ដំឡូងជ្វា | ហ.ត | 7,000 | 5,915 | 84.50 | 6,033 | |
| ៤ | បន្លែ | ហ.ត | 52,000 | 51,637 | 99.30 | 52,670 | |
| ៥ | សណ្តែកបាយ | ហ.ត | 54,000 | 53,294 | 98.69 | 54,360 | |
| | **សរុប** | | **752,200** | **775,822** | **103.14** | **791,338** | |
| ១ | សណ្តែកដី | ហ.ត | 19,000 | 17,818 | 93.78 | 18,174 | កំណើននឹងសម្រេចបានកើនឡើង២% |
| ២ | សណ្តែកសៀង | ហ.ត | 80,000 | 72,511 | 90.64 | 73,961 | ក្នុងលក្ខខណ្ឌធម្មជាតិអំណោយផល |
| ៣ | ល្ង | ហ.ត | 23,000 | 28,170 | 122.48 | 28,733 | |
| ៤ | អំពៅ | ហ.ត | 24,000 | 48,357 | 201.49 | 49,324 | |
| ៥ | ក្រចៅ | ហ.ត | 190 | 192 | 101.05 | 196 | |
| ៦ | ថ្នាំជក់ | ហ.ត | 10,000 | 10,727 | 107.27 | 10,942 | |
| | **សរុប** | ហ.ត | **156,190** | **177,775** | **113.82** | **181,331** | |
| | **សរុបរួម** | | **908,390** | **953,597** | **104.98** | **972,669** | |

# ផែនការផលិតកម្មដំណាំកៅស៊ូ ឆ្នាំ២០១៥

ឧបសម្ព័ន្ធទី ៣

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានឆ្នាំ២០១៤ | | | ទិសដៅសម្រាប់ផែនការឆ្នាំ២០១៥ | |
|---|---|---|---|---|---|---|---|
| | | | ផែនការ២០១៤ | សម្រេចបាន | ភាគរយ | ផែនការ | បញ្ជាក់ បម្រែបម្រួល |
| I | ផ្ទៃដីដាំដុះកៅស៊ូ | | | | | | |
| ១ | កៅស៊ូកសិឧស្សាហកម្ម□ | ហិកតា | *213,000* | *218,600* | *102.63* | 221,834 | |
| | ក. កសិឧស្សាហកម្មអវិនិយោគរបស់រដ្ឋ | ហិកតា | 56,000 | 56,900 | *101.61* | **56,900** | មិនមានការកើនឡើងទេ |
| | ខ. កសិឧស្សាហកម្មវិនិយោគឯកជន | ហិកតា | 157,000 | 161,700 | *102.99* | **164,934** | កើនប្រមាណ២% ក្នុងមួយឆ្នាំ |
| ២ | ចម្ការកៅស៊ូគ្រួសារ | ហិកតា | 144,000 | 140,300 | *97.43* | **143,106** | កើនប្រមាណ២% ក្នុងមួយឆ្នាំ |
| | សរុបរួម | | **357,000** | **358,900** | ***100.53*** | **364,940** | កើនប្រមាណ១,៦៨% ធៀបឆ្នាំមុន |
| II | ផលិតកម្មកៅស៊ូ | | | | | | |
| | ផលិតផលកៅស៊ូ | តោន | 96,000 | 96,800 | *100.83* | **106,480** | កើនប្រមាណ១០% ក្នុងមួយឆ្នាំ |

# ផែនការផលិតកម្មសត្វឆ្នាំ២០១៥

. ឧបសម្ព័ន្ធទី ៤

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានឆ្នាំ២០១៤ | | | ទិសដៅផែនការឆ្នាំ ២០១៥ | |
|---|---|---|---|---|---|---|---|
| | | | ផែនការ | សម្រេចបាន | ភាគរយ | ផែនការ | បញ្ជាក់ បម្រែបម្រួល |
| ១ | ការចិញ្ចឹមគោ | ក្បាល | 3,465,000 | 3,059,927 | *88.31* | **3,090,526** | កំណើន១% |
| ២ | ការចិញ្ចឹមក្របី | ក្បាល | 650,000 | 541,859 | *83.36* | **544,568** | កំណើន០,៥% |
| ៣ | ការចិញ្ចឹមជ្រូក | ក្បាល | 2,509,800 | 2,735,717 | *109.00* | **2,790,431** | កំណើន២% |
| ៤ | ការចិញ្ចឹមបក្សី | ក្បាល | 28,682,200 | 31,583,657 | *110.12* | **33,162,840** | កំណើន៥% |
| ៥ | សត្វគោក្របីចាក់វ៉ាក់សាំង | លានក្បាល | | | | **1.69** | |
| ៦ | សត្តឃាតដ្ឋានអនុវត្ត GAP | ចំនួន | 25 | | - | **50** | |

# ផែនការផលិតកម្មជលផលឆ្នាំ២០១៥

ឧបសម្ព័ន្ធទី ៥

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានឆ្នាំ២០១៤ | | | ទិសដៅសម្រាប់ឆ្នាំ២០១៥ | |
|---|---|---|---|---|---|---|---|
| | | | ផែនការ | សម្រេចបាន | % ធៀបផែនការ | ផែនការ | បញ្ជាក់មូលហេតុ បម្រែបម្រួល |
| ១ | នេសាទទឹកសាប | តោន | 585,000 | 505,005 | 86.33 | 512,000 | កំណើន ១,៣៩% ធៀបឆ្នាំ២០១៤ |
| ២ | នេសាទសមុទ្រ | តោន | 110,000 | 120,055 | 109.14 | 110,000 | |
| ៣ | វារីវប្បកម្ម | តោន | 100,000 | 120,055 | 120.06 | 144,000 | កំណើន ២០% ធៀបឆ្នាំ២០១៤ |
| ៤ | ផលិតកូនត្រីពូជ | លានក្បាល | | | | 180 | |
| ៥ | សហគមន៍នេសាទត្រូវបានពង្រឹងសមត្ថភាព | សហគមន៍ | 100 | 100 | 100.00 | 100 | |
| ៦ | ការដាំព្រៃលិចទឹកនិងព្រៃកោងកាង | ហ.ត | 100 | 90 | 90.00 | 100 | |

# ផែនការវែ្លកព្រៃឈើឆ្នាំ២០១៥

ឧបសម្ព័ន្ធទី ៦

| ល.រ | សូចនាករលទ្ធផល | ឯកតា | លទ្ធផលសម្រេចបានឆ្នាំ២០១៤ | | | ទិសដៅអនុវត្តឆ្នាំ២០១៥ | |
|---|---|---|---|---|---|---|---|
| | | | ផែនការ | សម្រេចបាន | (%) ធៀបផែនការ | ផែនការ | បញ្ជាក់មូលហេតុបម្រែបម្រួល |
| ១ | ព្រៃការពារ និងតំបន់អភិរក្សសត្វព្រៃ | លានហ.ត | 1.55 | 1.57 | 101.03 | 1.60 | |
| ២ | ផ្ទៃដីដាំព្រៃឡើងវិញ | ហិកតា | 20,280 | 5,422 | 26.74 | 22,300 | វិស័យឯកជននឹងចូលក្នុងសកម្មភាពនេះ |
| ៣ | បណ្តុះកូនឈើ | លានដើម | 10 | 3.98 | 39.75 | 10 | ថ្នាលបណ្តុះកូនឈើជាលក្ខណៈគ្រួសារនិងឯកជននឹងកើនឡើង |
| ៤ | ចំនួនសហគមន៍ព្រៃឈើត្រូវបានបង្កើន និងពង្រឹងសមត្ថភាព | ចំនួនសហគមន៍ | 489 | 476 | 97.34 | 520 | រៀបចំឱ្យបាន៤៤សមគមន៍បន្ថែមទៀតដើម្បីសម្រេចបានតាមផែនការ |
| ៥ | ប្រវែងព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវបានបោះបង្គោល | គម | 350 | 160 | 45.71 | 455 | ដៃគូអភិវឌ្ឍន៍នឹងមានការចូលរួម |

# ស្ថិតិផ្ទៃដីភ្ជួររាស់ និងផ្ទៃដីដាំដុះដំណាំស្រូវរដូវវស្សាឆ្នាំ ២០១៤

ឧបសម្ព័ន្ធទី ៧

| ល.រ | រាជធានី-ខេត្ត | ផែនការ (ហត) | ផ្ទៃដីភ្ជួររាស់ (ហ.ត) | | | | | ផ្ទៃដីសាប (ហត) | ផ្ទៃដីព្រោះស្ទូង និងបុកដាំ (ហត) | | | | | | សរុបស្ទូងនិងព្រោះបុកដាំ (ហត) | ភាគរយ (%) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប | គោ-ក្របី | | គ្រឿងយន្ត | | | ស្រូវស្រាល | | កណ្ដាល | ធ្ងន់ | ចំការ | ឡើងទឹក | | |
| | | | | ហ.ត | % | ហ.ត | % | | សរុប | បង្កើនរដូវ | | | | | | |
| 01 | បន្ទាយមានជ័យ | 235,000 | 246,138 | 744 | 0.30 | 245,394 | 99.70 | 135 | 44,753 | 26,459 | 133,937 | 54,863 | - | 10,172 | 243,725 | 103.71 |
| 02 | បាត់ដំបង | 252,000 | 296,181 | 1,028 | 0.35 | 295,153 | 99.65 | 1,202 | 71,458 | 25,675 | 115,458 | 95,549 | 787 | 11,809 | 295,061 | 117.09 |
| 03 | កំពង់ចាម | 86,540 | 87,483 | 31,611 | 36.13 | 55,872 | 63.87 | 4,182 | 18,861 | 4,640 | 33,393 | 33,917 | - | 1,050 | 87,221 | 100.79 |
| 04 | កំពង់ឆ្នាំង | 109,500 | 191,570 | 73,037 | 38.13 | 118,533 | 61.87 | 18,295 | 7,279 | 1,407 | 90,581 | 23,282 | - | 511 | 121,653 | 111.10 |
| 05 | កំពង់ស្ពឺ | 113,600 | 175,175 | 96,723 | 55.22 | 78,452 | 44.78 | 13,424 | 22,499 | 1,773 | 68,839 | 16,053 | 375 | - | 107,766 | 94.86 |
| 06 | កំពង់ធំ | 210,000 | 214,671 | 86,952 | 40.50 | 127,719 | 59.50 | 6,613 | 30,289 | 7,033 | 100,920 | 63,132 | 4,704 | 14,036 | 213,081 | 101.47 |
| 07 | កំពត | 126,000 | 135,528 | 57,460 | 42.40 | 78,068 | 57.60 | 15,348 | 16,436 | 16,436 | 67,713 | 52,249 | - | - | 136,398 | 108.25 |
| 08 | កណ្ដាល | 40,000 | 51,673 | 12,033 | 23.29 | 39,640 | 76.71 | 1,744 | 13,023 | 6,636 | 12,801 | 13,180 | 940 | 74 | 40,018 | 100.05 |
| 09 | កោះកុង | 10,400 | 9,171 | 2,219 | 24.20 | 6,952 | 75.80 | 859 | 2,363 | - | 5,694 | 1,100 | 1,244 | - | 10,401 | 100.01 |
| 10 | ក្រចេះ | 32,100 | 33,267 | 9,093 | 27.33 | 24,174 | 72.67 | 3,179 | 12,909 | 785 | 15,675 | 4,226 | 65 | - | 32,875 | 102.41 |
| 11 | មណ្ឌលគិរី | 20,000 | 24,300 | 1,160 | 4.77 | 23,140 | 95.23 | 3,816 | 3,922 | - | 10,795 | 4,675 | 3,631 | - | 23,023 | 115.12 |
| 12 | ភ្នំពេញ | 11,557 | 11,467 | 4,557 | 39.74 | 6,910 | 60.26 | 1,369 | 4,164 | - | 4,440 | 2,684 | - | - | 11,288 | 97.67 |
| 13 | ព្រះវិហារ | 75,570 | 75,439 | 6,768 | 8.97 | 68,671 | 91.03 | 3,349 | 11,300 | - | 43,369 | 18,619 | 3,280 | - | 76,568 | 101.32 |
| 14 | ព្រៃវែង | 250,000 | 272,532 | 43,258 | 15.87 | 229,274 | 84.13 | 1,771 | 90,891 | 21,090 | 146,853 | 34,685 | - | 103 | 272,532 | 109.01 |
| 15 | ពោធិសាត់ | 100,000 | 115,141 | 18,297 | 15.89 | 96,844 | 84.11 | 6,424 | 47,856 | - | 32,423 | 22,146 | 2,112 | 6,569 | 111,106 | 111.11 |
| 16 | រតនគិរី | 26,500 | 14,329 | 4,614 | 32.20 | 9,715 | 67.80 | 1,419 | 3,793 | - | 5,144 | 5,392 | 11,737 | - | 26,066 | 98.36 |
| 17 | សៀមរាប | 180,000 | 232,480 | 73,320 | 31.54 | 159,160 | 68.46 | 10,110 | 39,060 | | 87,970 | 42,055 | 6,735 | 8,215 | 184,035 | 102.24 |
| 18 | ព្រះសីហនុ | 16,500 | 16,510 | 4,953 | 30.00 | 11,557 | 70.00 | 621 | 1,695 | - | 10,017 | 4,855 | - | - | 16,567 | 100.41 |
| 19 | ស្ទឹងត្រែង | 27,400 | 25,183 | 9,173 | 36.43 | 16,010 | 63.57 | 2,341 | 13,956 | - | 9,913 | 1,314 | 2,668 | - | 27,851 | 101.65 |
| 20 | ស្វាយរៀង | 165,500 | 169,202 | 31,047 | 18.35 | 138,155 | 81.65 | 2,382 | 66,968 | 8,934 | 96,365 | 3,423 | - | - | 166,756 | 100.76 |
| 21 | តាកែវ | 170,000 | 408,470 | 130,915 | 32.05 | 277,555 | 67.95 | 6,931 | 106,702 | 51,198 | 85,494 | 7,409 | - | - | 199,605 | 117.41 |
| 22 | ឧត្តរមានជ័យ | 67,000 | 81,545 | 565 | 0.69 | 80,980 | 99.31 | 1,080 | 18,339 | - | 40,606 | 7,245 | 5,810 | - | 72,000 | 107.46 |
| 23 | កែប | 3,080 | 3,469 | 2,186 | 63.02 | 1,283 | 36.98 | 570 | 911 | | 2,184 | 374 | - | - | 3,469 | 112.63 |
| 24 | ប៉ៃលិន | 4,000 | 6,497 | - | - | 6,497 | 100.00 | 45 | 1,428 | - | 4,774 | 295 | - | - | 6,497 | 162.43 |
| 25 | ត្បូងឃ្មុំ | 78,960 | 82,696 | 13,471 | 16.29 | 69,225 | 83.71 | 6,153 | 10,251 | 4,176 | 30,901 | 37,858 | - | - | 79,010 | 100.06 |
| សរុប | | **2,411,207** | **2,980,117** | **715,184** | **24.00** | **2,264,933** | **76.00** | **113,362** | **661,106** | **176,242** | **1,256,259** | **550,580** | **44,088** | **52,539** | **2,564,572** | **106.36** |
| តួលេខឆ្នាំមុន | | **2,399,837** | **3,274,398** | **960,326** | **29.33** | **2,314,072** | **70.67** | **158,925** | **660,219** | **188,096** | **1,236,038** | **557,861** | **47,543** | **66,062** | **2,567,723** | **107.00** |
| ប្រៀបធៀប | | **11,370** | **-294,281** | **-245,142** | **-5.33** | **-49,139** | **5.33** | **-45,563** | **887** | **-11,854** | **20,221** | **-7,281** | **-3,455** | **-13,523** | **-3,151** | **-0.64** |

# ផ្ទៃដីប៉ះពាល់ និងខូចខាតលើដំណាំស្រូវរដូវវស្សាឆ្នាំ២០១៤

ឧបសម្ព័ន្ធទី ៨

| ល.រ | រាជធានី-ខេត្ត | បញ្ចប់ផ្ទៃដីអនុវត្តបាន | ប៉ះពាល់និងខូចខាតដោយប្រការផ្សេងៗ | | | | | | | | ផ្ទៃដស្តារឡើងវិញ (ហ.ត) | ផ្ទៃដីនៅសល់អាចប្រមូលផលបាន (ហ.ត) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ប៉ះពាល់ (ហ.ត) | | | | ខូចខាត (ហ.ត) | | | | | |
| | | | រាំងស្ងួត | សត្វល្អិត | ទឹកជំនន់ | សរុប | រាំងស្ងួត | សត្វល្អិត | ទឹកជំនន់ | សរុប | | |
| 01 | បន្ទាយមានជ័យ | 243,725 | 3,178 | 1,546 | | **4,724** | 2,178 | 1,546 | | **3,724** | | 240,001 |
| 02 | បាត់ដំបង | 295,061 | 44,352 | | 1,080 | **45,432** | 11,353 | | 930 | **12,283** | 2,573 | 285,351 |
| 03 | កំពង់ចាម | 87,221 | | | 7,402 | **7,402** | | | 2,704 | **2,704** | 2,116 | 86,633 |
| 04 | កំពង់ឆ្នាំង | 121,653 | 255 | | 353 | **608** | 255 | | 263 | **518** | - | 121,135 |
| 05 | កំពង់ស្ពឺ | 107,766 | 2,763 | | | **2,763** | 531 | | | **531** | 531 | 107,766 |
| 06 | កំពង់ធំ | 213,081 | | | 9,919 | **9,919** | | | 2,465 | **2,465** | 808 | 211,424 |
| 07 | កំពត | 136,398 | | | | **-** | | | | **-** | | 136,398 |
